ព្រឹត្តិបត្រប្រចាំខែ

*Monthly Newsletter*

# ការអប់រំ និង បច្ចេកវិទ្យា

# Education & Technology








ឆ្នាំទី១ លេខ០០២ ចេញផ្សាយប្រចាំខែកញ្ញា-ធ្នូ ឆ្នាំ២០២១



ការិយាល័យ: សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ ៧ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម

ប្រអប់សំបុត្រ: P.O Box ១៦២១ ភ្នំពេញ កម្ពុជា

042-941-481 / 042-941-918

kape@kapekh.org www.kapekh.org

www.facebook.com/kapeaction

www.youtube.com/TheKapeCambodia

www.linkedin.com/in/kapecambodia/

www.twitter.com/KAPECambodia

# មាតិកា

ទំព័រ


១-២ អំពីអង្គការ ខេប ចំនួនគម្រោងកំពុងប្រតិបត្តិ និងម្ចាស់ជំនួយក្នុងឆ្នាំ២០២១

## ១. ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ (NGS)

៤ ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលពិតជាសំខាន់ក្នុងការរស់នៅប្រចាំថ្ងៃ

៥ ការផ្ទេរការគាំទ្របន្តសាលារៀនជំនាន់ថ្មីខេត្តស្វាយរៀង ជូនក្រសួងអប់រំ យុវជន និងកីឡា

៧ ដំណើរទស្សនកិច្ចគណៈប្រតិភូសហគមន៍អឺរ៉ុប និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំងនៅសាលារៀនជំនាន់ថ្មី

៧ ដំណើរទស្សនកិច្ចសិក្សានៅសាលារៀនជំនាន់ថ្មីរបស់ ADB

៨ កិច្ចប្រជុំជាមួយអាណាព្យាបាលសិស្ស

៩ ការបណ្តុះបណ្តាលគ្រូថ្មីចូលបម្រើការងារក្នុងសាលារៀនជំនាន់ថ្មី

## ២. បច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារគមនាគមន៍សម្រាប់ការអប់រំ

១២ ការចុះប្រមូលទិន្នន័យក្នុងថាប់ប្លែតនៅតាមសាលារៀនគោលដៅ

១៣ ការផ្តល់ថាប់ប្លែតដល់សាលារៀនគោលដៅ

## ៣. ការអភិវឌ្ឍគ្រូបង្រៀន

១៥ ការប្រើប្រាស់កញ្ចប់ឯកសារបង្រៀនបន្ថែមក្នុងបរិបទជំងឺកូវីដ-១៩

១៥ ពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូលើសៀវភៅពន្លឿនការសិក្សា

១៦ តើអ្វីទៅជាការគ្រប់គ្រងថ្នាក់ និងវិន័យបែបវិជ្ជមាន?

១៧ កម្មវិធីសិក្សាលម្អិត និងការរៀនពីចម្ងាយ

១៧ បណ្តុះទម្លាប់ល្អដល់សិស្សដោយការបង្កើតក្លឹបអំណាន

១៨ តួនាទី និងការគ្រប់គ្រងបណ្ណាល័យក្នុងបរិបទកូវីដ-១៩

១៩ ការប្រឹក្សាគរុកោសល្យ គាំទ្រដល់ការអប់រំស្ទែម (STEM)

២០ ប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារ និងយុវជនប្រឈមនឹងហានិភ័យ

## ៤. កម្មវិធីអប់រំបរិយាប័ន្ន

២៣ ការផ្លាស់ប្តូររបៀបដឹកនាំរបស់នាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន

២៥ ការពិគ្រោះយោបល់ពីការវាយតម្លៃគ្រូកិច្ចសន្យាតាមតំបន់គោលដៅ

២៦ សិស្សក្រីក្រទទួលបានការគាំទ្រពីគម្រោងស៊ីក/SEEK

២៧ ដំណើរទស្សនកិច្ចម្ចាស់ជំនួយគម្រោងស៊ីក/SEEK

## ៥. កម្មវិធីអំណានថ្នាក់ដំបូង

២៩ ហេតុអ្វីសាលាគោលដៅរបស់គម្រោងត្រូវធ្វើតេស្តដំណាក់កាល?

## ៦. កម្មវិធីមត្តេយ្យសិក្សា

៣១ ការលេងល្បែងសិក្សា និងការផលិតសម្ភារៈបង្រៀន និងរៀន

## ៧. រចនាបថហេដ្ឋារចនាសម្ព័ន្ធ

៣៣ ការរៀបចំបន្ទប់បណ្ណាល័យបែបសតវត្សរ៍ទី២១

## ៨. ការអភិវឌ្ឍបណ្ណាល័យ

៣៥ បណ្ណាល័យស្តង់ដាសតវត្សរ៍ទី២១

## ៩. កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព

៣៧ តើយុវជនទទួលបានចំណេះអ្វីខ្លះពីវគ្គបណ្តុះបណ្តាលស្តីពី ផ្នត់គំនិតក្រិន ផ្នត់គំនិតអភិវឌ្ឍន៍ និងការនិយាយជាសាធារណៈ?

៣៨ តើខ្ញុំជានរណា?

៣៨ តើសិស្សស្ម័គ្រចិត្តទទួលបានចំណេះដឹងអ្វីខ្លះពីការតស៊ូមតិ?

៣៩ បំណិនជីវិតស្តីពី ការចិញ្ចឹមមាន់

៤១ កម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាន

## ១០. កម្មវិធីឆ្លើយតបនឹងវិស័យអប់រំក្នុងបរិបទកូវីដ១៩

៤៣ សកម្មភាពកម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំនៅកម្ពុជា

## ១១. ព្រឹត្តិការណ៍ ការស្រាវជ្រាវចំណេះដឹង និងការកំសាន្តផ្សេងៗ

៤៥ កម្មវិធីបើកដំណើគម្រោង សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម(CO-SAVED)

៤៦ មហោស្របជាតិលើកទី១ ស្តីពី ពិព័រណ៍ការអប់រំស្ទែម

៤៩ ការត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពគម្រោង

៥០ ត្រូវក្លាយជាខ្លួនឯង!

៥១ ប្រឡងបាក់ឌុប ២០២១!

៥២ គ្រូបង្រៀនរក្សាបានតួនាទីសំខាន់ក្នុងការអប់រំគ្រប់កាលៈទេសៈ

៥៣ មនុស្សរឹងមាំ!

៥៣ មតិអ្នកអាន



## ព្រឹត្តិបត្រ "ការអប់រំ និងបច្ចេកវិទ្យា"

## រៀបចំផលិត និងចេញផ្សាយដោយ

| | | |
|---|---|---|
| លោក អឿ សាថីន | មន្ត្រីទំនាក់ទំនងជាន់ខ្ពស់ | រៀបចំផែនការ បង្កើតទម្រង់ និងរចនា |
| លោក ឈួន តារា | មន្ត្រីបច្ចេកវិទ្យាព័ត៌មានជាន់ខ្ពស់ | ជំនួយការបច្ចេកទេស |
| លោក ខ៊ាន់ សុខសារៈ | មន្ត្រីតាមដាន & វាយតម្លៃ និងគ្រប់គ្រងទិន្នន័យជាន់ខ្ពស់ | ជំនួយការផ្នែកទិន្នន័យ |
| លោក ម៉ៃ សុខឃា | មន្ត្រីព័ត៌មានវិទ្យា | ជំនួយការបច្ចេកទេស |
| កញ្ញា ជួន ភាត់ថា | ជំនួយការផ្នែកទំនាក់ទំនង | ប្រមូល និងសរសេរព័ត៌មាន |

## ត្រួតពិនិត្យ និងកែសម្រួលខ្លឹមសារដោយ

លោក ស សុផាណាក់ ប្រធានសម្របសម្រួលផ្នែកបច្ចេកវិទ្យាសម្រាប់ការអប់រំ

# អំពីអង្គការ ខេប

ខេប គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធ នៅក្នុងប្រទេសកម្ពុជា។ ខេបបានប្រតិបត្តិការគម្រោងនៅគ្រប់កម្រិតជាមួយអ្នកទទួលផលនៅក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ កម្មវិធីអាហារូបករណ៍សម្រាប់សិស្សនៅសាកលវិទ្យាល័យ និងកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ។ ចំនួនកុមារទទួលផលផ្ទាល់មានជាង ១៥០០០០នាក់ និងគ្រូបង្រៀនជាច្រើនរយនាក់ដែលបង្រៀននៅជាង ៤០០សាលាក្នុង១៣រាជធានី-ខេត្ត។

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់ខេប គឺផ្តល់លទ្ធភាពដល់កុមារ និងយុវជននូវជម្រើសដ៏ល្អបំផុតនៅក្នុងជីវិតផ្អែកលើសក្តានុពលរបស់ពួកគេតាមរយៈទទួលបានការអប់រំល្អ។

## បេសកកម្ម

បេសកកម្មរបស់អង្គការ ខេប គឺធ្វើការជាមួយរដ្ឋាភិបាល សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដើម្បីផ្តល់អំណាចដល់កុមារ និងយុវជនងាយរងគ្រោះក្នុងការសម្រេចបាននូវសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាពតាមរយៈវិធីច្នៃប្រឌិតថ្មី។

## គុណតម្លៃ

- ការផ្តល់សិទ្ធិអំណាច
- ការសាមគ្គី
- សេចក្តីមេត្តា
- ការគោរព
- កិច្ចសហប្រតិបត្តិការ
- ការកែប្រែថ្មី ឬច្នៃប្រឌិតថ្មី
- តម្លាភាព
- ជឿជាក់

ការអភិវឌ្ឍមនុស្ស ប្រកបដោយសេចក្តីថ្លៃថ្នូរ!

# មុខងារគម្រោងរបស់អង្គការ ខេប តាមផ្នែកបច្ចេកទេសក្នុងឆ្នាំ២០២១

គម្រោងអង្គការ ខេប ឆ្នាំ ២០២១

| | ពាក្យបំព្រួញ | ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ | ICT សម្រាប់ការអប់រំ | ការអភិវឌ្ឍគ្រូបង្រៀន | កម្មវិធីអប់រំបរិយាប័ន្ន | កម្មវិធីអំណានថ្នាក់ដំបូង | កម្មវិធីមត្តេយ្យសិក្សា | វចនាបថហេដ្ឋារចនាសម្ព័ន្ធ | ការអភិវឌ្ឍបណ្ណាល័យ | កម្មវិធីបំណិនជីវិត និងប្រឹក្សាអាជីព | កម្មវិធីឆ្លើយតបនឹងវិស័យអប់រំក្នុងបរិបទកូវីដ១៩ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១. គម្រោង សៀវភៅសម្រាប់កម្ពុជា | BfC | | | | | | | | ✓ | | |
| ២. កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំក្នុងបរិបទជំងឺកូវីដ-១៩ | CERRP | | ✓ | ✓ | ✓ | ✓ | | | | | ✓ |
| ៣. គម្រោងអប់រំកុមារី | GEI | | | | ✓ | | | | | ✓ | ✓ |
| ៤. គម្រោង វាយតម្លៃ-GPE3 (តេស្ត EGRA) | GPE3-PE | | | | | ✓ | | | | | |
| ៥. គម្រោង កុមារកម្ពុជារីករាយ | HCC | | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ |
| ៦. គម្រោង សកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា | KYLA | | | | ✓ | | | | | ✓ | |
| ៧. គម្រោង អប់រំបំណិនជីវិតសម្រាប់កុមារី | LSLAG | | | | ✓ | | | | | ✓ | |
| ៨. មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី | NGPRC | ✓ | ✓ | ✓ | | | | | | | ✓ |
| ៩. គម្រោង សាលារៀនជំនាន់ថ្មី (កម្រិតបឋម) | NGS-P | ✓ | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ | ✓ |
| ១០. គម្រោង សាលារៀនជំនាន់ថ្មី (កម្រិតមធ្យម) | NGS-S | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| ១១. គម្រោង សាលារៀនជំនាន់ថ្មី/ស្វាយរៀង | NGS-SR | ✓ | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| ១២. គម្រោង ពន្លកចំណេះ (ស្រាវជ្រាវប្រឹក្សាគរុកោសល្យ) | PC | | | ✓ | | | | | | | |
| ១៣. គម្រោង បង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ | REACH IV | | | ✓ | ✓ | ✓ | ✓ | | ✓ | ✓ | ✓ |
| ១៤. គម្រោង លើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា | SEEK | | | ✓ | ✓ | | | | | ✓ | ✓ |
| ១៥. គម្រោង វិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ | TRAC III | | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | | ✓ |
| ១៦. គម្រោង អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ២ | USE-SDP2 | | ✓ | ✓ | | | | ✓ | ✓ | ✓ | |
| ១៧. គម្រោង សហគ្រិនវ័យក្មេង | YEP | | | | ✓ | | | | | ✓ | ✓ |
| ១៨. គម្រោង សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម | Co-SAVED | | ✓ | ✓ | ✓ | | ✓ | ✓ | ✓ | ✓ | |
| ១៩. គម្រោង ងាយស្រួលរៀន (ខេត្តព្រៃវែង) | E2L | | ✓ | ✓ | ✓ | | | ✓ | ✓ | ✓ | ✓ |
| សរុបគម្រោងកំពុងដំណើរការក្នុងផ្នែកនីមួយៗ | | ៤ | ៧ | ១១ | ១២ | ៦ | ៣ | ៦ | ៨ | ១១ | ១២ |

## ចំនួនអ្នកទទួលផលផ្ទាល់





| សិស្សានុសិស្ស | គ្រូបង្រៀន/នាយក | ភាគីពាក់ព័ន្ធ |
|---|---|---|
| ១២០៨៣១ | ២៨០៦ | ១៩៩៦ |

## ចំនួនសាលាគោលដៅ




១១០ មធ្យមសិក្សា

១៧២ បឋមសិក្សា




មត្តេយ្យសិក្សា ៤២

ឧត្តមសិក្សា ១

## ម្ចាស់ជំនួយអង្គការ ខេប ក្នុងឆ្នាំ២០២១

unicef for every child

GPE Transforming Education

GVC WeWorld

This project is co-funded by the European Union

EDUCATE A CHILD — A programme of education above all

Aide et Action — Changing the world through Education

THE PHOENIX FOUNDATION

ChildFund Cambodia

ADB

The Asia Foundation — Improving Lives, Expanding Opportunities

OXFAM

lotus outreach INTERNATIONAL

lotus outreach SOCIETY CANADA

USAID FROM THE AMERICAN PEOPLE

pact building local promise.

Oaktree

UNESCO

FFF | Franks Family Foundation

Gap Inc.

P.A.C.E. Gap Inc. Advancing Women to Advance the World

## តំបន់គោលដៅ អនុវត្តគម្រោង ក្នុងឆ្នាំ២០២១ របស់អង្គការ ខេប មានចំនួន ១៤ រាជធានី-ខេត្ត



# អនុវិស័យទី ១

# ការអភិវឌ្ឍសាលារៀនធម្មនុញ្ញ

“បង្កើតសាលារៀនរដ្ឋជាមួយនឹងស្តង់ដាសាលារៀនឯកជន”

## Charter School Development

*"Creating Public Schools with Private School Standards"*



# សុខុមាលភាព និងសុវត្ថិភាពលើឥទ្ធិពលប្រព័ន្ធបច្ចេកវិទ្យាឌីជីថល



លោក **សៅ ចន្ថា** នាយកវិទ្យាល័យសម្តេចអគ្គមហាពោធិសាល ជាស៊ីម ព្រែកអញ្ចាញ

នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ សាលារៀនជំនាន់ថ្មី វិទ្យាល័យសម្តេចអគ្គមហាពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ បានរៀបចំសិក្ខាសាលាស្តីពី **“សុខុមាលភាព និងសុវត្ថិភាពលើឥទ្ធិពលប្រព័ន្ធបច្ចេកវិទ្យាឌីជីថល”** តាមរយៈប្រព័ន្ធអនឡាញដែលមានអ្នកចូលរួមសរុបចំនួន ៤៤នាក់ រួមមានៈ នាយក/នាយករង លោកគ្រូអ្នកគ្រូ សិស្ស និងអ្នកពាក់ព័ន្ធផ្សេងៗ។

សិក្ខាសាលានេះមានគោលបំណងបំផុសឱ្យសិស្សានុសិស្សយកចិត្តទុកដាក់លើការប្រើប្រាស់បច្ចេកវិទ្យាឱ្យត្រូវទៅនឹងគោលដៅសិក្សារៀនសូត្រ និងធ្វើឱ្យប្អូនៗយល់ដឹងពីគន្លឹះសំខាន់ៗអំពីបច្ចេកវិទ្យាឌីជីថលដើម្បីប្រើប្រាស់ឱ្យបានត្រឹមត្រូវ។

លោក **សៅ ចន្ថា** នាយកវិទ្យាល័យសម្តេចអគ្គមហាពោធិសាល ជា ស៊ីម ព្រែកអញ្ចាញបានមានប្រសាសន៍ថា ***“នៅក្នុងសតវត្សរ៍ទី២១នេះ ប្រព័ន្ធឌីជីថលមានសារៈសំខាន់ក្នុងការអភិវឌ្ឍទាំងសង្គមកិច្ច និងសេដ្ឋកិច្ច ហើយវាក៏មានគុណសម្បត្តិ និងគុណវិបត្តិផងដែរ។ ដូច្នេះ បើប្អូនៗប្រើវាត្រូវផ្លូវនោះ វានឹងនាំប្អូនៗដើរទៅរកផ្លូវល្អ និងរីកចម្រើន តែបើប្រើមិនត្រូវផ្លូវទេ នោះវានឹងនាំបញ្ហាដល់ប្អូនវិញជាមិនខាន។ ចូរប្អូនប្រើប្រាស់ប្រព័ន្ធឌីជីថលឱ្យមានប្រយោជន៍ដើម្បីទទួលបានចំណេះដឹង ព័ត៌មាន និងមានទំនាក់ទំនងល្អជាមួយមនុស្សជុំវិញខ្លួន”***។

លោក **ញ៉ែម ឆដាវែន** ជាជំនួយការប្រធានផ្នែកព័ត៌មានវិទ្យានៅ ACE/IDP បានមានប្រសាសន៍ថា ***“បច្ចុប្បន្ននេះ បច្ចេកវិទ្យាឌីជីថលពិតជាដើរតួយ៉ាងសំខាន់ក្នុងជីវិតប្រចាំថ្ងៃ។ ដើម្បីរក្សាសុវត្ថិភាពនៅលើបណ្តាញសង្គម ប្អូនៗមិនត្រូវប្រាប់ ឬចែករំលែកលេខកូដសម្ងាត់ទៅអ្នកដទៃ និងចុចលើតំណភ្ជាប់ដែលខ្លួនមិនដឹងប្រភពច្បាស់លាស់នោះឡើយ”***។

សិស្សបានយល់ដឹងអំពីគុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃសម្រាប់ការប្រាស្រ័យទាក់ទងគ្នា ការសិក្សារៀនសូត្រ ការស្រាវជ្រាវរកព័ត៌មានពិត និងចំណេះដឹងថ្មីៗសំខាន់ៗជាច្រើននៅលើបណ្តាញសង្គមនៅគ្រប់ទីកន្លែងដោយគ្រាន់តែភ្ជាប់ជាមួយប្រព័ន្ធអ៊ីនធើណិតទៅនឹងទូរសព្ទដៃ/កុំព្យូទ័រ ថាប់ប្លេត និងឧបករណ៍ផ្សេងៗទៀត។




លោក **ញ៉ែម ឆដាវែន** ជាជំនួយការប្រធានផ្នែកព័ត៌មានវិទ្យានៅ ACE/IDP ធ្វើបទបង្ហាញពីសុខុមាភាព និងសុវត្ថិភាពលើប្រព័ន្ធបច្ចេកវិទ្យា

# ការផ្ទេរការគាំទ្រសាលារៀនជំនាន់ថ្មីខេត្តស្វាយរៀង ជូនដល់ក្រសួងអប់រំ យុវជន និងកីឡា ដឹកនាំបន្ត




*កិច្ចសម្ភាសន៍ជាមួយក្រុមប្រឹក្សាភិបាល នាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូ*

នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ អង្គការ ខេប បានរៀបចំសិក្ខាសាលាស្តីពី ***"ការផ្ទេរការគាំទ្របន្តសាលារៀនជំនាន់ថ្មីវិទ្យាល័យគោកព្រីង និងបឋមសិក្សាស្វាយព្រហូត ខេត្តស្វាយរៀង ជូនក្រសួងអប់រំ យុវជន និងកីឡា"*** ដែលបានរៀបចំឡើងតាមប្រព័ន្ធអនឡាញ ដោយមានអ្នកចូលរួមសរុបចំនួន៨៤នាក់ រួមមាន៖ រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា នាយកប្រតិបត្តិអង្គការឆាលហ្វានកម្ពុជា ក្រុមប្រឹក្សាភិបាលសាលារៀនជំនាន់ថ្មីថ្នាក់ជាតិ គណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ និងបុគ្គលិកអង្គការ ខេប។

អង្គការឆាលហ្វានកម្ពុជាបានផ្តល់ជំនួយហិរញ្ញប្បទានដល់អង្គការ ខេប ដើម្បីគាំទ្រសកម្មភាពកម្មវិធីសាលារៀនជំនាន់ថ្មី វិទ្យាល័យគោកព្រីង និងសាលាបឋមសិក្សាស្វាយព្រហូត ចាប់ផ្តើមពីឆ្នាំ២០១៦ មកដល់ខែសីហា ឆ្នាំ២០២១ និងបានចំណាយថវិកាសរុបជាង១លានដុល្លាអាមេរិកក្នុងការចូលរួមអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

សិក្ខាសាលានេះមានគោលបំណងធ្វើការពិភាក្សារៀបចំផែនការដើម្បីផ្ទេរការគាំទ្របន្តសាលារៀនជំនាន់ថ្មី វិទ្យាល័យគោកព្រីង និងបឋមសិក្សាស្វាយព្រហូត ខេត្តស្វាយរៀង ជូនទៅក្រសួងអប់រំ យុវជន និងកីឡា។

សមិទ្ធផលសំខាន់ៗដែលគម្រោងសម្រេចបាន រួមមាន៖

**១-ផ្នែកកសាងសមត្ថភាពនិងលើកកម្ពស់គុណភាពសិក្សា គឺ៖**

-បានបង្កើតក្លឹបសិក្សាតាមប្រធានមួយៗដែលគ្រប់គ្រង និងដឹកនាំដោយលោកគ្រូអ្នកគ្រូ រួមមាន៖ ក្លឹបវិទ្យាសាស្ត្រ ភាសាអង់គ្លេស ប្រវត្តិសាស្ត្រ និងមានក្លឹបសិក្សាដទៃៗទៀត។

-គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់សិស្សទាក់ទងទៅនឹងបំណិនជីវិត ដូចជា ផ្នែកកសិកម្ម បញ្ហាសង្គម ជំនាញសេដ្ឋកិច្ច និងការងារ ព្រមទាំងឱ្យសិស្សចេះប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ការសិក្សា។

-ផ្តល់វគ្គបំប៉ន និងសិក្ខាសាលាដល់គណៈគ្រប់គ្រងសាលារៀន បណ្ណារក្ស និងលោកគ្រូអ្នកគ្រូដែលបានពង្រឹងសមត្ថភាពវិជ្ជាជីវៈជាគ្រូបង្រៀនក៏ដូចជាពង្រីកចំណេះដឹងបន្ថែមក្នុងការបង្រៀន និងរៀន។

-ជំរុញលើកទឹកចិត្តលោកគ្រូអ្នកគ្រូឱ្យបន្តការរៀន និងការបង្រៀនតាមរយៈការប្រើប្រាស់កម្មវិធីអប់រំ(Google Form, Kahout, Quizz)។

-ផ្តល់ថវិកាឧបត្ថម្ភប្រចាំខែ និងផ្តល់អាហារូបករណ៍ជូនគ្រូបង្រៀនបន្តយកបរិញ្ញាបត្ររួមទាំងផ្តល់កញ្ចប់ថវិកាដល់សាលា។

-ដឹកនាំសកម្មភាពវាយតម្លៃគុណភាពសាលារៀនដោយក្រុមប្រឹក្សាថ្នាក់ជាតិ។

-តភ្ជាប់អ៊ីនធើណិតសម្រាប់ការងារទំនាក់ទំនង ការស្រាវជ្រាវការបង្រៀន និងការរៀន។

**២-ផ្នែកកសាងហេដ្ឋារចនាសម្ព័ន្ធសាលារៀន៖**

គម្រោងបានបំពាក់សម្ភារៈសិក្សាតាមស្តង់ដាសាលារៀនជំនាន់ថ្មី កែលម្អអគារសិក្សា និងបន្ទប់រៀន សាងសង់បណ្ណាល័យសតវត្សរ៍ទី២១ រៀបចំ (**អានបន្តទំព័រ** 6...)

(...តទំព័រទី5) បន្ទប់ពិសោធន៍ និងកុំព្យូទ័រ សាងសង់មណ្ឌលយុវជន អាហារដ្ឋាន និងកន្លែងលាងដៃ កែលម្អសួនជីវៈ និងសួនកុមារ ព្រមទាំងក្រាលសាបឥដ្ឋការ៉ូឡ។

**៣-ផ្នែកសម្ភារៈបរិក្ខាបំពាក់ក្នុងសាលារៀន៖**

-គាំទ្រសម្ភារៈបម្រើការងាររៀន និងបង្រៀនទាំងក្នុងថ្នាក់រៀន និងបណ្ណាល័យ។

-បំពាក់គ្រឿងសង្ហារិម ដូចជា ម៉ាស៊ីនត្រជាក់ និងកង្ហារទាំងក្នុងទីចាត់ការ បណ្ណាល័យ និងអគារសិក្សាប្រកបដោយផាសុកភាព។

-ផ្តល់កុំព្យូទ័រ ទូរទស្សន៍វៃឆ្លាត ថាប់ប្លេតដល់សាលាសម្រាប់សិស្ស និងគ្រូក្នុងការស្រាវជ្រាវ និងទិញសៀវភៅសម្រាប់ដាក់បណ្ណាល័យ។

លោក **ប្រាសាន់ វីម៉ា** នាយកប្រចាំប្រទេសរបស់អង្គការឆាលហ្វានកម្ពុជា បានមានប្រសាសន៍ថា *“ក្នុងនាមជាអង្គការអន្តរជាតិ មិនអាចជួយគាំទ្រនៅតែតំបន់មួយក្នុងរយៈពេលយូរឡើយ នោះសាលារៀនមិនមានឯករាជ្យភាពក្នុងការដឹកនាំ។ សមិទ្ធផលសំខាន់ៗសម្រេចបានដោយសារការខិតខំប្រឹងប្រែងរបស់គណៈគ្រប់គ្រងសាលាទាំងពីរ និងការជួយគាំបច្ចេកទេសរបស់គម្រោងបានធ្វើឱ្យសាលារៀនទទួលបានវិញ្ញាបនបត្រពីក្រុមប្រឹក្សាភិបាលថ្នាក់ជាតិស្របទៅតាមគោលនយោបាយក្រសួងអប់រំយុវជននិងកីឡា។ ទោះបីជាពេលនេះ សាលារៀនមិនទទួលបានការគាំទ្រពីខាងយើងទៀតក៏ដោយ សូមឱ្យសាលារៀនបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍសាលាប្រកបដោយនិរន្តភាព”*។



លោក ប្រាសាន់ វីម៉ា

លោក **ហ៊ិន ស៊ីមហួន** នាយករងប្រតិបត្តិអង្គការ ខេប បានមានប្រសាសន៍ថា *“សាលារៀនជំនាន់ថ្មី វិទ្យាល័យគោកព្រីង និងសាលាបឋមសិក្សាស្វាយព្រហូត ត្រូវបានបង្កើនឡើងនូវគុណភាពអប់រំ និងប្រសិទ្ធភាពជារៀងរាល់ឆ្នាំ ដើម្បីត្រៀមវាយតម្លៃពីអនុគណៈកម្មការវាយតម្លៃថ្នាក់ជាតិដើម្បីទទួលស្គាល់ពីគុណភាពអប់រំ។ នៅឆ្នាំ២០២០ សាលារៀនទាំងពីរទទួលបានវិញ្ញាបនបត្រទទួលស្គាល់ពីគុណភាពអប់រំ ស្របពេលដែលគម្រោងត្រូវបានបញ្ចប់ ហើយសាលារៀននៅមិនទាន់មានស្ថេរភាពក្នុងការឈរជើងឱ្យរឹងមាំនៅឡើយ។ ដូច្នេះ អង្គការ ខេប បានស្វែងរកការសហការ និងការគាំទ្រពីក្រសួងអប់រំ យុវជន និងកីឡាដើម្បីបន្តនិរន្តរភាពដល់សាលារៀន”*។



*លោក ហ៊ិន ស៊ីមហួន*

ឯកឧត្តម អ៊ឹម កុច រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា *“កម្មវិធីសាលារៀនជំនាន់ថ្មីទាំងពីរដែលបានដំណើរការក្រោមការឧបត្ថម្ភរបស់អង្គការឆាលហ្វានកម្ពុជានាពេលនេះ អាចនឹងត្រឡប់ទៅស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយក្រុមប្រឹក្សាភិបាលសាលារៀនជំនាន់ថ្មីថ្នាក់ជាតិ ហើយសាលារៀននឹងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធសាលារៀនជំនាន់ថ្មីដែលក្រសួងអប់រំ យុវជន និងកីឡាកំពុងបង្កើតដោយមានជំនួយបច្ចេកទេសពីអង្គការដៃគូដែលមានបទពិសោធន៍ដ៏ល្អរបស់យើង គឺអង្គការ ខេប ដែលរៀបចំផែនការពង្រីកប្រព័ន្ធសាលារៀនជំនាន់ថ្មីចំនួន១៥សាលាបន្ថែមទៀត ហើយខ្ញុំប្រាកដណាស់ថា សាលារៀនទាំងពីរ ក៏នឹងទទួលបានអត្ថប្រយោជន៍ពីកិច្ចខិតខំប្រឹងប្រែងទាំងនេះផងដែរ”*។



*ឯកឧត្តម អ៊ឹម កុច*

លោក **សោម សំ** ជានាយកសាលារៀនបឋមសិក្សាស្វាយព្រហូតបានមានប្រសាសន៍ថា *"សាលារៀនមានការរីកចម្រើនគួរឱ្យកត់សម្គាល់បន្ទាប់ពីទទួលបានការជួយគាំទ្រពីគម្រោងក្នុងការពង្រឹងសមត្ថភាពបង្រៀន និងរៀន ក៏ដូចជាពង្រឹងជំនាញទន់គណៈគ្រប់គ្រងសាលារៀនក្នុងការដឹកនាំតាមរយៈការផ្តល់វគ្គសិក្ខាសាលា បណ្តុះបណ្តាល និងបំប៉នលើវិធីសាស្ត្របង្រៀនថ្មីៗដើម្បីធ្វើឱ្យសិស្សចូលរួមជាមួយសកម្មភាពបង្រៀន និងរៀនប្រកបដោយបរិយាកាសសប្បាយរីករាយទាំងក្នុង និងក្រៅថ្នាក់ ជាពិសេសគម្រោងបានជួយអភិវឌ្ឍន៍សកម្មភាពសាលារៀនជាច្រើនបន្ថែមទៀត"*។



*លោក សោម សំ*

កម្មវិធីសាលារៀនជំនាន់ថ្មីខេត្តស្វាយរៀង គឺជាការបង្កើតសាលារៀនស្វយ័តសាធារណៈ ដើម្បីទទួលបានការអប់រំជាស្តង់ដាកម្រិតខ្ពស់ដែលមានអភិបាលកិច្ចល្អ គណនេយ្យភាព តម្លាភាព និងមានកម្រិតវិជ្ជាជីវៈខ្ពស់ដែលជាធាតុសំខាន់របស់កម្មវិធី ជាពិសេសវាជាសាលារៀនគំរូមួយនៅក្នុងជនបទដោយមានការទទួលស្គាល់ពីក្រុមប្រឹក្សាភិបាលថ្នាក់ជាតិ ជាសាលារៀនជំនាន់ថ្មីស្របតាមក្របខ័ណ្ឌគោលនយោបាយដែលបានកំណត់នៅក្នុងកម្មវិធី។

សិក្ខាសាលាបានដំណើរការទៅដោយរលូន ក្នុងការពិភាក្សាស្វែងរកដោះស្រាយប្រកបដោយផ្លែផ្កាដើម្បីស្វែងរកថវិកាក្នុងការគាំទ្រសកម្មភាពនានារបស់សាលារៀន។ ជាលទ្ធផលសរុប សាលារៀនជំនាន់ថ្មីទាំងពីរត្រូវរៀបចំផែនការក្នុងការអភិវឌ្ឍ និងធ្វើរបាយការណ៍ដាក់ជូនទៅក្រសួងអប់រំ យុវជន និងកីឡាដើម្បីស្វែងរកការគាំទ្របន្តទៀតដល់សាលា។

# ដំណើរទស្សនកិច្ចគណៈប្រតិភូសហគមន៍អឺរ៉ុប និងទីភ្នាក់ងារ អភិវឌ្ឍន៍បារាំងនៅសាលារៀនជំនាន់ថ្មី

កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១ គណៈប្រតិភូសហគមន៍អឺរ៉ុប និងទីភ្នាក់ងារ អភិវឌ្ឍន៍បារាំងបានអញ្ជើញមកទស្សនកិច្ច នៅសាលារៀនជំនាន់ថ្មី វិទ្យាល័យព្រែកលៀប ដើម្បីសិក្សាស្វែងយល់អំពីការអនុវត្តកម្មវិធី សាលារៀនជំនាន់ថ្មីដែលបានសម្របសម្រួល ដោយឯកឧត្តម សាន វឌ្ឍនា។



*ដំណើរទស្សនកិច្ចគណៈប្រតិភូសហគមន៍អឺរ៉ុប និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំងនៅសាលារៀន ជំនាន់ថ្មី ដែលសម្របសម្រួលដោយ ឯកឧត្តម សាន វឌ្ឍនា។*

កម្មវិធីសាលារៀនជំនាន់ថ្មីគឺជាកម្មវិធី កំណែទម្រង់អប់រំថ្មីមួយដែលមានការគាំទ្រ ហិរញ្ញប្បទានពីក្រសួងអប់រំ យុវជន និង កីឡា តាំងពីឆ្នាំ២០១៥ ដើម្បីបង្កើតសាលា រៀនសាធារណៈស្វយ័តមួយប្រកបដោយភាព ច្នៃប្រឌិត និងកែលម្អគុណភាពអប់រំ ហើយ ផ្តោតសំខាន់លើស្តង់ដាវិជ្ជាជីវៈខ្ពស់ ព្រមទាំង មានអភិបាលកិច្ចល្អ។ គន្លងអភិវឌ្ឍន៍ថ្មីនេះ ព្យាយាមជំរុញគ្រឹះស្ថានអប់រំសាធារណៈឱ្យ ឈានដល់កម្រិតខ្ពស់មួយទៀតដើម្បីសម្រេច បានស្តង់ដាអប់រំអតិបរិមា ជាពិសេសចំពោះ មុខវិជ្ជាស្ទែម (STEM) តែម្តង៕

# ដំណើរទស្សនកិច្ចសិក្សារបស់ធនាគារ ADB នៅសាលារៀនជំនាន់ថ្មី

កាលពីថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១អ្នក តំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បាន អញ្ជើញមកធ្វើទស្សនកិច្ចសិក្សានៅសាលា រៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាម ដើម្បីស្វែងយល់អំពីកម្មវិធីសាលារៀនជំនាន់ថ្មី ពាក់ព័ន្ធនឹងដំណើរការរីកចម្រើន បញ្ហា ប្រឈម និងជាតុចូលរបស់សាលារៀន ជា ពិសេសលើមុខវិជ្ជាស្ទែម។



អ្នកតំណាងធនាគារអភិវឌ្ឍន៍អាស៊ីជួបជាមួយសិស្សសាលារៀនជំនាន់ថ្មីនៅក្រុងកំពង់ចាម។

អ្នកតំណាងធនាគារអភិវឌ្ឍន៍អាស៊ីបាន ជួបសំណេះសំណាលជាមួយនាយកសាលា ពិភាក្សាអំពីប្រវត្តិសាលារៀនជំនាន់ថ្មី បញ្ហា ប្រឈមដែលបានជួបប្រទះ ដំណោះស្រាយ និងគោលការណ៍ប្រតិបត្តិកម្មវិធី។ ក្រៅពីជួប សំណេះសំណាលជាមួយលោកនាយកសាលា រួចមក ពួកគាត់បានទៅអង្កេតមើលបន្ទប់កុំព្យូ ទ័រ ក្លឹបសិក្សាវិទ្យាសាស្ត្រ (Robotic) និង បន្ទប់គីមីវិទ្យា ព្រមទាំងបានបន្តចូលទស្សនា នៅក្នុងបណ្ណាល័យសតវត្សទី២១ និងបាន ចាប់អារម្មណ៍ពីសោភ័ណភាពក្នុងបណ្ណាល័យ ដោយពិនិត្យលើ Tablets ដែលមានកម្មវិធី សិក្សាមួយចំនួនដែលត្រូវបានតម្លើងសម្រាប់ សិស្ស និងបានសួរសិស្សពីការប្រើប្រាស់កុំព្យូ ទ័រម៉ាក់(Mac) សម្រាប់រៀន។

តំណាងធនាគារអភិវឌ្ឍន៍អាស៊ីក៏បាន បន្តជួបនិងសំណេះសំណាលជាមួយសិស្ស អំពីការសិក្សាតាមបែបបច្ចេកវិទ្យា ការបង្រៀន និងរៀនរបស់លោកគ្រូអ្នកគ្រូ។ សិស្សសាលា រៀនជំនាន់ថ្មីបានឆ្លើយតបភ្លាមៗយ៉ាងរីករាយ ចំពោះការសិក្សានៅនៅសាលារៀនជំនាន់ថ្មី ពីព្រោះពួកគាត់បានយល់ដឹងច្រើនអំពីមុខវិជ្ជា ស្ទែម ក្លឹប Robotic និងទទួលបានការប្រឹក្សា យោបល់ពីគ្រូប្រឹក្សាអាជីពបន្ថែមទៀតផង៕

# កិច្ចប្រជុំជាមួយឪពុកម្តាយ និងអាណាព្យាបាលសិស្ស

កាលពីថ្ងៃទី០៣-០៤ ខែធ្នូ ឆ្នាំ២០២១ សាលារៀនជំនាន់ថ្មី វិទ្យាល័យ ព្រែកលៀប បានរៀបចំកិច្ចប្រជុំជាមួយឪពុកម្តាយ និងអាណាព្យាបាលសិស្សចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ នៅក្នុងបរិវេណសាលារៀន ដោយមានការអញ្ជើញចូលរួមពីសំណាក់ឪពុកម្តាយ និងអាណាព្យាបាលសិស្សសរុបចំនួន២០៩ នាក់ និងសិស្សសរុបចំនួន២៧១នាក់ ដើម្បីទទួលបានការណែនាំអំពីគោលការណ៍កម្មវិធីសាលារៀនជំនាន់ថ្មីដល់ឪពុកម្តាយ និងអាណាព្យាបាលសិស្សថ្មី ព្រមទាំងពាក្យចុះឈ្មោះសិស្សថ្មីចូលរៀនក្នុងឆ្នាំសិក្សាថ្មី ២០២១-២០២២។

សាលារៀនជំនាន់ថ្មី វិទ្យាល័យ ព្រែកលៀបទទួលបានជំនួយហិរញ្ញប្បទានពីក្រសួងអប់រំ យុវជន និងកីឡា និងប្រតិបត្តិដោយអង្គការ ខេប ដើម្បីបង្កើតគំរូអភិវឌ្ឍន៍ថ្មីនៅក្នុងប្រព័ន្ធអប់រំសាធារណៈដែលនឹងនាំទៅដល់ការបង្កើតសាលារៀនសាធារណៈស្វយ័ត ដែលទទួលបានការវិនិយោគខ្ពស់ផ្សារភ្ជាប់ទៅនឹងស្តង់ដាថ្មីដែលមានគណនេយ្យភាព និងអភិបាលកិច្ចល្អ ព្រមទាំងមានស្តង់ដាវិជ្ជាជីវៈសម្រាប់ការសិក្សានៅក្នុងសតវត្សរ៍ទី២១។



*សកម្មភាពសិស្សទទួលយកពាក្យចូលរៀនសម្រាប់ឆ្នាំសិក្សាថ្មី។*

ដោយទទួលបានវិញ្ញាបនបត្រទទួលស្គាល់ជាសាលារៀនជំនាន់ថ្មីពីក្រុមប្រឹក្សាថ្នាក់ជាតិក្នុងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ សាលារៀនជំនាន់ថ្មី វិទ្យាល័យ ព្រែកលៀប អាចស្នើសុំថវិកាបដិភាគពីមាតាបិតាសិស្សដើម្បីចូលរួមអភិវឌ្ឍន៍ និងគាំទ្រសកម្មភាពសាលារៀន។

ជាចុងបញ្ចប់នៃកម្មវិធីប្រជុំនេះ ឪពុកម្តាយ និងអាណាព្យាបាលសិស្សបានគាំទ្រគោលការណ៍សាលារៀនជំនាន់ថ្មី និងបានយល់ស្របតាមសំណើរសុំ ដោយអនុញ្ញាតឱ្យវិទ្យាល័យ ព្រែកលៀប ប្រមូលថវិកាវិភាគទានពីមាតាបិតាសិស្សក្នុង១នាក់ ចំនួន២៦០ ដុល្លារអាមេរិក ប៉ុន្តែមានការលើកលែងចំពោះសិស្សក្រីក្រ នៅក្នុងឆ្នាំសិក្សា ២០២១-២០២២នេះ ដើម្បីចូលរួមចំណែកគាំទ្រសកម្មភាពបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់ក្នុងការឆ្លើយតបនឹងការអប់រំក្នុងសតវត្សរ៍ទី២១៕



*ឪពកុម្តាយ និងអាណាព្យាបាលសិស្សចូលរួមប្រជុំនៅវិទ្យាល័យ ព្រែកលៀប ដើម្បីស្វែងយល់ឱ្យច្បាស់អំពីកម្មវិធីសាលារៀនជំនាន់ថ្មី។*

# ការបណ្តុះបណ្តាលគ្រូថ្មីចូលបម្រើការងារក្នុងសាលារៀនជំនាន់ថ្មី



*គ្រូបង្រៀនថ្មីថតរូបរួមគ្នាក្រោយពេលបញ្ចប់ការបណ្តុះបណ្តាលសមត្ថភាពនៅសាលប្រជុំសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាម។*

កម្មវិធីសាលារៀនជំនាន់ថ្មីបានរៀបចំសិក្ខាសាលាស្តីពី **ការបំប៉នសមត្ថភាពគ្រូបង្រៀនថ្មី** ពីថ្ងៃទី១៣ ដល់ទី២៥ ខែធ្នូ ឆ្នាំ ២០២១ មានរយៈពេល១២ថ្ងៃកន្លះនៅសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាម។ កម្មវិធីនេះទទួលបានហិរញ្ញប្បទានពីក្រសួង អប់រំ យុវជន និងកីឡា។ អ្នកចូលរួមសរុបមានចំនួន៨០នាក់ ជាគ្រូបង្រៀនតាមមុខវិជ្ជានីមួយៗមកពីសាលារៀនជំនាន់ថ្មីចំនួន៩សាលា រួមមាន៖ វិទ្យាល័យ ហ៊ុន សែន ពាមជីកង វិទ្យាល័យ សម្តេចអគ្គមហាធម្មពោធិសាល ជាស៊ីម ព្រែកអញ្ចាញ វិទ្យាល័យ ព្រែកលៀប វិទ្យាល័យ គោក ព្រីង វិទ្យាល័យ ហ៊ុន សែន កំពង់ចាម សាលាបឋមសិក្សា ហ៊ុន សែន អនុវត្តន៍ សាលាបឋមសិក្សា ព្រះរាជអគ្គមហេសី សាលាបឋមសិក្សាអង្គរបាន និងសាលាបឋមសិក្សាស្វាយព្រហូត។

សិក្ខាសាលានេះរៀបចំឡើងមានគោលបំណង៖ ១) ឱ្យលោកគ្រូអ្នកគ្រូយល់ដឹងពីគោលនយោបាយ និងគោលការណ៍ប្រតិបត្តិក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី។ ២) ផ្តល់វិធីសាស្រ្ត និងបច្ចេកទេសល្អៗក្នុងការបង្រៀន និងរៀន។ ៣) យល់ដឹងពីការបង្កើតតេស្ត និងសំណួរឱ្យបានស្របតាមសមត្ថភាពសិស្ស និងយល់បានកាន់តែច្បាស់ពីរបៀបរៀបចំផែនការគន្លងអាជីពជាគ្រូបង្រៀន។

លោកគ្រូអ្នកគ្រូទទួលបានចំណេះដឹងជាច្រើនទាក់ទងទៅនឹងកម្មវិធីសាលារៀនជំនាន់ថ្មីដូចខាងក្រោម៖ ១) ស្គាល់ និងយល់ដឹងពីគោលនយោបាយ និងគោលការណ៍នៅសាលារៀនជំនាន់ថ្មី។ ២) ក្របខណ្ឌអភិវឌ្ឍន៍គ្រូបង្រៀន គឺកម្លាំងចលករជួរមុខ មិនអាចខ្វះបានក្នុងការផលិតមូលធនមនុស្សដែលជាកម្លាំងពលកម្មសកម្ម និងមានផលិតភាពខ្ពស់សម្រាប់ធានាកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។ ធាតុសំខាន់ៗក្នុងក្របខណ្ឌអភិវឌ្ឍន៍គ្រូដូចជា ផែនការគន្លងអាជីពគ្រូបង្រៀន ការធ្វើផែនការ និងការអនុវត្ត ការផ្តល់ប្រឹក្សាទល់មុខ ការសង្កេតការបង្រៀន ដំណើរទស្សនិច្ចសិក្សាក្រៅសាលា និងផ្តល់ការប្រឹក្សាដល់គ្រូបង្រៀនបែបឌីជីថល។ ៣) ការអប់រំនៅសតវត្សរ៍ទី២១ គឺផ្តោតលើការស្រាវជ្រាវ ថ្នាក់រៀនមានភាពបត់បែន សិស្សរៀនដោយខ្លួនឯង សាលារៀនមានបណ្តាញទំនាក់ទំណង មានទស្សនវិជ្ជាអប់រំមិនមានភាពដូចគ្នា និងសាលារៀនមិនកំណត់ស្តង់ដាតែមួយ។ ៤) ការសិក្សាបែបស្ថាបនានិយម គឺជាវិធីសាស្រ្តបង្រៀនមួយដែលបូកបញ្ចូលទ្រឹស្តីសិក្សាផ្សេងៗទៀត ដូចជា ការសិក្សាអាស្រ័យលើបញ្ហា ការពិចារណាស៊ីជម្រៅ ការសិក្សាបែបស្រាវជ្រាវ ការបង្កើតបញ្ញត្តិ ការសិក្សាបែបរិះរក ការឆ្លុះបញ្ចាំងពីបទពិសោធន៍ និងការពិភាក្សាក្រុម។ ៥) ការសិក្សាបែបសហការ គឺវិធីសាស្រ្តបង្រៀនមួយដែលផ្តល់ឱកាសឱ្យសិស្សរៀនរួមគ្នាជាក្រុមតូច ធ្វើឱ្យសិស្សសិក្សាយ៉ាងសកម្ម រៀនជួយគ្នាទៅវិញទៅមក និងទទួលបានការគាំទ្របែបបណ្តាញកុមារជួយកុមារ។ ៦) ការសិក្សាបែបគម្រោងគឺជាវិធីសាស្រ្តបង្រៀនមួយដែលសិក្សាលើបទពិសោធន៍ ផ្តល់ឱ្យសិស្សនូវឱកាសដើម្បីសំយោគចំណេះដឹងពីផ្នែកផ្សេងៗនៃការសិក្សា រួចអនុវត្តវាទៅក្នុងស្ថានភាពរស់នៅប្រចាំថ្ងៃ ឬការស្រាវជ្រាវប្រកបដោយការវិភាគ និងច្នៃប្រឌិត។ ការសិក្សាបែបនេះជួយលើកកម្ពស់ចំណេះដឹងដល់សិស្ស និងអាចឱ្យពួកគេទទួលបានបំណិន ដូចជា បំណិនសហការ បំណិនប្រាស្រ័យទាក់ទង និងការរៀនដោយម្ចាស់ការ ព្រមទាំងរៀប (**អានបន្តទំព័រ 10...**)

( ...តពីទំព័រ ៩ ) ចំពួកគេសម្រាប់ការរៀនពេញមួយជីវិត និងត្រៀមខ្លួនក្នុងការប្រឈមនឹងឧបសគ្គនាពេលអនាគត។ ៧) ការសិក្សាបែបចម្រុះ គឺជាវិធីសាស្រ្តមួយផ្នែករៀនតាមរយៈអនឡាញ មួយផ្នែករៀនក្នុងបន្ទប់សិក្សា ហើយត្រូវគ្រប់គ្រងលើជាតុសំខាន់មួយចំនួន ដូចជា ពេលវេលា ទីតាំង វគ្គសិក្សា និងល្បឿនរបស់សិស្ស។ ៨) ប្លូមតាក់សូណូមី លោកគ្រូអ្នកគ្រូត្រូវប្រើប្រាស់តាក់សូណូមីសម្រាប់ការវាយតម្លៃ ការបង្កើតកម្មវិធីសិក្សា និងការសរសេរវត្ថុបំណងបង្រៀនតាមមុខវិជ្ជានីមួយៗ។ ប្លូមតាក់សូណូមីមាន៦កម្រិត ដូចជា ការចងចាំ ការយល់ដឹង ការអនុវត្ត ការវិភាគ ការវាយតម្លៃ និងការបង្កើតថ្មី។ ៩) ការវាយតម្លៃសិស្សក្នុងថ្នាក់រៀន គឺដើម្បីតាមដានវឌ្ឍនភាពរបស់សិស្សឆ្ពោះទៅរកការសម្រេចបាននូវការរំពឹងទុក។ ដូច្នេះ គ្រូអាចផ្តល់នូវមតិត្រលប់ទៅកាន់សិស្ស រៀបចំផែនការក្នុងការឆ្លើយតប ដូរវិធីសាស្រ្តបង្រៀន និងការវាយតម្លៃដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស។ ១០) ការអប់រំបំណិនជីវិត គឺជាការសិក្សាអំពីជីវភាពប្រចាំថ្ងៃ អំពីអាជីព ដើម្បីបណ្តុះបញ្ញាស្មារតី ចេះជួយគ្នា សហការ និងចេះដោះស្រាយបញ្ហាប្រឈម និង ១១) ការប្រើប្រាស់ ICT សំដៅដល់ក្នុងការបង្រៀនដោយប្រើប្រាស់បច្ចេកវិទ្យាជំនួយដល់ការបង្រៀន និងរៀន ការបង្កើតមេរៀន ការធ្វើតេស្ត ការដាក់ពិន្ទុតាមកម្មវិធីអប់រំ និងប្រព័ន្ធអនឡាញដែលឆ្លើយតបតាមយុគសម័យឌីជីថល។

លោក **ណេង ផ្លុយ** ជាគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសនៅវិទ្យាល័យ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ មានប្រសាសន៍ថា ***“ការបណ្តុះបណ្តាលនេះគឺមានអត្ថប្រយោជន៍ជាច្រើនសម្រាប់ការបង្រៀន និងរៀន ពីព្រោះខ្ញុំបានរៀនសូត្រ និងយល់ដឹងកាន់តែច្បាស់អំពី គោលបំណងបង្រៀន ការកំណត់គោលដៅ វិធីសាស្រ្តបង្រៀន ការវាយតម្លៃ សកម្មភាព បច្ចេកទេស ល្បែងសិក្សា បំណិនជីវិត និងចេះប្រើប្រាស់បច្ចេកវិទ្យាថ្មីមួយចំនួនក្នុងការបង្រៀនសិស្ស ដោយមានភាពបត់បែនតាមកាលៈទេសៈគួបផ្សំនឹងវិធីសាស្រ្តបង្រៀនថ្មីៗ ដើម្បីឆ្លើយតបទៅនឹងការអប់រំបែបសតវត្សរ៍ទី២១ សម្រាប់យកទៅអនុវត្តន៍ក្នុងសាលារៀន”***។


*សកម្មភាពក្រុមត្រៀមធ្វើបទបង្ហាញពីអ្វីដែលពួកគាត់បានពិភាក្សាដល់ក្រុមដទៃ*

អ្នកគ្រូ **ជាន សុជាតា** ជាគ្រូបង្រៀននៅសាលាបឋមសិក្សាអង្គរបាន បានមានប្រសាសន៍ថា ***“នាងខ្ញុំពិតជាសប្បាយចិត្តយ៉ាងខ្លាំងដែលទទួលបានឱកាសចូលរួមការបណ្តុះបណ្តាលនេះ ពីព្រោះនាងខ្ញុំទទួលបានចំណេះដឹងថ្មីៗជាច្រើន រួមមាន៖ ស្គាល់ពីរបៀបបង្រៀន និងរៀននៅសាលារៀនជំនាន់ថ្មី ចេះរៀបចំផែនការគន្លងអាជីពគ្រូ ស្គាល់ពីតួនាទីគ្រូប្រឹក្សាដែលចាំជួយជំរុញគ្រូក្នុងការបង្រៀន ស្គាល់កាន់តែច្បាស់ពីការប្រើប្រាស់ប្លូមតាក់សូណូមីទាំង៦កម្រិត ដឹងពីការប្រើប្រាស់សម្ភារៈឧបទេសក្នុងការបង្រៀន ចេះប្រើប្រាស់បច្ចេកវិទ្យាមួយចំនួនជំនួយដល់ការបង្រៀន និងរៀន និងមានវិធីសាស្រ្តល្អៗយ៉ាងសម្បូរបែបសម្រាប់យកទៅអនុវត្តក្នុងការថ្នាក់រៀន។ សិក្ខាសាលានេះ បានចូលរួមចំណែកអភិវឌ្ឍសមត្ថភាពក្នុងការបង្រៀនរបស់នាងខ្ញុំក៏ដូចជាបានជួយជំរុញឱ្យមានកម្លាំងចិត្តក្នុងការបំពេញការងារ ព្រមទាំងពង្រឹងវិជ្ជាជីវៈជាគ្រូបង្រៀនដើរឱ្យទាន់សម័យកាល”***។

លោក **ផាន វាសនា** ជាគ្រូបង្រៀនជីវវិទ្យានៅវិទ្យាល័យ ព្រែកលៀប បានលើកឡើងថា ***“ការបណ្តុះបណ្តាលនេះពិតជាល្អសម្រាប់គ្រូបង្រៀនពាក់ព័ន្ធវិធីសាស្រ្តល្អៗសម្រាប់ពង្រឹងដំណើរការបង្រៀន និងរៀននៅក្នុងកម្មវិធីសាលារៀនជំនាន់ថ្មី និងរបៀបរៀបចំសំណួរឱ្យបានសមស្របតាមសមត្ថភាពសិស្ស ជាពិសេសវិធីសាស្រ្តសិក្សាស្រាវជ្រាវថ្មីៗមកបង្រៀនប្រកបដោយភាពច្នៃប្រឌិត និងបង្កើតបរិយាកាសរីករាយក្នុងការរៀនសូត្រតាមបែបសម័យឌីជីថល”***។

អ្នកគ្រូ **ចេង ស្រីម៉ូវ** ជាគ្រូបង្រៀនភាសាអង់គ្លេសនៅវិទ្យាល័យ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ព្រែកអញ្ចាញ មានប្រសាសន៍ថា ***“ការបណ្តុះបណ្តាលរបស់កម្មវិធីសាលារៀនជំនាន់ថ្មី មានប្រព័ន្ធកម្មវិធីសិក្សាល្អជាងសាលារដ្ឋធម្មតា ការសិក្សាផ្តោតទៅលើការអនុវត្តជាក់ស្តែងជាជាងការសិក្សាតាមបែបទ្រឹស្តីដែលធ្វើឱ្យសិស្សមានការគិតបែបស៊ីជម្រៅ មានអគារសិក្សាបំពាក់ដោយគ្រឿងបរិក្ខារសិក្សាជាច្រើន មានសម្ភារឧបទេសគ្រប់គ្រាន់ មានប្រព័ន្ធអ៊ីនធើណែតសម្រាប់គ្រូ និងសិស្សប្រើប្រាស់សិក្សាស្រាវជ្រាវ និងបានពង្រឹងវិជ្ជាជីវៈជាគ្រូបង្រៀន”***។

ជាគោលការណ៍របស់កម្មវិធីសាលារៀនជំនាន់ថ្មី សមត្ថភាពគ្រូបង្រៀនជាកត្តាដ៏សំខាន់ និងត្រូវបានជ្រើសរើសដោយមានការវាយតម្លៃហ្មត់ចត់ដោយផ្អែកលើបទពិសោធន៍ និងគុណវឌ្ឍន៍ជាក់ស្តែង និងតម្រូវឱ្យបណ្តុះបណ្តាលបំប៉នសមត្ថភាព និងតម្រង់ទិសបន្ថែមមុននឹងចាប់ផ្តើមបង្រៀនសិស្សនៅសាលារៀនជំនាន់ថ្មី។ ការបបណ្តុះបណ្តាលនេះបានជួយអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន លើកកម្ពស់គុណភាពអប់រំ ផ្តល់វិធីសាស្រ្តបង្រៀនថ្មីៗមានលក្ខណៈបត់បែនតាមស្ថានការណ៍ និងបានបង្ហាញពីការប្រើប្រាស់បច្ចេកវិទ្យាមួយចំនួនជំនួយដល់ការបង្រៀន និងរៀនដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារក្នុងសតវត្សរ៍ទី២១ ហើយស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលចង់ប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ២០៥០។



អនុវិស័យទី ២

# បច្ចេកវិទ្យាព័ត៌មាន និង សារគមនាគមន៍សម្រាប់ ការអប់រំ

*"បច្ចេកវិទ្យានឹងមិនអាចជំនួសគ្រូដ៏ឆ្នើមៗបានទេ ប៉ុន្តែគ្រូឆ្នើមៗ ក៏មិនអាចអត់បច្ចេកវិទ្យាសម្រាប់បរិវត្តកម្មបានដែរ"*

## Information and Communication Technology (ICT) in Education

*"Technology will never replace great teachers, but in the hands of great teachers, it's transformational"*

# ការចុះប្រមូលទិន្នន័យក្នុងថាប់ប្លែតនៅតាមសាលារៀនគោលដៅ

នៅថ្ងៃទី២០-២១ ខែតុលា ឆ្នាំ២០២១ គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ ហៅកាត់ថា (TRAC III) បានធ្វើការប្រមូលទិន្នន័យ និងវាយតម្លៃដំណើរការបណ្ណាល័យសតវត្សរ៍ទី២១ នៅតាមសាលារៀនគោលដៅទាំង១៨របស់ខ្លួនក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។ សកម្មភាពនេះរៀបចំឡើងក្នុងគោលបំណងដើម្បីពិនិត្យវឌ្ឍនភាពគម្រោង និងបញ្ហាប្រឈមមួយចំនួនដែលសាលារៀនបានជួបប្រទះ អំឡុងពេលសាលាបិទទ្វារជាច្រើនខែកន្លងមកនេះ។

កម្មវិធី M-Learning ជាកម្មវិធីសិក្សាអេឡិចត្រូនិកមួយរបស់គម្រោងដែលកំពុងត្រូវបានតម្លើងដាក់ឱ្យប្រើប្រាស់ក្នុងថាប់ប្លែត ដើម្បីលើកកម្ពស់សមត្ថភាពអានរបស់កុមារពីចម្ងាយសម្រាប់ការអប់រំបែបឌីជីថលក្នុងបរិបទជំងឺកូវីដ-១៩។



សិស្សកំពុងប្រើប្រាស់កម្មវិធី M-learning សៀវភៅឆ្លាតរបស់អង្គការ ខេប នៅលើថាប់ប្លែតក្នុងបណ្ណាល័យ។

ការប្រមូលទិន្នន័យក្នុងថាប់ប្លែតនៅតាមសាលារៀន ជាសូចនាករសំខាន់ជួយឱ្យគម្រោងដឹងពីការប្រើប្រាស់កម្មវិធីអេឡិចត្រូនិកនៅលើថាប់ប្លែត និងងាយស្រួលសម្រាប់គម្រោងតាមដានសកម្មភាពនានា ក៏ដូចជារិះរកមធ្យោបាយអន្តរាគមន៍ចម្រុះដល់សិស្សក្នុងការពង្រឹងសមត្ថភាពអំណានថ្នាក់ដំបូង ដែលជាមូលដ្ឋានគ្រឹះសម្រាប់រៀនមុខវិជ្ជាដទៃទៀតបានយ៉ាងរហ័ស ទោះបីជាពួកគេមិនបានមកសាលារៀនផ្ទាល់ក៏ដោយ។



មន្ត្រីគម្រោងចុះប្រមូលទិន្នន័យក្នុងថាប់ប្លែតនៅសាលាបឋមសិក្សា ប៊ុន រ៉ានី ហ៊ុន សែនក្រូចឆ្មារ

នៅតាមសាលារៀនគោលដៅទាំងអស់ទទួលបានថាប់ប្លែតចន្លោះពី ២០ ទៅ ២៥ គ្រឿងឱ្យសិស្សមកប្រើប្រាស់នៅក្នុងបណ្ណាល័យ ពង្រឹងអំណាន។ កម្មវិធី M-Learning នេះមានរឿងអប់រំអេឡិចត្រូនិកជាច្រើនសម្បូរបែបសម្រាប់សិស្សសិក្សា ប៉ុន្តែសិស្សភាគច្រើននៅតាមសាលារៀននីមួយៗមិនសូវបានប្រើប្រាស់ថាប់ប្លែតក្នុងការសិក្សានោះទេ ដោយសារការឆ្លងរីករាលដាលជាសកលនៃជំងឺកូវីដ-១៩។ គម្រោងត្រាក់៣នៅតែបន្តតាមដាន ត្រួតពិនិត្យ និងជំរុញឱ្យគ្រប់សាលារៀនគោលដៅទាំងអស់បង្កើតសកម្មភាពសិស្សសិក្សាតាមថាប់ប្លែតបានច្រើន។

# ថាប់ប្លែតគឺជាឧបករណ៍អេឡិចត្រូនិកជួយសិស្សសិក្សាដោយខ្លួនឯង



អ្នកគ្រូតំណាងឱ្យសាលាបឋមសិក្សាក្រញូងបានទទួលថាប់ប្លែតចំនួន១២គ្រឿងពីគម្រោងត្រាក់៣ដាក់ឱ្យសិស្សសិក្សា។

កាលពីថ្ងៃទី២៦ដល់ទី២៧ ខែតុលា ឆ្នាំ ២០២១ គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRACIII) បានផ្តល់ថាប់ប្លែតដែលជាឧបករណ៍អេឡិចត្រូនិកដោយបានដាក់បញ្ចូលកម្មវិធីពង្រឹងអំណានមួយចំនួន (កម្មវិធីអានខ្មែរ សរសេរខ្មែរ រឿងអប់រំ សៀវភៅឆ្លាត) ជូនដល់សាលារៀនគោលដៅ (ជុំទី៣) ដែលមាន៦សាលា ដូចជា សាលាបឋមសិក្សាស្យាបឹងវែង សាលាបឋមសិក្សាបឹងត្រាវ សាលាបឋមសិក្សាស្ទើងជ័យ សាលាបឋមសិក្សាថ្កូវ សាលាបឋមសិក្សាជៀស និងសាលាបឋមសិក្សាក្រញូង។ គម្រោងបានប្រតិបត្តិសកម្មភាពឆ្នាំទី២របស់ខ្លួនយ៉ាងជោគជ័យនៅសាលាគោលដៅចំនួន១២ក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ។ ផ្អែកលើលទ្ធផលធ្វើតេស្តអំណាន មូលនិធិហ្វីនិកបានបន្តផ្តល់ជំនួយហិរញ្ញប្បទានដល់គម្រោងត្រាក់៣ចំនួន២ឆ្នាំទៀត ដោយពង្រីកសាលារៀនគោលដៅដល់ទៅចំនួន១៨សាលារៀន។ នេះបញ្ជាក់ថាលទ្ធផលសិក្សារបស់កុមារមានការកើនឡើង បើប្រៀបធៀបទៅនឹងឆ្នាំចាស់នាពេលកន្លងមក។

ការផ្តល់ថាប់ប្លែតគឺជាសកម្មភាពនឿនការសិក្សារបស់កុមារ និងបង្កបរិយាកាសរីករាយក្នុងការសិក្សា ព្រមទាំងបានជួយកុមារលើកកម្ពស់អំណានឱ្យកាន់តែប្រសើរឡើងនៅថ្នាក់ដំបូង (ថ្នាក់ទី១ ទី២ និងទី៣)។ កុមារទាំងអស់អាចប្រើប្រាស់ភាសាដើម្បីរៀនមុខវិជ្ជាដទៃៗទៀតបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាពខ្លាំង។

គម្រោងបានផ្តល់ថាប់ប្លែតដល់សាលារៀនគោលដៅទៅតាមចំនួនសិស្សតិច ឬច្រើននៅក្នុងថ្នាក់រៀនជាក់ស្តែង។ ការធ្វើតេស្តដំណាក់កាលតាមថាប់ប្លែតជាធាតុសំខាន់របស់គម្រោងក្នុងការអនុវត្តកម្មវិធីនៅក្នុងសាលារៀនគោលដៅទាំងអស់ ហើយការធ្វើតេស្តនេះមិនឱ្យលើសពីពីរបីដងឡើយ។ ប្រសិនបើមានសិស្សច្រើនធ្វើតេស្តលើសពីពីរដង នោះគម្រោងនឹងពិភាក្សាជាមួយនាយកសាលាឱ្យចូលរួមបដិភាគថវិកា ដើម្បីទិញថាប់ប្លែតបន្ថែមដាក់បញ្ចូលសាលាទៅតាមចំនួនសិស្សមកសិក្សាជាក់ស្តែងច្រើន ឬតិច៕



គ្រូតំណាងសាលាបឋមសិក្សាថ្កូវទទួលថាប់ភ្លែត១២គ្រឿងពីគម្រោងត្រាក់៣។

អនុវិស័យទី

# ៣

# ការអភិវឌ្ឍគ្រូបង្រៀន

"គ្រូដែលល្អមិនមែនគ្រាន់តែជាអ្នកប្រាប់ ជាអ្នកពន្យល់ និងបង្ហាញនោះទេ
តែជាអ្នកជំរុញលើកទឹកចិត្តសិស្ស"

## Teacher Development

*"The mediocre teacher tells. The good teacher explains.
The superior teacher demonstrates. The great teacher inspires."*



# ការប្រើប្រាស់កញ្ចប់ឯកសារបង្រៀនបន្ថែមក្នុងបរិបទជំងឺកូវីដ-១៩



*លោកគ្រូអ្នកគ្រូមកពីសាលារៀនគោលដៅចំនួន ២២ ក្នុងខេត្តស្វាយរៀង និងព្រៃវែង។*

កាលពីថ្ងៃទី១៤-១៥ ខែតុលា ឆ្នាំ ២០២១ គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (REACH IV) បានរៀបចំសិក្ខាសាលាស្តីពី **"ការប្រើប្រាស់កញ្ចប់ឯកសារបង្រៀនបន្ថែមក្នុងបរិបទជំងឺកូវីដ-១៩"** ដែលធ្វើឡើងតាមប្រព័ន្ធអនឡាញ(Google Meet)។ សិក្ខាសាលានេះមានសិក្ខាកាមចូលរួមសរុបចំនួន ២២៧នាក់ ដែលជានាយក នាយិកា និងលោកគ្រូអ្នកគ្រូមកពីសាលារៀនគោលដៅចំនួន២២ក្នុងខេត្តស្វាយរៀង និងព្រៃវែង។

សិក្ខាសាលានេះមានគោលបំណងពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូលើការប្រើប្រាស់កញ្ចប់ឯកសារបង្រៀនបន្ថែមថ្នាក់ទី២ ដល់ទី៦ ឱ្យចំគោលដៅប្រកបដោយគុណភាព និងមានប្រសិទ្ធភាព។

លោកគ្រូអ្នកគ្រូបានស្វែងយល់ពីការប្រើប្រាស់កញ្ចប់ឯកសារបំប៉នបន្ថែម ការរៀបចំសម្ភារៈបង្រៀន និងរៀន ការប្រើប្រាស់ទ្រឹស្តីប្លូមមកពិពណ៌នាកម្រិតយល់ដឹងរបស់សិស្ស និងចេះបង្កើតសកម្មភាពបង្រៀនស្រដៀងៗគ្នាដើម្បីបង្រៀនសិស្សរៀនយឺតផងដែរ។

ការផ្តល់វគ្គសិក្ខាសាលាដល់លោកគ្រូអ្នកគ្រូនៅតាមសាលារៀនគោលដៅគឺជាសកម្មភាពចម្បងរបស់គម្រោង ដើម្បីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនដោយប្រើវិធីសាស្ត្របង្រៀនថ្មីៗបែបចម្រុះដល់សិស្សានុសិស្សក្នុងការសិក្សារៀនសូត្រ និងបង្កើតភាពងាយស្រួលចូលសាលារៀនដោយផ្អែកលើគោលនយោបាយកម្មវិធីសាលារៀនកុមារមេត្រី៕

# សមត្ថភាពប្រើប្រាស់សៀវភៅពន្លឿនការសិក្សាមានសារៈសំខាន់ខ្លាំង



*សកម្មភាពលោកគ្រូអ្នកគ្រូចូលរួមជាមួយគម្រោងដើម្បីពង្រឹងសមត្ថភាពលើការប្រើប្រាស់សៀវភៅពន្លឿនការសិក្សា។*

គម្រោងកុមារកម្ពុជារីករាយបានរៀបចំសិក្ខាសាលាស្តីពី **"ការប្រើប្រាស់សៀវភៅពន្លឿនការសិក្សា"** ពីថ្ងៃទី១៨ដល់ទី២០ ខែតុលា ឆ្នាំ២០២១ តាមប្រព័ន្ធអនឡាញ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន២៤៨នាក់ ដែលជាមន្ត្រីមន្ទីរនិងការិយាល័យអប់រំ យុវជន និងកីឡាស្រុក-ខេត្ត នាយក/នាយិកា និងលោកគ្រូអ្នកគ្រូដែលមកពីសាលារៀនគោលដៅចំនួន៣០នៅក្នុងខេត្តត្បូងឃ្មុំ ក្រចេះ រតនគិរី និងសៀមរាប។

សិក្ខាសាលានេះ មានគោលបំណងផ្តល់ឱកាសដល់លោកគ្រូអ្នកគ្រូសិក្សាអំពីរបៀបប្រើប្រាស់សៀវភៅពន្លឿនការសិក្សាក្នុងការសម្របសម្រួលដល់ការរៀនរបស់សិស្សដែលខកខានមិនបានរៀនពេញលេញក្នុងអំឡុងពេលរីករាលដាលជំងឺកូវីដ-១៩ និងធ្វើយ៉ាងណាឱ្យពួកគេទទួលបានចំណេះដឹង និងមានមូលដ្ឋានគ្រឹះរឹងមាំអាចឈានទៅកាន់កម្រិតថ្នាក់ថ្មី ទោះបីជាពួកគេមិនទទួលបានការអប់រំនៅក្នុងសាលារៀនក៏ដោយ។

លោក **ឆែម ឌុំ** ជានាយកសាលាបឋមសិក្សាសាមគ្គី ស្រុកអូរជុំ (**អានបន្តទំព័រ ១៦...**)

(...តពីទំព័រ ១៥)ខេត្តរតនគិរីបានមាន



លោក ផែម ឌុំ នាយកសាលាបឋមសិក្សាសាមគ្គី

ប្រសាសន៍ថា *"សិក្ខាសាលានេះមានអត្ថប្រយោជន៍ណាស់សម្រាប់ខ្ញុំ ក៏ដូចជាលោកគ្រូអ្នកគ្រូដទៃទៀត ព្រោះធ្វើឱ្យគ្រូៗងាយស្រួលក្នុងការបង្កើតថ្នាក់ពន្លឿនការសិក្សា និងថ្នាក់ធម្មតាសម្រាប់ឆ្នាំសិក្សាបន្ទាប់ ចេះបែងចែកសិស្សទៅតាមកម្រិតអាយុ និងអាចជួយសិស្សឱ្យបានទាន់ពេលវេលា។ ម៉្យាងទៀត សៀវភៅពន្លឿនការសិក្សានេះធ្វើឱ្យសិស្សរៀនតែបីឆ្នាំចប់កម្រិតបឋម ហើយស្របនឹងអាយុរបស់ពួកគេ"*។

លោក **ទ្រី អ៊ុយគា** ជាគ្រូបង្រៀនកិច្ចសន្យានៃសាលាបឋមសិក្សា ហ៊ុន សែន ផ្គាវ ស្រុកតំបែរ បានមានប្រសាសន៍ថា *"ខ្ញុំទទួលបានចំណេះដឹងថ្មីៗជាច្រើនទាក់ទងនឹងការប្រើប្រាស់សៀវភៅពន្លឿនការសិក្សា យល់ដឹងពីភាពបន្ទុះរវាងសៀវភៅសិក្សាគោល និងសៀវភៅពន្លឿនការសិក្សាគ្រូ និងសិស្សថ្នាក់ទី២។ សិក្ខាសាលានេះបានផ្តល់ចំណេះដឹងល្អៗជាច្រើនសម្រាប់ខ្ញុំយកទៅអនុវត្តក្នុងការបង្រៀន ដើម្បីបង្កើតបរិយាកាសរីករាយសម្រាប់សិស្សក្នុងការរៀនសូត្រ"*។



លោក ទ្រី អ៊ុយគា គ្រូកិច្ចសន្យាសាលាបឋមសិក្សា ហ៊ុន សែន ផ្គាវ ខេត្តត្បូងឃ្មុំ

លោកគ្រូអ្នកគ្រូទទួលបានចំណេះដឹងបន្ថែមទាក់ទងទៅនឹងការបង្រៀន និងរៀនលើសៀវភៅពន្លឿនការសិក្សា ដូចជា ដឹងពីរបៀបបង្រៀនចំណុចសំខាន់ៗក្នុងសៀវភៅពន្លឿនមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ឆ្នាំទី១ ដល់ថ្នាក់ឆ្នាំទី៣ ចេះបំណែងចែកកម្មវិធីសិក្សាលំនាំនៃការបង្រៀន ដឹងពីភាពខុសគ្នារវាងសៀវភៅគ្រូ និងសៀវភៅសិស្ស ភាពខុសគ្នារវាងសៀវភៅថ្នាក់ពន្លឿនការសិក្សា និងសៀវភៅសិក្សាគោល ចេះពីរបៀបធ្វើតេស្ត និងស្រង់ពិន្ទុ។ ដូច្នេះ ការពង្រឹងសមត្ថភាពគ្រូក្នុងការប្រើប្រាស់សៀវភៅពន្លឿនការសិក្សាគឺពិតជាមានសារៈសំខាន់ និងជួយជំរុញលើកកម្ពស់ការបង្រៀនឱ្យមានប្រសិទ្ធភាព៕

# តើការគ្រប់គ្រងថ្នាក់រៀន និងវិន័យបែបវិជ្ជមានមានន័យដូចម្ដេច ?

កាលពីថ្ងៃទី២៦ដល់ទី៣០ ខែតុលាឆ្នាំ ២០២១ គម្រោងងាយស្រួលរៀនក្រោមជំនួយហិរញ្ញប្បទានពីអង្គការឆាលហ្វាន កម្ពុជា បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី **"វិន័យបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធិភាព និងកម្មវិធីសាលាកុមារមេត្រី"** ដែលអនុវត្តនៅតាមសាលារៀនគោលដៅចំនួនប្រាំមួយក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង រួមមាន៖ សាលាបឋមសិក្សាកំពង់ត្របែក បឋមសិក្សាទួលរកា បឋមសិក្សាអន្សោង បឋមសិក្សាគ្រើល បឋមសិក្សាព្រៃពោន និងបឋមសិក្សាបេងបុរី។ វគ្គបណ្ដុះបណ្ដាលនេះមានអ្នកចូលរួមសរុបមានចំនួន ១២២នាក់ រួមមាន៖ មន្ទីរការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុក នាយក លោកគ្រូអ្នកគ្រូ និងអ្នកសម្របសម្រួលរបស់គម្រោង។



សកម្មភាពសម្ដែងតួតុលាការសុប្បនិម្មិត

វគ្គបណ្ដុះបណ្ដាលនេះធ្វើឡើងក្នុងគោលបំណងដើម្បីផ្សព្វផ្សាយការអនុវត្តកម្មវិធីវិន័យតាមបែបវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងផ្សារភ្ជាប់ការអនុវត្តជាក់ស្ដែងរបស់គ្រូនៅតាមសាលារៀនជាមួយសិស្សឱ្យកាន់តែមានភាពល្អប្រសើរក្នុងការបង្រៀន និងរៀន។

លោកគ្រូអ្នកគ្រូបានសិក្សាអំពី ការកំណត់បានពីទណ្ឌកម្មរាងកាយ និងផ្នែកស្មារតី ផលវិបាកទណ្ឌកម្មរាងកាយ និងផ្នែកស្មារតី ការឆ្លុះបញ្ចាំង និងការស្វែងយល់អំពីសារៈសំខាន់អំពីតួនាទីគំរូ ការកំណត់ពីរបៀបដែលសិស្សរៀនបានច្រើនបំផុត ការគ្រប់គ្រងអារម្មណ៍ និងរង្វាប់កំហឹង ការអនុវត្តការដាក់វិន័យបែបវិជ្ជមានជំនួសដោយទណ្ឌកម្មរាងកាយ និងផ្នែកស្មារតី និងសរសេរគោលការណ៍សម្រាប់ថ្នាក់រៀនជាមួយសិស្ស និងលើកទឹកចិត្តសិស្សឱ្យមានអាកប្បកិរិយាល្អ ឱ្យមានការផ្លាស់ប្ដូរទម្លាប់អនុវត្តកាលវិភាគសិក្សាប្រចាំថ្ងៃ៕

# តើត្រូវធ្វើបែបណាឱ្យកម្មវិធីសិក្សាលម្អិត និងការរៀនពីចម្ងាយល្អ?

កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២១ គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍(រីក៤/REACH IV) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "**កម្មវិធីសិក្សាលម្អិត និងការរៀនពីចម្ងាយ**" តាមប្រព័ន្ធអនឡាញដល់សាលារៀនគោលដៅចំនួន១៦នៅក្នុងខេត្តព្រៃវែង និងស្វាយរៀង ដោយមានគ្រូនិងនាយកសាលាសរុបចំនួន៣៥នាក់ចូលរួម។



*សាលារៀនគោលដៅចំនួន១៦ ដែលមានសមាសភាពអ្នកចូលរួមសរុបចំនួន ៣៥នាក់ ។*

វគ្គបណ្តុះបណ្តាលនេះមានបំណង៖ ១)-ពង្រឹងសមត្ថភាពគ្រូមត្តេយ្យសិក្សារដ្ឋស្តីពីការបំពេញកម្មវិធីសិក្សាចុងឆ្នាំ ២)-ពង្រឹងលើការបង្រៀន និងរៀនតាមប្រព័ន្ធអនឡាញ ៣)-ពង្រឹងលើមុខវិជ្ជាភាសាខ្មែរ និងបុរេគណិតវិទ្យានិងរំលឹកឡើងវិញនូវកម្មវិធីសិក្សាលម្អិត និងតេស្តកុមារ៥ឆ្នាំក៏ដូចជារៀបចំផែនការបន្ត។

អ្នកស្រី **ញឹម រចនា** ជាគ្រូបង្រៀននៅសាលាបឋមសិក្សាវត្តស្លាបានមានប្រសាសន៍ថា "*ចំណេះដឹងល្អៗជាច្រើនដែលខ្ញុំទទួលបានពីវគ្គបណ្តុះបណ្តាលរបស់គម្រោងរីក វាពិតជាបានជួយពង្រឹងសមត្ថភាពខ្ញុំក្នុងការបង្រៀន និងរៀនក្នុងបរិបទជំងឺកូវីដ-១៩ ជាពិសេសខ្ញុំបានយល់ដឹងអំពីវិធីសាស្ត្របង្រៀនបន្ថែម និងការបំពេញកិច្ចតែងការបង្រៀនឱ្យស្របតាមកម្មវិធីសិក្សា ហើយខ្ញុំបានរៀនពីការចែករំលែកពិសោធន៍ល្អៗរវាងលោកគ្រូអ្នកគ្រូដែលចូលរួមជាមួយគ្នា។ ខ្ញុំនឹងយកចំណុចល្អៗទាំងនោះមកអនុវត្តក្នុងថ្នាក់រៀន ធ្វើយ៉ាងណាឱ្យកុមារបានសិក្សាប្រកបដោយគុណភាពល្អ*"។

លោក **ហួត វណ្ណៈ** គ្រូបង្រៀននៅសាលាបឋមសិក្សាថ្មីបានមានប្រសាសន៍ថា "*វគ្គបណ្តុះបណ្តាលនេះ ពិតជាមានអត្ថប្រយោជន៍ដល់គ្រូបង្រៀនដូចជាខ្ញុំសម្រាប់យកទៅបង្រៀនសិស្សជាមួយវិធីសាស្ត្រថ្មីៗ និងមានលក្ខណៈច្នៃប្រឌិត*"។

វគ្គបណ្តុះបណ្តាលនេះបានផ្តល់នូវរបៀបបង្រៀនសិស្សតាមបែបបំពេញកម្មវិធីសិក្សាដល់លោកគ្រូអ្នកគ្រូយកទៅអនុវត្តតាមសាលារៀនរៀងៗខ្លួន៕

# ការបណ្តុះទម្លាប់ល្អដល់សិស្សតាមរយៈការបង្កើតក្លឹបអំណាន

កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ គម្រោងអប់រំកុមារីបានរៀបចំបណ្តុះបណ្តាលស្តីពី **"ការបង្កើតក្លឹបអំណាន"** រយៈពេលមួយថ្ងៃពេញនៅក្នុងខេត្តកំពង់ចាម ដោយមានអ្នកចូលរួមសរុបមានចំនួន៩នាក់ ដែលជានាយក លោកគ្រូអ្នកគ្រូទទួលបន្ទុកអាហារូបករណ៍ពីសាលារៀនគោលដៅ និងសម្របសម្រួលដោយមន្ត្រីកម្មវិធីអប់រំកុមារីអង្គការខេប។

ការបណ្តុះបណ្តាលនេះមានគោលបំណងផ្តោតសំខាន់ទៅលើ៖ ១).ការបង្កើនភាពយល់ដឹងពីគម្រោងអប់រំគម្រោងអប់រំកុមារី ២).ការស្វែងយល់ពីលទ្ធផលការសិក្សា និងបញ្ហាប្រឈមរបស់សិស្សអាហារូបករណ៍។ ៣). (**អានបន្តទំព័រ ២០...**)



*កញ្ញា ស៊ីម ផល្លី ប្រធានក្រុម GEI បានធ្វើបទបង្ហាញអំពីការបង្កើតក្លឹបអំណាន។*

# កិច្ចប្រជុំស្តីពីតួនាទី និងការគ្រប់គ្រងបណ្ណាល័យក្នុងបរិបទកូវីដ-១៩

គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (រីក/REACH IV) បានរៀបចំកិច្ចប្រជុំស្តីពី **"ការរំលឹកឡើងវិញតួនាទី និងមុខងារបណ្ណាល័យបឋមសិក្សា និងការងារបណ្ណាល័យក្នុងបរិបទកូវីដ-១៩"** ដែលធ្វើឡើងតាមប្រព័ន្ធអនឡាញ (Google Meet) កាលពីថ្ងៃទី១៥ ដល់ទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១។ សមាសភាពអ្នកចូលរួមសរុបចំនួន៤២នាក់ រួមមាន៖ តំណាងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត នាយក និងបណ្ណារក្ស ដែលមកពីសាលារៀនគោលដៅចំនួន១៩ក្នុងខេត្តកំពង់ឆ្នាំង និងពោធិ៍សាត់។

កិច្ចប្រជុំនេះមានគោលបំណង ដើម្បី៖ ១-ស្វែងយល់ឡើងវិញនូវមុខងារ និងតួនាទីក្នុងបណ្ណាល័យបឋមសិក្សា។ ២-ឆ្លុះបញ្ចាំងសកម្មភាព និងលទ្ធផលការងារបណ្ណាល័យក្នុងត្រីមាសទី១ របស់បណ្ណារក្សកន្លងមកក្នុងឆ្នាំ២០២១។ ៣-រៀបចំផែនការបន្ត និងយន្តការរបស់ក្រុមការងារចុះជួយសាលា នាយកបណ្ណារក្ស និងក្រុមប្រឹក្សាកុមារសម្រាប់ឆមាសទី២ ឆ្នាំ២០២១ និងអន្តរាគមន៍សិស្សតាមរយៈការផ្តល់សៀវភៅសិក្សាគោល និងសម្ភារៈកុមារលេង ដោយប្រកាន់ភ្ជាប់វិធានការបីកុំ បីការពារ។

អ្នកគ្រូ **នៅ ចន្ធា** បណ្ណារក្សមកពីសាលាបឋមសិក្សាសំប៉ានបានមានប្រសាសន៍ថា *"ការចូលរួមកិច្ចប្រជុំនេះ ខ្ញុំទទួលបានចំណេះដឹងល្អៗមួយចំនួនទាក់ទងទៅនឹងការងារគ្រប់គ្រងបណ្ណាល័យ ការងាររដ្ឋបាល និងការរៀបចំបណ្ណាល័យឱ្យក្លាយទៅជាបណ្ណាល័យស្តង់ដា ជាពិសេសបានផ្លាស់ប្តូរបទពិសោធន៍ល្អៗពីលោកគ្រូអ្នកគ្រូ និងគ្រូឧទ្ទេសដែលធ្វើឱ្យខ្ញុំបានយល់ដឹងកាន់តែច្បាស់អំពីតួនាទី និងភារកិច្ចរបស់បណ្ណារក្ស"*។

កិច្ចប្រជុំនេះបានជួយពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូជាបណ្ណារក្សលើការគ្រប់គ្រងការងាររដ្ឋបាល និងការរៀបចំបណ្ណាល័យឱ្យមានសោភ័ណភាពល្អមានលក្ខណៈទាក់ទាញ និងកែលម្អវាឱ្យក្លាយទៅជាបណ្ណាល័យមួយដែលមានស្តង់ដា ជួយបង្កើននិងរក្សាចំនួនសិស្សចូលអានថេរ៕






*រូបភាពសិក្ខាកាមចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ស្តីពី តួនាទី និងការគ្រប់គ្រងបណ្ណាល័យក្នុងបរិបទជំងឺកូវីដ-១៩។*

# ការប្រឹក្សាគរុកោសល្យគាំទ្រដល់ការអប់រំស្ទែម/STEM

មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី នៃវិទ្យាស្ថានជាតិអប់រំ ក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(ខេប) បានរៀបចំសន្និសីទអន្តរជាតិលើកទី២ស្តីពី **ការប្រឹក្សាគរុកោសល្យក្រោមប្រធានបទ៖ គ្រូប្រឹក្សាគរុកោសល្យគាំទ្រដល់ការអប់រំស្ទឹម** ដែលបានរៀបចំឡើងតាមរយៈប្រព័ន្ធអនឡាញចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១។

គោលបំណងនៃការធ្វើសន្និសីទនេះ គឺដើម្បីពិនិត្យមើលលទ្ធភាពនៃការផ្តល់ប្រឹក្សាគរុកោសល្យតាមរបៀបផ្សេងៗ និងបង្កើតឱកាសដើម្បីជួយគ្រាំទ្រអ្នកអប់រំចំណោះទូទៅចាប់ពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី១២ ក្នុងការអភិវឌ្ឍសមត្ថភាពរបស់ពួកគេ ជាពិសេសនៅក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា (STEM)។ អ្នកចូលរួមសរុបមានចំនួនប្រមាណជា៥០០នាក់ ដែលជាអ្នកសិក្សាស្រាវជ្រាវ គ្រូបង្រៀន គ្រូឧទ្ទេស ទីប្រឹក្សាអប់រំ អ្នកប្រឹក្សាយោបល់ និងអ្នកពាក់ព័ន្ធផ្សេងទៀតមកពីប្រទេសចំនួន ១៧នៅជុំវិញពិភពលោក ចូលរួមចែករំលែកលទ្ធផលសិក្សាស្រាវជ្រាវ ចំណេះដឹង និងបទពិសោធន៍ផ្សេងៗអំពីការអប់រំ។

ក្នុងសន្និសីទអន្តរជាតិនេះមានប្រធានបទសំខាន់ជាច្រើន ដូចជា តួនាទី និងកាតព្វកិច្ចរបស់អ្នកផ្តល់ការប្រឹក្សាក្នុងការអប់រំស្ទែម (STEM) អនុវត្តន៍ការរប្រឹក្សា និងណែនាំតាមប្រព័ន្ធអនឡាញនៅក្នុងវិសាលភាពទូលំទូលាយ ការអប់រំស្ទែម និងយុទ្ធសាស្ត្រក្នុងការអនុវត្តនៅក្នុងប្រទេសកម្ពុជា ក្របខណ្ឌអភិវឌ្ឍន៍កម្មវិធីគ្រូប្រឹក្សាអាជីព ការប្រើប្រាស់ការបង្វឹកដើម្បីជួយកែលម្អការអនុវត្តរបស់គ្រូបង្រៀន យុទ្ធសាស្ត្រប្រកបដោយភាពច្នៃប្រឌិត និងការអនុវត្តល្អបំផុតកាប្រឹក្សាអាជីព និងណែនាំតាមប្រព័ន្ធអនឡាញសម្រាប់គ្រូសិក្សាភាសាអង់គ្លេស សមាសភាគ និងផលជះការប្រឹក្សាក្នុងការរអប់រំស្ទែម ព្រមទាំងមានប្រធានបទផ្សេងៗជាច្រើនទៀត។

លោកស្រីបណ្ឌិត ប៊ិវើលី ដេ អៀប៊ី បានមានប្រសាសន៍ថា "*ពួកយើងបានចុះអនុស្សរណៈយោគយល់គ្នាជាមួយមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី (NGPRC) ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន អ្នកអប់រំ និងអ្នកដឹកនាំដើម្បីបង្កើតសក្តានុពលលើផ្នែកសិក្សាស្រាវជ្រាវ និងអភិវឌ្ឍទាក់ទងនឹងការប្រឹក្សយោបល់ ដូចជា ធ្វើការផ្លាស់ប្តូរនិស្សិត ដើម្បីបង្កើន និងពង្រីកបទពិសោធន៍ល្អៗថ្នាក់អន្តរជាតិរវាងសហរដ្ឋអាមេរិក និងប្រទេសកម្ពុជាដោយចូលរួមតាមរយៈប្រព័ន្ធអនឡាញក្នុងអំឡុងពេលរីករាលជំងឺកូវីដ-១៩នេះ*"។

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ក្នុងសន្និសីទអន្តរជាតិលើកទី២នេះថា "*គោលបំណងសន្និសីទឆ្នាំនេះគឺស្វែងរកវិធីសាស្ត្រអប់រំថ្មីៗ និងឱកាសប្រឹក្សាយោបល់ណែនាំផ្សេងៗ ដែលរៀបចំឡើងដើម្បីជួយលោកគ្រូអ្នកគ្រូ និងអ្នកអប់រំក្នុងការអភិវឌ្ឍសមត្ថភាពរបស់ពួកគេ ជាពិសេសក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា។ មួយវិញទៀតសន្និសីទនេះនឹងជំរុញ ក៏ដូចជាផ្តួចផ្តើមកិច្ចសហប្រតិបត្តិការពីអ្នកចូលរួមកាន់តែច្រើនទាក់ទងទៅនឹងការប្រឹក្សាគរុកោសល្យគាំទ្រដល់ការអប់រំស្ទឹម*"។

សន្និសីទអន្តរជាតិនេះបានបង្កលទ្ធភាពច្រើន ក៏ដូចជាផ្តល់ឱកាសដល់អ្នកចូលរួមជាតិ និងអន្តរជាតិបានចែករំលែកចំណេះដឹងគោលគំនិតផ្សេងៗ បទពិសោធន៍ល្អៗ លទ្ធផលសិក្សាស្រាវជ្រាវ និងកិច្ចពិភាក្សាលើបញ្ហាប្រឈមនានា ដែលទាក់ទងនឹងការប្រឹក្សាគរុកោសល្យ ព្រមទាំងបានអនុញ្ញាតឱ្យអ្នកចូលរួមអាចអនុវត្តទៅតាមគន្លងអាជីពរបស់ខ្លួនដើម្បីចូលរួមបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់អ្នកប្រឹក្សាគរុកោសល្យ ហើយបង្កើតបានជាបណ្តាញសិក្សាអប់រំនៅទូទាំងពិភពលោក៕



*ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អញ្ជើញចូលរួមជាអធិបតីភាពបើកសន្និសីទអន្តរជាតិលើកទី២*

(...តពីទំព័រ១៧) បង្ហាញពីអត្ថប្រយោជន៍នៃការបង្កើតក្លឹបអំណាន និងរៀបចំបង្កើតក្លឹបអំណានតាមសាលារៀនគោលដៅ ។

ក្លឹបអំណាននេះបង្កើតឡើងដើម្បីឱ្យសិស្សអាហារូបករណ៍បង្កើនទម្លាប់អាន និងរៀនពាក្យថ្មីៗ មានគំនិតច្នៃប្រឌិត ចេះសង្ខេបរឿងដោយប្រើប្រាស់ពាក្យពេចន៍បានទូលំទូលាយ ចេះចែករំលែករឿង ឬអត្ថបទដែលបានអានដល់មិត្តភក្តិ និងយល់ដឹងពីការប្រើប្រាស់ពេលវេលាទំនេរឱ្យមានតម្លៃ។

លោកគ្រូអ្នកគ្រូបានយល់ដឹងនូវៈ ១) របៀបដឹកនាំក្លឹបអំណាន និងការអនុវត្តជាក់ស្តែង មានអ្នកអាន និងកត់ត្រារបាយការណ៍បន្ទាប់ពីអានសៀវភៅរឿងចប់។ ២) ភាពងាយស្រួលរៀបចំក្លឹបអំណានរបស់គ្រូទទួលបន្ទុកអាហារូបករណ៍។ ៣) បទពិសោធថ្មីទាក់ទងនឹងការបង្កើតក្លឹប។ ៤) ការជួយពង្រឹងសិស្សឱ្យចាប់អារម្មណ៍អំពីអំណានដោយចេះប្រើប្រាស់ពេលវេលារបស់ពួកគេឱ្យមានប្រយោជន៍។ ៥) ផលប្រយោជន៍របស់ក្លឹបច្បាស់លាស់។ ៦) វិធីសាស្ត្រថ្មីៗក្នុងការបង្រៀនធ្វើយ៉ាងណាឱ្យសិស្សក្លាហានជាងមុនក្នុងការពិភាក្សា និងស្វែងយល់ពីអត្ថន័យអប់រំក្នុងអត្ថបទរឿង។



លោកគ្រូកំពុងពិភាក្សាអំពីរបៀបដឹកនាំក្លឹបអំណានឱ្យកាន់តែមានប្រសិទ្ធភាពទ្វេឡើង។

សម្រាប់គោលដៅរយៈពេលវែង គម្រោងអប់រំកុមារីជួយគាំទ្រ និងផ្តល់សិទ្ធិអំណាចដល់ក្មេងស្រីដែលជួបការលំបាកប្រឈមនឹងការបោះបង់ការសិក្សា អាចបន្តការអប់រំរហូតដល់បញ្ចប់ការសិក្សានៅអនុវិទ្យាល័យនិងផ្តល់ការប្រឹក្សាអំពីគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈដែលពួកគាត់ត្រូវធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវមុនពេលបញ្ចប់គម្រោង។

ការបណ្តុះបណ្តាលនេះបានធ្វើឱ្យលោកគ្រូអ្នកគ្រូដែលជានាយកសាលា និងគ្រូទទួលបន្ទុកអាហារូបករណ៍ចេះធ្វើផែនការបង្កើតក្លឹបអានសៀវភៅចំនួន៣ខែដំបូង គឺចាប់ពីខែធ្នូ ឆ្នាំ២០២១ ដល់ខែកុម្ភៈ ឆ្នាំ២០២២) នេះតទៅ។ គម្រោងនឹងធ្វើការតាមដាន និងគាំទ្របន្តបន្ទាប់ពីដំណើរការក្លឹបអានសៀវភៅ។ កញ្ចប់អាហារូបករណ៍ត្រូវបានផ្តល់ឱ្យសាលារៀនគោលដៅចំនួន៥នៅក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំសម្រាប់សិស្សដែលងាយរងគ្រោះ និងអាចមានលទ្ធភាពបន្តការសិក្សារបស់ខ្លួនបានច្រើនបន្តទៀត៕

# ប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារ និងយុវជនប្រឈមនឹងហានិភ័យ

កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ គម្រោងសមត្ថភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម(CO-SAVED)បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី **"ប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារ និងយុវជនប្រឈមនឹងហានិភ័យ"** ដែលធ្វើឡើងនៅសាលាបឋមសិក្សាកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត។ សមាសភាពអ្នកចូលរួមសរុបចំនួន៦៥នាក់ ដែលជានាយក/នាយករង ប្រធានការិយាល័យបឋម អប់រំ យុវជន និងកីឡាខេត្តកំពត តំណាងមន្ត្រីការិយាល័យ អប់រំ យុវជន និងកីឡាស្រុកកំពង់ត្រាច តំណាងក្រុមប្រឹក្សាស្រុកកំពង់ត្រាច ប្រធានសមាគមក្រុមប្រឹក្សាកំពត និងអង្គការដៃគូ ព្រមទាំងបុគ្គលិកគម្រោង។ សាលារៀនគោលដៅចំនួន៤៦បានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ក្នុងនោះមានសាលាបឋមសិក្សាចំនួន១៥ និងអនុវិទ្យាល័យចំនួន១១សាលា។



សកម្មភាពលោកគ្រូៗពិភាក្សាអំពីការបំពេញទម្រង់កុមារងាយរងគ្រោះ

(អានបន្តទំព័រ ២១...)

(...តពីទំព័រ ២០) វគ្គបណ្ដុះបណ្ដាលនេះ មានគោលបំណងចែករំលែក និងរៀនសូត្រពីប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់កុមារ និងយុវជនប្រឈមនឹងហានិភ័យដល់អង្គការដៃគូ និងលោកគ្រូអ្នកគ្រូ ក៏ដូចជាអ្នកពាក់ព័ន្ធយកទៅអនុវត្តនៅតាមតំបន់គោលដៅ។

តាមរយៈបទបង្ហាញរបស់លោកស្រី **ឈី សុភារិទ្ធ** ជាប្រធានផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់អង្គការ Aide et Action បានលើកឡើងថា "*ប្រភេទកុមារក្រៅសាលារៀនមានចំនួនប្រាំប្រភេទ ដូចជា ១) កុមារដែលមិនបានចូលរៀន ២) កុមារដែលមានលទ្ធភាពទៅរៀន ប៉ុន្តែមិនបានចុះឈ្មោះ ៣) កុមារដែលមានលទ្ធភាពទៅរៀន និងបានចុះឈ្មោះចូលរៀន ប៉ុន្តែអត់ទៅរៀន ៤) កុមារដែលបោះបង់ការសិក្សា និងកុមារដែលស្ថិតក្នុងស្ថានភាពអាសន្ន ឬវិបត្តិ។ ទាំងនេះជាប្រភេទកុមារដែលងាយគ្រោះក្នុងការបោះបង់ការសិក្សានៅថ្នាក់បឋមសិក្សា*"។



លោកស្រី **ឈី សុភារិទ្ធ** ជាប្រធានផ្នែកត្រួតពិនិត្យតាមដាន និងវាយតម្លៃរបស់អង្គការ Aide et Action ធ្វើបទបង្ហាញពីប្រភេទកុមារនៅក្រៅសាលា។

វគ្គបណ្ដុះបណ្ដាលនេះបានផ្ដល់ឱកាសច្រើនដល់លោកគ្រូអ្នកគ្រូស្វែងយល់អំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យកុមារ និងយុវជនងាយរងគ្រោះ និងជាឧបករណ៍យកទៅរៀបចំផែនការអនុវត្តនៅតាមសាលារៀងៗខ្លួនដើម្បីជួយសិស្សដែលងាយប្រឈមនឹងការបោះបង់ការសិក្សា បានទទួលការគាំទ្រពីសាលារៀនក្នុងការអនុវត្តការងារឱ្យកាន់តែប្រសើរឡើងតាមរយៈការអន្តរាគមន៍នានាពីគម្រោង។ វគ្គបណ្ដុះបណ្ដាលនេះជាសកម្មភាពពង្រឹងសមត្ថភាពលោកគ្រូអ្នកគ្រូឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការងារអប់រំកុមារ និងយុវជននៅតំបន់គោលដៅឆ្នេរសមុទ្រក្នុងខេត្តកំពត និងខេត្តកែប៕



លោកគ្រូអ្នកគ្រូសរុបចំនួន៦៥នាក់ដែលមកពីសាលារៀនគោលដៅចំនួន៤៦ក្នុងខេត្តកំពតកំពុងចូលរួមក្នុងវគ្គបណ្ដុះបណ្ដាល។

# អនុវិស័យទី ៤

# កម្មវិធីអប់រំបរិយាប័ន្ន

"ភាពចម្រុះ និងការអប់រំបរិយាប័ន្នផ្ដល់តម្លៃដល់មនុស្សគ្រប់រូប
មិនថាយើងមានភាពគ្នាយ៉ាងណាក៏ដោយ"។

## Inclusive Education

"Diversity and Inclusion are about giving value to every human being, no matter our differences."



# ការផ្លាស់ប្តូររបៀបដឹកនាំជាវិជ្ជមានរបស់លោកនាយក និងគណៈកម្មការគ្រប់គ្រងសាលារៀន



*បរិស្ថាន និងបរិវេណសាលារៀនមានភាពទាក់ទាញបន្ទាប់ពីទទួលបានការគាំទ្រពីគម្រោង*

សាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កន្ទួត ស្ថិតនៅក្នុងភូមិកន្ទួត ឃុំរំចេក ស្រុកមេមត់ មានចម្ងាយ៦៥គីឡូម៉ែត្រពីទីរួមខេត្តត្បូងឃ្មុំ និងមានចម្ងាយ៣៩គីឡូម៉ែត្រពីការិយាល័យអប់រំ យុវជន និងកីឡាស្រុកមេមត់។ សាលានេះមានភូមិចំណុះចំនួន៤ រួមមាន៖ ភូមិកន្ទួត ភូមិខ្ទប ភូមិញ៉ៅ និងភូមិសែនផល ដែលមានប្រជាជនសរុបចំនួន ២,៨២១នាក់ និងមានគ្រួសារចំនួន៩២២ ដែលភាគច្រើនបំផុតជាកសិករ ហើយមានអ្នកចំណាកស្រុក ៥% និងគ្រួសារក្រីក្រ ៨%។

សាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កន្ទួត ត្រូវបានកសាងឡើងនៅក្នុងឆ្នាំ១៩៩៧ មានអគារមួយខ្នង៦បន្ទប់ ហើយបានដំណើរការរហូតដល់ឆ្នាំ២០១៤ មានកំណើនសិស្សកើនឡើងជាបន្តបន្ទាប់។ ដោយមើលឃើញការលំបាកបែបនេះ ក៏មានសប្បុរសជនជប៉ុនបានផ្តល់ជំនួយថវិកាមកកសាងអគារមួយខ្នងមានពីរបន្ទប់បន្ថែមទៀត។

ស្ថានភាពនៅមុនពេលគម្រោងកុមារកម្ពុជារីករាយ (HCC) ចូលមកអន្តរាគមន៍សាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កន្ទួត បានជួបប្រទះបញ្ហាប្រឈមច្រើន ដូចជា ខ្វះអគារសិក្សា ពិសេសថ្នាក់មត្តេយ្យសិក្សា អគារសិក្សាពេលនោះមានលក្ខណៈទ្រុឌទ្រោម ធ្លុះធ្លាយ ខ្វះហេដ្ឋារចនាសម្ព័ន្ធ បង្គន់ចាស់ពិបាកប្រើប្រាស់ ខ្វះសម្ភារៈប្រើប្រាស់ ដូចជា តុ ក្តារខៀន កៅអី។ សាលារៀនមិនអាចដោះស្រាយបញ្ហាទាំងអស់នោះបានទេ ដោយសារលើសពីលទ្ធភាពដែលសាលាមាន ទោះបីជាលោក សន គង់ ជានាយកសាលានេះបានខិតខំខ្នះខ្នែងស្វែងការគាំទ្រពីថ្នាក់ដឹកនាំមន្ទីរ/ការិយាល័យអប់រំខាងលើ ប៉ុន្តែលទ្ធផលឆ្លើយតបនៅតែឃឹតយ៉ាវ។ ទំហំថវិកាសាងសង់នេះធំធេងពេក ទើបសប្បុរជននៅក្នុងសហគមន៍មិនអាចមានលទ្ធភាពនិងសមត្ថភាពជួយដោះស្រាយបាន។

ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពសាលារៀនត្រូវបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សបន្ទាប់ពីមានអន្តរាគមន៍របស់គម្រោងកុមារកម្ពុជារីករាយចាប់តាំងពីឆ្នាំ២០១៩មក។ លោក សន គង់ បានមានប្រសាសន៍ថា *“វាជារឿងមួយមិនងាយស្រួលឡើយដើម្បីស្វែងរកការគាំទ្រពីម្ចាស់ជំនួយខាងក្រៅ ព្រោះយើងត្រូវប្តេជ្ញាចិត្តខ្ពស់លះបង់ពេលវេលា ទាំងកំលាំងកាយនិងកំលាំងចិត្តចំពោះការងារដឹកនាំអភិវឌ្ឍន៍សាលារៀន។ យើងត្រូវមានទំនាក់ទំនងល្អជាមួយអាជ្ញាធរ និងភាគីពាក់ព័ន្ធទាំងអស់។ បច្ចុប្បន្ននេះ ខ្ញុំពិតជាមានការសប្បាយចិត្តយ៉ាងខ្លាំងចំពោះការជួយរបស់គម្រោង HCC ព្រោះបានធ្វើឱ្យសាលារៀនរបស់ខ្ញុំមានការផ្លាស់ប្តូរមុខមាត់ ដូចជា ការជួសជុលអគារសិក្សាចាស់ៗចំនួនពីរខ្នងមាន ៨បន្ទាប់ កសាងអគារសិក្សាថ្នាក់មត្តេយ្យថ្មី ១ខ្នងមាន២បន្ទប់ និងបង្គន់អនាម័យ១ខ្នងមាន ២បន្ទប់ ជួសជុលតុ* (**អានបន្តទំព័រ ២៤...**)



*លោក សន គង់ នាយកសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កន្ទួត*

( ...តពីទំព័រ២៣ ) *កៅអី ជាពិសេសការផ្តល់សម្ភារៈសិក្សាបន្ថែម។ ក្រៅពីនេះគម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងដឹកនាំសាលារៀនដល់សាលាខ្ញុំផងដែរ ដែលខ្ញុំទទួលបានបទពិសោធន៍ថ្មីបន្ថែម និងបានផ្លាស់ប្តូរឥរិយាបថគ្រប់គ្រង និងដឹកនាំសាលារៀន ជាពិសេសការងារប្រថុយប្រថានជួយកុមារ។ គម្រោងបានជួយកែលម្អហេដ្ឋារចនាសម្ព័ន្ធ រៀបចំផ្ទាំងរូបចម្លាក់សត្វ រៀបចំសកម្មភាពរៀនរបស់កុមារតាមតម្រូវការ និងកៀរគរធនធានពីមូលដ្ឋាន។ សាលាខ្ញុំបានបញ្ចប់ការកសាងរបងសាលារៀនប្រវែង១០៥ ម៉ែត្រ ដោយមានការចូលរួមពីសហគមន៍អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធយ៉ាងផុសផុល”*។

គម្រោងកុមារកម្ពុជារីករាយ ឬហៅកាត់ថា HCC បានជួយបណ្តុះបណ្តាលសមត្ថភាពគ្រូបង្រៀន ទាំងគ្រូក្របខណ្ឌ និងគ្រូកិច្ចសន្យាតាមរយៈសិក្ខាសាលាខ្លីៗ និងវែងក្នុងគោលបំណងកសាងធនធានមនុស្សឱ្យរឹងមាំ ធ្វើយ៉ាងណាឱ្យលោកគ្រូអ្នកគ្រូមានសមត្ថភាពគ្រប់គ្រាន់សម្រាប់បង្រៀនសិស្សប្រកបដោយភាពច្នៃប្រឌិតថ្មីៗ។ គម្រោងបានជួយអភិវឌ្ឍសាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កន្ទួតបន្ថែមទៀតលើការតុបតែងថ្នាក់រៀន បច្ចេកទេសផលិតសម្ភារៈសិក្សា ការធ្វើតេស្តអំណាន ការអនុវត្តមុខងារប្រកបដោយវិជ្ជាជីវៈ និងមានការផ្លាស់ប្តូរឥរិយាបថបង្រៀនសិស្សបែបវិជ្ជមាន។

នៅពេលបច្ចុប្បន្ននេះ លោកគ្រូអ្នកគ្រូបានមកបង្រៀនទៀងទាត់ពេលវេលា មានសមត្ថភាពគ្នាល្អ ធ្វើឱ្យសិស្សមានភាពរីករាយក្នុងការសិក្សា និងមកសាលារៀនជាប់លាប់។ បរិស្ថានសាលាមានការរៀបចំដោយភាពច្នៃប្រឌិត និងទាក់ទាញសិស្ស ជាពិសេសសហគមន៍បានចាប់អារម្មណ៍យកចិត្តទុកដាក់យ៉ាងផុសផុលចូលរួមការងារអភិវឌ្ឍសាលារៀន គឺខុសប្លែកច្រើនជាងកាលពីមុនដែលពួកគាត់មិនសូវចាប់អារម្មណ៍ការងារសាលា។ ការបង្ហាញសមិទ្ធផលអភិវឌ្ឍន៍សាលារៀនរបស់គណៈគ្រប់គ្រងដល់ឪពុកម្តាយសិស្ស អាជ្ញាធរ និងសហគមន៍ បានជំរុញឱ្យមាតាបិតាតាមដានការសិក្សារបស់កូន។ សាលា



ច្រកចូលទៅកាន់សាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កន្ទួត



*លោក ទួន យុនឡេង ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន សាលាបឋមសិក្សា កន្ទួត*

រៀនមានការប្រែប្រួលទាំងបរិស្ថាន គុណភាពអប់រំ និងឥរិយាបថសិស្ស។

លោក **ទួន យុនឡេង** ប្រធានគណៈកម្មការគ្រប់គ្រងសាលារៀន បានមានប្រសាសន៍ថា ***“ខ្ញុំមានសេចក្តីរំភើបដែលមានគម្រោងកុមារកម្ពុជារីករាយចូលមកជួយអភិវឌ្ឍសាលារបស់ខ្ញុំ។ គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលអំពីតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រងសាលារៀន របៀបរៀបចំបោះឆ្នោត ជាពិសេសការផ្សព្វផ្សាយព័ត៌មានអំពីការសិក្សាកូន និងការងារសាលាដល់ឪពុកម្តាយសិស្ស និងទទួលព័ត៌មានត្រឡប់ពីពួកគាត់វិញ។ ខ្ញុំបានយល់ដឹងអំពីសារៈសំខាន់នៃការអប់រំកុមារខ្លាំងជាងមុន និងរួមសហការយ៉ាងស្អិតរមួតជាមួយនាយក និងអាជ្ញាអរមូលដ្ឋាន តាមដានការបង្រៀនរបស់លោកគ្រូអ្នកគ្រូ និងការសិក្សារបស់សិស្ស។ ខ្ញុំសូមឱ្យគម្រោង HCC ផ្តល់សម្ភារៈសិក្សា វគ្គបណ្តុះបណ្តាលផ្សេងៗ និងបន្តជួយសាលារៀនយើងខ្ញុំបន្តទៀត”***។

ចំណែកមត្តេយ្យសិក្សាវិញ លោកនាយក និងគណៈកម្មការទ្រទ្រង់សាលារៀនបានដឹកនាំប្រជុំជាមួយមាតាបិតាសិស្សទៀងទាត់ ដើម្បីផ្សព្វផ្សាយសកម្មភាពសាលារៀន និងលទ្ធផលសិក្សារបស់សិស្ស។ ទោះបីអាក់ខានការប្រជុំនេះដោយសារការរីករាលដាលជំងឺកូវីដ-១៩ក៏ដោយ ក៏លោកនាយកបានប្រើប្រាស់ប្រព័ន្ធអនឡាញដើម្បីឱ្យគ្រូបង្រៀនសិស្ស ផ្តល់ព័ត៌មាន និងទំនាក់ទំនងជាមួយឪពុកម្តាយ និងសហគមន៍ផងដែរ។

ក្រោមការដឹកនាំរបស់លោក សន គង់ និងជំនួយបច្ចេកទេសពីគម្រោង HCC សាលាបឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កន្ទួត បានផ្លាស់ប្តូរមុខមាត់ គ្រូបង្រៀនសិស្សមានលក្ខណៈច្នៃប្រឌិត បរិស្ថានស្អាត មានសម្ភារៈបង្រៀនច្រើនប្រភេទ មានអគារសិក្សាគ្រប់គ្រាន់ មានការប្រជុំផ្សព្វផ្សាយដល់អាណាព្យាបាល និងឪពុកម្តាយសិស្សទូលំទូលាយ មានកិច្ចសហការពីអ្នកពាក់ព័ន្ធ អាជ្ញាធរ និងលោកគ្រូអ្នកគ្រូទាំងអស់។

សាលារៀននេះរីកចម្រើនដោយសារការមានឆន្ទៈដ៏រឹងមាំ និងមានទស្សនវិស័យច្បាស់លាស់របស់ថ្នាក់ដឹកនាំសាលា និងលោកគ្រូអ្នកគ្រូ បានធ្វើឱ្យកុមារក្នុងមូលដ្ឋានទទួលបានការអប់រំប្រកបដោយគុណភាព ៕

# ការពិគ្រោះយោបល់ពីការវាយតម្លៃគ្រូកិច្ចសន្យាតាមតំបន់គោលដៅ

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ គម្រោងកុមារកម្ពុជារីករាយបានរៀបចំកម្មវិធីប្រជុំស្តីពី"**ការពិគ្រោះយោបល់លើការវាយតម្លៃគ្រូកិច្ចសន្យា**" ធ្វើឡើងតាមរយៈប្រព័ន្ធអនឡាញ(Zoom)។ សមាសភាពអ្នកចូលរួមការប្រជុំសរុបចំនួន៨០នាក់ រួមមាន៖ ប្រធាន/អនុប្រធានមន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡាខេត្ត-ស្រុក ប្រធានមន្ទីរទទួលបន្ទុកការងារបឋមសិក្សា ប្រធានការិយាល័យបឋមសិក្សា ប្រធានការិយាល័យបុគ្គលិក ប្រធានការិយាល័យអធិការកិច្ចនៃមន្ទីរអប់រំ យុវជន និងកីឡាស្រុក។

កិច្ចប្រជុំនេះមានគោលបំណង៖

១.បង្ហាញសមិទ្ធផលគម្រោងកុមារកម្ពុជារីករាយ រយៈពេលបីឆ្នាំកន្លងមក

២.បង្ហាញយន្តការ និងយុទ្ធសាស្ត្រការគាំទ្រគ្រូកិច្ចសន្យារបស់គម្រោង

៣.ពិគ្រោះយោបល់លើការងារវាយតម្លៃគ្រូកិច្ចសន្យា និងការលើកទឹកចិត្ត។

លោក អឿន បូរ៉ា ប្រធានគម្រោងកុមារកម្ពុជារីករាយបានមានប្រសាសន៍ *"គម្រោងបានគាំទ្រសកម្មភាពសាលារៀនចំនួន៤១ ក្នុងខេត្តចំនួន៥ ដើម្បីអភិវឌ្ឍគំរូកម្មវិធីសាលាកុមារមេត្រី និងផ្តោតលើគុណភាពអប់រំ ការអប់រំបញ្ចូលគ្នា និងការចូលរួមពីអ្នកពាក់ព័ន្ធរបស់សាលារៀន ដើម្បីធ្វើយ៉ាងណាជានាឱ្យបានការផ្លាស់ប្តូរយ៉ាងល្អនូវការសិក្សាពីកម្រិតសាលាមត្តេយ្យសិក្សាឆ្លងទៅសាលាបឋមសិក្សា។ គម្រោងបានធ្វើការពង្រឹងលទ្ធភាពនៃការទទួលបានសេវាការអប់រំ ពង្រឹងប្រសិទ្ធភាពនៃការបង្រៀននិងរៀន ពង្រឹងសកម្មភាពអំណានថ្នាក់ដំបូង កែលម្អសមត្ថភាពអ្នកគ្រប់គ្រងសាលារៀន និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ"*។



លោក អឿន បូរ៉ា

សមិទ្ធិផលសំខាន់ៗរបស់គម្រោងរួមមាន៖ ១) ផ្តល់វគ្គសិក្ខាសាលាបណ្តុះបណ្តាល និងបំប៉នពង្រឹងសមត្ថភាពបង្រៀន និងរៀនដល់គ្រូក្របខ័ណ្ឌ គ្រូកិច្ចសន្យ ព្រមទាំងបណ្ណារក្សទទួលបានចំណេះដឹងទាក់ទងនឹងការគ្រប់គ្រងបណ្ណាល័យ ជាពិសេស នាយកសាលា និងគណៈកម្មការគ្រប់គ្រងសាលាមានការផ្លាស់ប្តូររបៀបនៃការគ្រប់គ្រង និងដឹកនាំកិច្ចការងារនៅក្នុងសាលារៀន។ ២) ផ្នែកសម្ភារៈរៀន និងបង្រៀន គម្រោងបានផ្តល់ហិបអំណានភាសាខ្មែរ និងគណិត តេស្តអំណាន សៀវភៅអាន សម្ភារបង្រៀននិងរៀន ព្រមទាំងថាប់ភ្លែត។ ៣)ផ្នែកសំណង់គម្រោងបានជួសជុលអគារសិក្សាចាស់ អគារឈើ និងបង្គន់។ ៤) ផ្នែកហេដ្ឋារចនាសម្ព័ន្ធ គម្រោងបានជួលជុលអគារ រួមមាន៖ លាបថ្នាំ រៀបចំការ៉ូ ពិដាន ទ្វា បង្អួច ផ្តល់ និងជួសជុលតុ។ ៥) ផ្នែកសង្ហារឹមសាលារៀន រួមមានៈ ផ្តល់ក្តារខៀនថ្មី ឧបករណ៍ចម្រុះទឹកស្អាត កន្លែងលាងដៃ និងធ្វើដាក់ស្បែកជើង និង ៦) ការអភិវឌ្ឍបណ្ណាល័យ គម្រោងបានរៀបចំ និងកែលម្អបណ្ណាល័យដែលគាំទ្រសកម្មភាពអានរបស់កុមារយ៉ាងសកម្ម។



សកម្មភាពបណ្តុះបណ្តាលលោកគ្រូអ្នកគ្រូពីរបៀបសម្ភារៈសិក្សាក្នុងការបង្រៀន និងរៀន។

ទន្ទឹមនឹងនោះ គម្រោងក៏មានសកម្មភាពបន្ថែមដល់សាលា ដូចជា ១) បំប៉នគ្រូពីដំណើរការនៃប្រព័ន្ធឆ្លើយតបរហ័ស តាមរយៈការប្រើប្រាស់សៀវភៅស្តង់ដាអំណានរបស់ក្រសួងអប់រំ យុវជន និងកីឡា និងការជំរុញលើកទឹកចិត្តឱ្យគ្រូៗរៀបចំធ្វើតេស្តដំណាក់។ ២)រៀបចំធ្វើតេស្តវាយតម្លៃអំណានថ្នាក់ដំបូង (EGRA) សម្រាប់ជាទិន្នន័យមូលដ្ឋាន ដើមគ្រា និងចុងគ្រា ដើម្បីធ្វើការប្រៀបធៀបពីសាលាអនុវត្តគម្រោងទៅនឹងសាលាប្រៀបធៀបអំពីប្រសិទ្ធភាពអំណាន។ ៣) ប្រជុំជាមួយមាតាបិតាសិស្ស ដើម្បីឱ្យពួកគាត់ចូលរួមជួយបង្រៀនកូនៗរបស់គាត់នៅផ្ទះ។ ៤) ផ្តល់សម្ភារឧបទេសនិងល្បែងស្វ័យសិក្សាពង្រឹងអំណាន ដើម្បីដំណើរការប្រព័ន្ធឆ្លើយតបរហ័សឱ្យបានល្អ។ ៥)បង្កើតឱ្យមានកម្មវិធីកុមារជួយកុមារ ដែលអាចឱ្យកុមារដែលមានតម្រូវការរៀនបន្ថែម(រៀនយឺត) បានរៀនសូត្របន្ថែមពីមិត្តភក្តិ។ ៦) បំប៉នគ្រូកុមារមេត្រីលើវិធីសាស្ត្រឆ្លើយតមតាមតម្រូវការនិងសមត្ថភាពសិស្ស។ ៧) បំប៉នសមត្ថភាពអ្នកពាក់ពន្ធ័ គណៈគ្រប់គ្រងសាលារៀន សហគមន៍ អាណាព្យាបាលសិស្ស និងរៀបចំកម្មវិធីបំណិនជីវិត។

គម្រោងកុមារកម្ពុជារីករាយបានខិតខំប្រឹងប្រែងពង្រឹងគុណវុឌ្ឍន៍គ្រូក្របខ័ណ្ឌ គ្រូកិច្ចសន្យា នាយក នាយករង គណៈកម្មការគ្រប់គ្រងសាលា និងអ្នកពាក់ព័ន្ធទាំងអស់នៅតាមសាលារៀន (អានបន្តទំព័រ ២៦...)

# សិស្សក្រីក្រទទួលបានការយកចិត្តទុកដាក់គាំទ្រពីគម្រោង SEEK

កាលពីថ្ងៃទី២៥ ដល់ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១ គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា(SEEK) បានរៀបចំកម្មវិធី **"ចែកអាហារូបករណ៍ដល់សិស្សក្រីក្រ"** នៅសាលារៀនគោលដៅចំនួន១០ក្នុងខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំដោយមានសិស្សអាហារូបករណ៍ចំនួន១៥០នាក់។

កម្មវិធីនេះមានគោលបំណងផ្ដល់ឱ្យសិស្សអាហារូបករណ៍ទទួលបាននូវៈ **១**-ចំណេះដឹងស្ដីពីកម្មវិធីបំណិនជីវិតមុខរបរខ្នាតតូច និងរបៀបគ្រប់គ្រងថវិកា។ **២**-វិធីសាស្ត្រ និងគោលការណ៍ទូទៅ ព្រមទាំងបច្ចេកទេសទាក់ទងមុខរបរខ្នាតតូចជាលក្ខណៈគ្រួសារ ធ្វើយ៉ាងណាឱ្យពួកគាត់ទទួលចំណេះដឹងកាន់តែច្បាស់លាស់ និង **៣**-ថវិកាសម្រាប់ដំណើរការមុខរបរខ្នាតតូច។

កម្មវិធីនេះបានជំរុញលើកទឹកឪពុកម្ដាយយល់ដឹងច្រើនអំពីសារៈប្រយោជន៍នៃការសិក្សារបស់កូនៗ ជាពិសេសការបង្កប់នូវគោលគំនិតកម្មវិធីលើកកម្ពស់ការអប់រំធនធានមនុស្ស ធ្វើឱ្យពួកគាត់ប្ដេជ្ញាចិត្តបញ្ជូនកូនទៅសិក្សា។ គម្រោងស៊ីកបង្កើតឡើងក្នុងគោលបំណងដើម្បីបំពេញនូវសិទ្ធិសេដ្ឋកិច្ច និងសង្គមរបស់យុវជន ពិសេសការយកចិត្តទុកដាក់ទៅលើស្ត្រីមកពីសហគមន៍ជនជាតិចាមតាមរយៈទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាប័ន្ន ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការងារដែលសមរម្យ។

ជាលទ្ធផល ឪពុកម្ដាយ និងអាណាព្យាបាលសិស្សដែលបានចូលរួមនៅក្នុងកម្មវិធីចែកអាហារូបករណ៍មានការយល់ដឹងច្រើនអំពីកម្មវិធីបំណិនជីវិត ដូចជា ការចិញ្ចឹមមាន់ ចិញ្ចឹមត្រី និងការដាំបន្លែជាលក្ខណៈគ្រួសារ ដើម្បីកាត់បន្ថយការចំណាយ៕



*អាណាព្យាបាលសិស្សចូលរួមកម្មវិធីចែកអាហារូបករណ៍ និងបានយល់ដឹងពីមុខរបរខ្នាតតូចលក្ខណៈគ្រួសារនៅវិទ្យាល័យហ៊ុន សែនពញាក្រែក*

( ...តពីទំព័រ ២៥ ) គោលដៅនីមួយៗក្នុងការកសាងធនធានមនុស្សឱ្យរឹងមាំ សមស្របទៅតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។ម្យ៉ាងវិញទៀត គម្រោងមានផែនការពង្រីកសាលារៀនគោលដៅបន្ថែមជាច្រើនទៀតនៅពេលខាងមុខនេះ។ នៅពេលណាគណៈគ្រប់គ្រងសាលារៀន លោកគ្រូ និងអ្នកពាក់ព័ន្ធមានសមត្ថភាពខ្លាំង នោះសាលារៀននឹងវិវត្តទៅតាមនោះដែរ៕



*សិស្សានុសិស្សចូលលេងល្បែងសិក្សានៅក្នុងបណ្ណាល័យនៅម៉ោងចេញ។*

# ដំណើរទស្សនកិច្ចម្ចាស់ជំនួយគម្រោងស៊ីក/SEEK



*គណៈប្រតិភូបានទស្សនកិច្ចនៅអង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA ) ដែលជាអង្គការដៃគូរបស់ អង្គការ ខេប ស្ថិតក្នុងស្រុកកំពង់សៀមពីវឌ្ឍនភាពរបស់គម្រោង និងបញ្ហាប្រឈមនានាអំឡុងពេលរីករាលដាលនៃជំងឺកូវីដ-១៩។*

កាលពីថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១ គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (ស៊ីក/SEEK) ក្រោមជំនួយហិរញ្ញប្បទានពីសហភាពអឺរ៉ុប និងរួមសហប្រតិបត្តិដោយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA) អង្គការក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) និងអង្គារវីវើល (WeWorld) បានរៀបចំទទួលដំណើរទស្សនកិច្ចរបស់លោកស្រី Flora Bertizzolo លោកស្រី Vanicha Padmadevi និងលោក បូ នឿន ដែលជាគណៈប្រតិភូសហភាពអឺរ៉ុប ក្នុងគោលបំណងសិក្សាស្វែងយល់ និងជួបសំណេះសំណាលជាមួយក្រុមយុវជនគោលដៅគម្រោង ដែលទទួលបានការងារតាមរយៈការប្រឹក្សាអាជីពពីមណ្ឌលស៊ីក។ យុវជនទាំងនេះជាក្រុមជួយខ្លួនឯង ហើយបន្តផ្សព្វផ្សាយដល់យុវជនដទៃទៀតក្នុងសហគមន៍ ដើម្បីទទួលបានសេវាប្រឹក្សាអាជីព និងស្តាប់បទបង្ហាញពីអង្គការ BSDA ស្ថិតក្នុងស្រុកកំពង់សៀមអំពីវឌ្ឍនភាពរបស់គម្រោង និងបញ្ហាប្រឈមនានាអំឡុងពេលការឆ្លងរីករាលដាលជំងឺកូវីដ-១៩។

គណៈប្រតិបានជួបសំណេះសំណាលជាមួយសិស្ស លោកគ្រូអ្នកគ្រូ និងនាយកសាលារៀនបន្តទៀតក្នុងស្រុកជើងព្រៃ ដើម្បីស្វែងយល់អំពីការប្រឹក្សាអាជីព សិស្សអាហារូបករណ៍ក្រីក្រ ការបំប៉នសិស្សរៀនយឺត និងប្រព័ន្ធរំឭកទុកជាមុន ជាពិសេសការអន្តរាគមន៍ផ្សេងៗដល់សិស្សគោលដៅ។ សិស្សប្រមាណជា២០០នាក់ បានទទួលចំណេះដឹងពីការប្រឹក្សាអាជីពនៅវិទ្យាល័យកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន មានជ័យ ពិតជាត្រេកអរដែលមានកម្មវិធីប្រឹក្សាអាជីពនៅសាលារៀនរបស់ពួកគាត់។

ក្រៅពីការសិក្សាស្វែងអំពីការប្រតិបត្តិគម្រោង ស៊ីក/SEEK គណៈប្រតិភូក៏បានទៅទស្សនកិច្ចសាលារៀនជំនាន់ថ្មី វិទ្យាល័យពាមជីកង ដើម្បីសិក្សាស្វែងយល់អំពីនិន្នាការសិស្សទាក់ទងទៅនឹងការអប់រំចំណេះទូទៅ ឬបច្ចេកទេសនៅកម្រិតវិទ្យាល័យ។ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ថវិកា៦០ម៉ឺនរៀលសម្រាប់សិស្សម្នាក់ ដែលសិក្សាជំនាញបច្ចេកទេស។ ចំណែកសាលារៀនជំនាន់ថ្មី វិទ្យាល័យ ហ៊ុន សែន កំពង់ចាមវិញ ក៏បានបើកថ្នាក់អគ្គីសនី និងក្បេត្រសាស្រ្តសម្រាប់សិស្សសិក្សាផងដែរ។

ជាលទ្ធផលនៃដំណើរទស្សនកិច្ចនេះ គណៈប្រតិភូសហភាពអឺរ៉ុបបានទទួលព័ត៌មានជាច្រើនពីសកម្មភាពអនុវត្តគម្រោងរបស់អង្គការសហប្រតិបត្តិទាំង៤ និងបញ្ហាប្រឈមផ្សេងៗដែលកំពុងកើតមានក្នុងអំឡុងពេលជំងឺកូវីដ-១៩៕



អនុវិស័យទី

៥

# កម្មវិធីអំណានថ្នាក់ដំបូង

“នៅពេលអ្នករៀនអាន អ្នកនឹងមានសេរីភាពរហូត”។

## Early Grade Reading

"Once you learn to read, you will be forever free."

# ហេតុអ្វីសាលាគោលដៅរបស់គម្រោងត្រូវធ្វើតេស្តដំណាក់កាល ?




តេស្តដំណាក់កាលទី៥ នៅសាលាបឋមសិក្សា ហ៊ុន សែន ក្រូចឆ្មារ តាមរយៈថាប់ភ្លែត។

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRAC III) គឺបង្កើតឡើងក្នុងគោលបំណងបង្កើនកម្រិតនៃការអាន និងសរសេរសម្រាប់កុមារថ្នាក់ទី១ ទី២ និងថ្នាក់ទី៣ ដោយរៀបចំឱ្យមានការវាយតម្លៃយ៉ាងទៀងទាត់ជាមួយប្រព័ន្ធឆ្លើយតបរហ័ស ព្រមទាំងពង្រឹងការចូលរួមពីឪពុកម្តាយក្នុងការជួយបង្រៀនសិស្ស។ ការធ្វើតេស្តដំណាក់កាលគឺជាសូចនាករដ៏សំខាន់មួយរបស់គម្រោងដើម្បីជួយអន្តរាគមន៍អំណានថ្នាក់ដំបូងដល់សិស្សានុសិស្សនៅតាមសាលារៀនគោលដៅនីមួយៗ។

តេស្តដំណាក់កាលចាប់ផ្តើមនៅពេលដែលសិស្សចូលរៀនបានរយៈពេលមួយខែ លោកគ្រូអ្នកគ្រូត្រូវចាប់ផ្តើមធ្វើតេស្តដំណាក់កាលទី១ និងបន្តបន្ទាប់រហូតដំណាក់កាលទី៩ ក្នុងរយៈពេលមួយឆ្នាំសិក្សាពេញ។ ការធ្វើតេស្តនេះឡើង ដើម្បីដឹងពីសមត្ថភាពអានរបស់សិស្ស និងមានយន្តការជួយពួកគាត់ភ្លាមៗ ក្នុងករណីពួកគេធ្លាក់តេស្តដំណាក់កាល លោកគ្រូអ្នកគ្រូនឹងជួយបង្រៀនបំប៉នបន្ថែមសិស្សដែលរៀនយឺត (៤សប្តាហ៍) រហូតដល់ការធ្វើតេស្តដំណាក់កាលបន្ទាប់។

ក្នុងឆ្នាំ២០២១ ការធ្វើតេស្តដំណាក់កាលនៅតាមសាលារៀនគោលដៅនីមួយៗ ទទួលបានលទ្ធផលមិនល្អប្រសើរឡើយ ដោយសារតែការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឱ្យសិស្សានុសិស្សមួយចំនួនធំ មិនទទួលបានការអប់រំពេញលេញ ជាហេតុធ្វើឱ្យការសិក្សារបស់សិស្សមានការធ្លាក់ចុះយ៉ាងខ្លាំង។

ទោះបីជាយ៉ាងណាក៏ដោយ គម្រោងនៅតែបន្តជួយគាំទ្រសកម្មភាពសាលារៀនដោយជំរុញឱ្យសិស្សការប្រើប្រាស់កម្មវិធីអេឡិចត្រូនិត (M-learning) របស់អង្គការ ខេប ដើម្បីលើកកម្ពស់ការអានរបស់ពួកគេ៕

**លទ្ធផលតេស្តដំណាក់កាលតាមគម្រោង**




ដ្យាក្រាមបង្ហាញពីលទ្ធផលតេស្តដំណាក់កាលនីមួយៗ



អនុវិស័យទី

៦

# កម្មវិធីមត្តេយ្យសិក្សា

“បង្កើនគំនិតមួយសម្រាប់កុមារមួយនាក់ក្នុងពេលតែមួយ”។



# Preschool Programming

*"Enriching the mind one child at a time."*

# ការលេងល្បែងសិក្សា និងការផលិតសម្ភារៈបង្រៀន និងរៀន

គម្រោងវិធីសាស្ត្រសរុបដើម្បីពង្រឹងអំណានសម្រាប់កុមារ (ត្រាក់៣/TRAC III) បានរៀបចំសិក្ខាសាលាស្តីពី **ការលេងល្បែងសិក្សា និងការផលិតសម្ភារៈបង្រៀន និងរៀន** សម្រាប់មត្តេយ្យសិក្សា ដែលបានប្រព្រឹត្តទៅឡើងនៅក្នុងថ្ងៃទី២៧ ដល់ទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ក្នុងក្រុងកំពង់ចាម។ សមាសភាពអ្នកចូលរួមសរុបចំនួន៩នាក់ រួមមាន៖ មន្ត្រីជំនាញការិយាល័យអប់រំកុមារតូចនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម-ត្បូងឃ្មុំ និងអ្នកគ្រូមត្តេយ្យសិក្សា។

សិក្ខាសាលានេះ មានគោលបំណងផ្តល់ឱ្យអ្នកចូលរួមបានយល់ដឹងពីការប្រើប្រាស់ល្បែងសិក្សា និងដឹងពីរបៀបផលិតសម្ភារៈឧបទេសសម្រាប់បង្រៀន និងរៀន។

អ្នកស្រី វ៉េង សុភាព ជាអនុប្រធានការិយាល័យអប់រំកុមារតូចនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តត្បូងឃ្មុំបានមានប្រសាសន៍ថា *"ការផលិត និងប្រើប្រាស់សម្ភារឧបទេសនេះពិតជាសំខាន់សម្រាប់អ្នកគ្រូៗក្នុងការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព។ សិក្ខាសាលានេះបានផ្តល់ចំណេះដឹងល្អៗដល់អ្នកគ្រូឱ្យចេះផលិតសម្ភារៈថ្មីៗ ចេះពីវិធីលេងសម្ភារៈសិក្សា និងទទួលបានបទពិសោធន៍បង្រៀនល្អៗដែលអ្នកគ្រូបានចែករំលែកឱ្យគ្នាទៅវិញទៅមកសម្រាប់យកមកអនុវត្តក្នុងថ្នាក់ជាក់ស្តែងឱ្យកាន់តែល្អប្រសើរឡើង"*។

គម្រោងត្រាក់៣មានសកម្មភាពសំខាន់ៗ ដូចជា ១-បំប៉នគ្រូពីដំណើរការនៃប្រព័ន្ធឆ្លើយតបរហ័ស និងការប្រើប្រាស់សៀវភៅស្តង់ដាអំណានរបស់ក្រសួង អប់រំ យុវជន និងកីឡា ណែនាំឱ្យគ្រូៗរៀបចំធ្វើតេស្តដំណាក់។ ២-រៀបចំធ្វើតេស្ត EGRA សម្រាប់ជាទិន្នន័យមូលដ្ឋានដើមគ្រា និងចុងគ្រា។ ៣-ប្រជុំជាមួយមាតាបិតាសិស្សដើម្បីឱ្យពួកគាត់ជួយបង្រៀនកូនៗរបស់គាត់នៅផ្ទះ។ ៤-ផ្តល់សម្ភារល្បែងសិក្សាដល់សាលារៀនគោលដៅដើម្បីពង្រឹងអំណាន។ ៥-បង្កើតឱ្យមានកម្មវិធីកុមារជួយកុមារ ដែលអាចឱ្យកុមាររៀនយឺតបានរៀនសូត្រពីមិត្តភក្តិ។ ៦-ផ្តល់ Tablets ដាក់ក្នុងបណ្ណាល័យ ដើម្បីផ្តល់ឱ្យកុមារលេងតាមកម្មវិធីអេឡិចត្រូនិក។ ៧-រៀបចំបង្កើតបណ្ណាល័យសតវត្សទី២១ ដែលគាំទ្រសកម្មភាពអានរបស់កុមារយ៉ាងសកម្ម។

ជាសន្និដ្ឋានចុងក្រោយ អ្នកគ្រូមត្តេយ្យសិក្សាបានចេះផលិតសម្ភារឧបទេស និងដឹងពីរបៀបប្រើប្រាស់ល្បែងសិក្សាក្នុងមុខវិជ្ជាទាំង៥របស់មត្តេយ្យសិក្សា ដូចជា គណិតវិទ្យា សិក្សាសង្គម ភាសាខ្មែរ ចលនាភាព និងវិទ្យាសាស្ត្រក៏ដូចជាបានរៀបចំផែនការប្រចាំឆ្នាំសម្រាប់បង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព និងមានគុណភាព។ ការពង្រឹងសមត្ថភាពគ្រូបង្រៀនគឺឧបករណ៍សម្រាប់បង្កើនការអប់រំកុមារឱ្យកាន់តែរីកចម្រើនថែមទៀត៕



សកម្មភាពអ្នកគ្រូកំពុងផលិតសម្ភារៈឧបទេសសម្រាប់ពង្រឹងដល់ការបង្រៀន និងរៀននៅថ្នាក់មត្តេយ្យសិក្សា។

អនុវិស័យទី

# ៧

# រចនាបថ ហេដ្ឋារចនាសម្ព័ន្ធ

"ធ្វើឱ្យទម្រង់ការអប់រំស្របតាមតម្រូវការ និងដើរតួនាទីថ្មីៗ"។

## Infrastructure Design

"Making educational forms that follow new needs and functions."



# ការរៀបចំបន្ទប់សម្រាប់ដំណើរការបណ្ណាល័យបែបសតវត្សរ៍ទី២១



*មន្ត្រីគម្រោងចុះពិនិត្យមើលការជួសជុលអាគារសិក្សាធ្វើជាបណ្ណាល័យសតវត្សរ៍ទី២១ នៅសាលាបឋមសិក្សាខ្លុងពពក ខេត្តកំពង់ឆ្នាំង។*

គម្រោងបង្កើនភាពងាយស្រួលចូលសាលារៀនតាមរយៈការគាំទ្រពីសហគមន៍ (រីក/REACH IV) បានជួសជុលបណ្ណាល័យដល់សាលារៀនគោលដៅចំនួន៣ ដូចជាសាលាបឋមសិក្សាខ្លុងពពក សាលាបឋមសិក្សាឯកលីផល និងសាលាបឋមសិក្សាស្នាមព្រះ ក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ដោយចាប់ផ្ដើមជួសជុលចាប់ពីថ្ងៃទី៣០ ខែតុលា និងបញ្ចប់នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១។

សកម្មភាពកែលម្អបណ្ណាល័យធម្មតាទៅជាបណ្ណាល័យបែបសតវត្សរ៍ទី២១ គឺជាសកម្មភាពថ្មីមួយសម្រាប់គម្រោងរីកដើម្បីពង្រឹងអក្ខរកម្មរបស់កុមារដែលមានបរិស្ថានសិក្សាប្រកបដោយសុខុមាលភាពក្នុងការចូលរួមចំណែកលើកកម្ពស់ការអភិវឌ្ឍគុណភាពអប់រំ ដោយឈរលើគោលនយោបាយកម្មវិធីសាលាកុមារមេត្រី។

ក្រៅពីជួសជុលបណ្ណាល័យដល់សាលារៀន គម្រោងបានបន្តយកចិត្តទុកដាក់លើការលើកកម្ពស់ការចូលរៀន ដោយផ្ដោតសំខាន់លើការពង្រឹងជំនាញអាន ការពង្រឹងថ្នាក់មត្តេយ្យសិក្សា ការពង្រឹងការការពារកុមារ ការពង្រឹងបរិស្ថានសិក្សា និងការពង្រឹងការចូលរួមពីសហគមន៍។ ការពង្រឹងសកម្មភាពកម្មវិធីអប់រំតាមរយៈការកសាងអគារូបវន្តសម្រាប់ទ្រទ្រង់ដល់ដំណើរការលូតលាស់នៃអប់រំកុមារគឺជាយន្តការដ៏សំខាន់របស់គម្រោង៕ ***“សហគមន៍រឹងមាំកសាងបាននូវសាលារៀនដ៏រឹងមាំ!”***



*បណ្ណាល័យសតវត្សរ៍ទី២១នៅសាលាបឋមសិក្សាឯកលីផល*

អនុវិស័យទី

# ៨

# ការអភិវឌ្ឍបណ្ណាល័យ

"បណ្ណាល័យសាលារៀនៈ ជាសោរសម្រាប់អតីតកាល និង ជាទ្វារសម្រាប់អនាគត"។

## Library Development

*"The School Library: Key to the Past and Gateway to the Future."*





# ហេតុអ្វីបានជាត្រូវអភិវឌ្ឍបណ្ណាល័យបែបស្តង់ដាសតវត្សរ៍ទី២១

អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(ខេប) គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ ខេបមានគម្រោងចំនួន២០កំពុងអនុវត្តន៍សកម្មភាពរបស់ខ្លួននៅតាមសាលារៀនគោលដៅ ក្នុងនោះកម្មវិធីសាលារៀនជំនាន់ថ្មីមានការរីកចម្រើនលូតលាស់យ៉ាងខ្លាំងក្នុងការចូលរួមលើកកម្ពស់ការអប់រំដើម្បីដើរឱ្យទាន់សម័យឌីជីថល ដែលគាំទ្រហិរញ្ញប្បទានពីក្រសួងអប់រំ យុវជន និងកីឡា។

កម្មវិធីសាលារៀនជំនាន់ថ្មីគឺជាកំណែទម្រង់ការអប់រំថ្មី ស្វែងរកការបង្កើតគន្លងនៃការអភិវឌ្ឍថ្មីមួយនៅក្នុងប្រព័ន្ធអប់រំសាធារណៈដែលនឹងនាំទៅរកការបង្កើតសាលារៀនសាធារណៈស្វយ័ត ដែលទទួលការវិនិយោគខ្ពស់សមស្របទៅនឹងស្តង់ដាថ្មី ដែលមានគណនេយ្យភាព និងអភិបាលកិច្ច ក៏ដូចជាមានស្តង់ដាវិជ្ជាជីវៈសម្រាប់ការសិក្សាបបែបសតវត្សរ៍ទី២១។

ការអភិវឌ្ឍបណ្ណាល័យធម្មតាឱ្យក្លាយទៅជាបណ្ណាល័យសតវត្សរ៍ទី២១ ជាចំណុចស្នូលដ៏សំខាន់មួយរបស់កម្មវិធី។ បណ្ណាល័យសតវត្សរ៍ទី២១ដើរតួនាទីយ៉ាងសំខាន់ដើម្បីជួយជំរុញឱ្យសាលារៀនជំនាន់ថ្មីអាចបំពេញតាមសេចក្តីត្រូវការនៃការសិក្សាបែបឌីជីថលដូចខាងក្រោម៖ ១) ផ្តល់ជូននូវបរិយាកាសសិក្សាប្រកបដោយសុខុមាលភាព មានភាពទាក់ទាញដល់ការសិក្សាបែបស្រាវជ្រាវ រុករក និងសិក្សាពង្រីកបន្ថែម មិនមែនត្រឹមតែជាកន្លែងដែលសិស្សានុសិស្សមកអានសៀវភៅពីរបីក្បាលរៀងរាល់សប្តាហ៍នោះទេ។ ២) សម្ភារសៀវភៅសិក្សា ល្បែងសិក្សា និងសម្ភារសិក្សាសម្រាប់សិស្សក្នុងការរៀនសូត្រ និងជាប្រភពព័ត៌មានសម្រាប់ស្វែងយល់ព្រឹត្តការណ៍ដែលបានកើតឡើងជុំវិញពិភពលោក។ ៣) ផ្តល់ជូននូវបច្ចេកវិទ្យាទំនើបមានបំពាក់កុំព្យូទ័រ កុំព្យូទ័របន្ទះស្តើងដោយភ្ជាប់ជាមួយប្រព័ន្ធអ៊ីនធើណិត ដើម្បីពង្រឹងផ្នែកស្រាវជ្រាវ ជាពិសេសមានបរិវេណសម្របសម្រួលដល់ការអានសៀវភៅប្រកបដោយភាពច្នៃប្រឌិតខ្ពស់ក្នុងការទាក់ទាញសិស្សានុសិស្សចូលមកក្នុងបណ្ណាល័យពេលទំនេរពីការសិក្សា។ ៤) មានបរិក្ខាទំនើបៗបំពាក់ដោយម៉ាស៊ីនត្រជាក់ប្រកបដោយផាសុកភាព និងសោភ័ណភាព។

បណ្ណាល័យទំនើបបង្កើតឡើងមានរចនាសម្ព័ន្ធបណ្ណាល័យថ្មី ផ្តល់សេវាឌីជីថល និងមានបណ្ណារក្សប្រចាំការត្រឹមត្រូវ ដែលមានជំនាញក្នុងការគ្រប់គ្រងនិងផ្សារភ្ជាប់បណ្ណាល័យទៅនឹងសកម្មភាពទាំងឡាយដែលកើតឡើងនៅក្នុងថ្នាក់រៀនដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរនៃសេចក្តីត្រូវការក្នុងការបង្រៀន និងរៀនរវាងសិស្សនិងគ្រូ។ (អត្ថបទខាងលើដកស្រង់ចេញពីស្តង់ដាបណ្ណាល័យសតវស្សរ៍ទី២១) សម្រាប់ព័ត៌មានបន្ថែម សូមចុចលើតំណភ្ជាប់ខាងក្រោម៖ (http://www.kapekh.org/en/publications-media/26/) ដើម្បីទាញយកឯកសារ បណ្ណាល័យស្តង់ដាសតវត្សរ៍ទី២១ មើលសេចក្តីលម្អិតបន្ថែមទៀត៕




*សកម្មភាពកុមារនៅសាលាបឋមសិក្សាអង្គបានចូលក្នុងបណ្ណាល័យដើម្បីទស្សនារឿងនិទានកុមារតូចៗ។*


អនុវិស័យទី
៦
កម្មវិធីបំណិនជីវិត
និងប្រឹក្សាអាជីព
"បំណិនជីវិតទទួលបានអត្ថប្រយោជន៍ពីការអប់រំសកម្មភាពគ្រូបង្រៀន
មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកម្មវិធីសិក្សាឌីណាមិក"។
Life Skills Education & Career Counseling
"Life Skills benefit from proactive education, Qualified Instructors,
& Dynamic Curriculum.."

# តើយុវជនទទួលបានចំណេះអ្វីខ្លះពីវគ្គបណ្តុះបណ្តាលស្តីពី ផ្នត់គំនិតក្រិន ផ្នត់គំនិតអភិវឌ្ឍន៍ និងការនិយាយជាសាធារណៈ?

នៅថ្ងៃទី៤ ដល់ទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា (KYLA) បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ផ្នត់គំនិតក្រិន ផ្នត់គំនិតអភិវឌ្ឍន៍ និងការនិយាយជាសាធារណៈ ជូនដល់សិស្សវិទ្យាល័យគោលដៅចំនួន៦ រួមមាន៖ វិទ្យាល័យ ហ៊ុន សែន មានជ័យ វិទ្យាល័យប៊ុនរ៉ានី ហ៊ុន សែន មានជ័យ វិទ្យាល័យ ហ៊ុន សែន ពាមជីលាំង វិទ្យាល័យ តេជោ ហ៊ុន សែន កំពង់ទ្រាស វិទ្យាល័យ ហ៊ុន សែន ពញាក្រែក និង វិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន វាលតូច ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណងពង្រឹងការនិយាយជាសាធារណៈឱ្យបានល្អ និងបង្កើនចំណេះដឹងអំពីគំនិតក្រិន និងផ្នត់គំនិតអភិវឌ្ឍន៍ដើម្បីឆ្លុះបញ្ចាំងនូវការគិតរបស់សិស្ស។ អ្នកចូលរួមសរុបក្នុងវគ្គនេះមានលោកនាយក គ្រូទទួលបន្ទុកផ្នែកយុវជន សិស្ស និងសេនាធិការគម្រោងសរុបចំនួន៩១នាក់។

កញ្ញា ណែម សុខជាតិ ជាសិស្សថ្នាក់ទី ១០ 'B' នៃវិទ្យាល័យ ហ៊ុន សែន មានជ័យ បានបង្ហាញចំណាប់អារម្មណ៍ចំពោះវគ្គបណ្តុះបណ្តាលនេះថា ***“នាងខ្ញុំពិតជាពេញចិត្តនូវប្រធានបទស្តីពី គំនិតគ្រិន និងគំនិតអភិវឌ្ឍន៍នេះខ្លាំងមែន ព្រោះវាបានបង្រៀនឱ្យខ្ញុំមានចិត្តទូលាយ ចេះអត់ធន់ ឧស្សាហ៍ព្យាយាម យកចិត្តទុកដាក់ក្នុងការធ្វើអ្វីមួយ ជាពិសេសពង្រឹងការគិតតែម្តង”***។

វគ្គនេះត្រូវបានរៀបចំឡើងនៅសាលារៀនគោលដៅផ្ទាល់បន្ទាប់ពីក្រសួងអប់រំ យុវជន និងកីឡា បានប្រកាសបើកសាលារៀនឡើងវិញនៅថ្ងៃទី០១ ខែវិច្ឆិការ ឆ្នាំ២០២១។ ក្រោមការសម្របសម្រួលពីមន្ត្រីគម្រោងឃីឡា សេនាធិការចំនួនពីររូបបានបណ្តុះបណ្តាលដល់សិស្សស្ម័គ្រចិត្ត ដែលមិនបានចូលរួមវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញបានជោគជ័យ។ សិស្សស្ម័គ្រចិត្តទាំងអស់បានបង្ហាញនូវភាពរីករាយច្រើន បន្ទាប់ពីពួកគាត់ធ្វើការឆ្លុះបញ្ចាំងតាមរយៈតេស្តសំណេរ នូវអ្វីដែលបានសិក្សាពាក់ព័ន្ធនឹងផ្នត់គំនិតក្រិន ផ្នត់គំនិតអភិវឌ្ឍន៍ និងការនិយាយជាសាធារណៈនៅក្នុងថ្ងៃនេះបានបង្ហាញឱ្យឃើញយ៉ាងជាក់ស្តែងថា ពួកគាត់បានយល់ច្បាស់នូវពាក្យ “**ផ្នត់គំនិតក្រិន**” គឺជាគំនិតសាំញ៉ាំ និងមិនហ៊ានធ្វើអ្វីមួយដោយមោះមុត ហើយបានប្តូរទៅជាគំនិតវិជ្ជមាន ហ៊ានពិសោធន៍ធ្វើអ្វីដែលថ្មី ជាពិសេសផ្នត់គំនិតអភិវឌ្ឍន៍។ ន័យនេះគឺជំរុញពួកគាត់ប្តូរការគិតពីអវិជ្ជមានមកវិជ្ជមានវិញនៅក្នុងការរស់នៅប្រចាំថ្ងៃ។ ពួកគាត់ចេះរបៀបរៀបចំផែនការនិយាយឱ្យមានប្រសិទ្ធភាព ដោយត្រូវមានគោលដៅច្បាស់លាស់មុនពេលនិយាយចេញទៅ។

គម្រោងឃីឡាបានបង្កើនឱកាសល្អដល់យុវជនសម្រាប់បំពេញនូវសក្តានុពលភាពរបស់ពួកគេតាមរយៈការផ្តល់សិទ្ធិអំណាចក្នុងការដឹកនាំក្រុមយុវជនក្នុងការគៀងគរធនធានដែលមានប្រយោជន៍សម្រាប់យុវជននៅក្នុងសង្គម៕



*សិស្សស្ម័គ្រចិត្តគម្រោងនៅវិទ្យាល័យហ៊ុន សែន ពាមជីលាំង*

# តើខ្ញុំជានរណា ?



*សិស្សស្ម័គ្រចិត្តនៅវិទ្យាល័យកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន មានជ័យ*

កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២១ គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា( ឃីឡា/KYLA )បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី **"តើខ្ញុំជាអ្នកណា ?"** ដែលបានប្រព្រឹត្តទៅនៅតាមសាលារៀនគោលដៅចំនួន៤ក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។ សមាសភាពអ្នកចូលរួមសរុបមានចំនួន ៤០នាក់ ដែលជាសិស្សស្ម័គ្រចិត្តវ័យក្មេងនៅក្នុងគម្រោងឃីឡា។

វគ្គបណ្តុះបណ្តាលនេះមានគោលបំណងឆ្លុះបញ្ចាំងពីការស្គាល់ខ្លួនឯង ការឱ្យតម្លៃខ្លួនឯង ការកំណត់អំពីគោលបំណងផ្ទាល់ខ្លួនដែលជាផ្នែកចាំបាច់បំផុតនៃការគ្រប់គ្រងខ្លួនឯង ការខិតខំដើម្បីភាពត្រឹមត្រូវភាពស្ថិតស្ថេរក្នុងជំនឿផ្ទាល់ខ្លួន និងការផ្លាស់ប្តូរឥរិយាបថ ដើម្បីសម្រេចគោលដៅជីវិត។

សិស្សស្ម័គ្រចិត្តបានស្វែងយល់ពីការស្គាល់ខ្លួនឯង ភាពខ្លាំង និងភាពខ្សោយ ចំណង់ចំណូលចិត្ត ស្គាល់ពីទេពកោសល្យ ចរិកលក្ខណៈ និងការទទួលខុសត្រូវចំពោះអ្វីដែលពួកគេបានធ្វើ និងកំពុងធ្វើ។

សិស្សស្ម័គ្រចិត្តនៅតាមសាលារៀនីមួយៗបានរៀនសូត្រ និងយល់ពីខ្លឹមសារមេរៀនបានប្រមាណជា៧០ភាគរយ និងបានស្នើមកដល់គម្រោងឱ្យមានរៀបចំវគ្គបណ្តុះបណ្តាលបែបនេះបន្ថែមច្រើនទៀត។

គម្រោងឃីឡាបានបង្កើនឱកាសដល់យុវជន ដើម្បីបំពេញនូវសក្តានុពលរបស់ពួកគេតាមរយៈការផ្តល់សិទ្ធិអំណាចក្នុងការដឹកនាំក្រុមយុវជន គៀងគរធនធានដែលមានប្រយោជន៍ដល់យុវជននៅក្នុងសង្គម និងជាការចូលរួមចំណែកអភិវឌ្ឍធនធានមនុស្ស៕

# តើយុវជនស្ម័គ្រចិត្តទទួលបានចំណេះដឹងអ្វីខ្លះពីការតស៊ូមតិ ?

គម្រោងសកម្មភាពយុវជនវ័យក្មេងនៅកម្ពុជា(ឃីឡា/KYLA) បានសហការជាមួយអង្គការក្រុមប្រឹក្សាយុវជនកម្ពុជា( YCC) រៀបចំវគ្គបណ្តុះបណ្តាលស្តីពី**"ការតស៊ូមតិ"** ដែលនៅសាលារៀនគោលដៅចំនួន៥ ដូចជា វិទ្យាល័យកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានហ៊ុន សែន មានជ័យ វិទ្យាល័យ ហ៊ុន សែន មានជ័យ វិទ្យាល័យ តេជោ ហ៊ុន សែន វិទ្យាល័យ ហ៊ុន សែន ពាមជីលាំង វិទ្យាល័យជីជុះ ហ៊ុន សែន ដែលស្ថិតក្នុងខេត្តកំពង់ចាម និងត្បូងឃ្មុំ។ សមាសភាពអ្នកចូលរួមសរុបមានចំនួន៥៨ នាក់ រួមមាន៖ នាយក/នាយករង លោកគ្រូអ្នកគ្រូ បុគ្គលិក YCC និងសិស្សស្ម័គ្រចិត្តគម្រោង។

វគ្គបណ្តុះបណ្តាលមានគោលបំណង៖ **១**-ដើម្បីពង្រឹងសមត្ថភាពដល់បណ្តាញយុវជនតាមរយៈការចែករំលែកចំណេះដឹង។ **២**-បង្កើនការចូលរួមរបស់យុវជនក្នុងការស្វែងរកមតិគាំទ្រដើម្បីអភិវឌ្ឍសហគមន៍។ **៣**-លើកកម្ពស់ការយល់ដឹងរបស់យុវជន ក្នុងការវិភាគបញ្ហាក្នុងសហគមន៍ ដើម្បីរកដំណោះស្រាយ និងការសហការជាមួយអ្នកពាក់ព័ន្ធ និង **៤**-យុវជនចូលរួមលើកកម្ពស់អភិបាលកិច្ចល្អនិងជំរុញការចូលរួមក្នុងមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍ។



សកម្មភាពសិស្សពិភាក្សាក្រុមលើនៅវិទ្យាល័យ ហ៊ុន សែន មានជ័យ

សិក្ខាកាមទទួលបានចំណេះដឹងទាក់ទងនឹងការតស៊ូមតិដូចជា៖ **១**-ចេះស្វែងរកមតិគាំទ្រ គឺជាការប្រើប្រាស់មធ្យោបាយប្រជាធិបតេយ្យ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរដោយសន្តិវិធី។ **២**-ដឹងពីយុទ្ធនាការស្វែងរកមតិគាំទ្រ គឺជាកម្រងសកម្មភាពយូរអង្វែង ដូចជា ការស្រាវជ្រាវ ធ្វើផែនការ ការត្រួតពិនិត្យ និងវាយតម្លៃ។ **៣**-ការកំណត់បញ្ហាសំដៅដល់ការលើកឡើងអំពីបញ្ហាដែលកំពុងកើតឡើងក្នុងសហគមន៍ និងធ្វើការវិភាគឬសគល់បញ្ហា។ **( អានបន្តទំព័រ ៣៩... )**

# វគ្គបណ្តុះបណ្តាលកម្មវិធីបំណិនជីវិតស្តីពី ការចិញ្ចឹមមាន់

កាលពីថ្ងៃទី០៣ ដល់ទី០៤ ខែធ្នូ ឆ្នាំ២០២១ គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (ស៊ីក/SEEK) បានរៀបចំវគ្គបណ្តុះបណ្តាលបំណិនជីវិតស្តីពី **“ការចិញ្ចឹមមាន់ ការរៀបចំប្រាក់ចំណូល និងលទ្ធផលនៃផែនការអាជីវកម្មខ្នាតតូច”** នៅតាមសាលារៀនគោលដៅក្នុងខេត្តកំពង់ឆ្នាំង។ អ្នកចូលរួមសរុបមានចំនួន៥៩នាក់ ដែលជានាយកសាលា លោកគ្រូអ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលារៀន ក្រុមប្រឹក្សាឃុំ និងអាណាព្យាបាលសិស្ស។

វគ្គបណ្តុះបណ្តាលមានគោលបំណង៖ ១-ធ្វើការយល់ដឹងអំពីគម្រោងស៊ីក ២-ផ្តល់បច្ចេកទេសចិញ្ចឹមមាន់ តាមដានចំណូល និងលទ្ធផល និង ៣-ការយល់ដឹងអំពីការចាប់ផ្តើមអាជីវកម្មខ្នាតតូច។

វគ្គបណ្តុះបណ្តាលនេះផ្តល់នូវចំណេះដឹង ដូចជា ១-**សារៈប្រយោជន៍នៃការចិញ្ចឹមមាន់៖** ពួកគាត់អាចបង្កើនប្រាក់ចំណូល និងការងារដល់គ្រួសារ ព្រមទាំងបានកាត់បន្ថយចំណាយបានមួយកម្រិត។ ជាពិសេស ការចំណាយដើមទុនតិច ប៉ុន្តែវាងាយស្រួលចិញ្ចឹមហើយមានតម្រូវការទីផ្សារខ្ពស់ និងលក់បានថ្លៃ។ ២-**ការរៀបចំទ្រុង និងសម្ភារៈ៖** ដើម្បីចិញ្ចឹមមាន់ឱ្យទទួលបានលទ្ធផលល្អ ពួកគាត់ត្រូវមានទ្រុងសម្រាប់ក្រុងមាន់ ទ្រុងសម្រាប់មេមាន់ និងកូនដាក់ផ្សេងគ្នា ការរៀបចំធ្នើរ និងសំបុកមាន់ខ្ពស់ឱ្យផុតពីដី។ ការសង់ទ្រុងមាន់ត្រូវរើសទីតាំងមិនលិចទឹក មានពន្លឺ និងខ្យល់អាកាសចេញចូលល្អ។ ការសង់ទ្រុងមាន់



ធំអាចទទឹង ២,៥ម x បណ្តោយ ៥ម។ កម្ពស់ជើងរៀង ១,៧ម កម្ពស់កណ្តាល ២,៧ម ដោយមានខ័ណ្ឌជាបន្ទប់ដាច់ដោយឡែកពីគ្នា និងទុកកន្លែង ៣ម ទៅ ៤ម សម្រាប់មាន់ដើរលេង។ ចំពោះទ្រុងកូនមាន់មានទំហំទទឹង ០,៨ម x (**អានបន្តទំព័រ ៤០...**)

(**...តពីទំព័រ ៣៨**) ៤-ការស្រាវជ្រាវគឺជាជំហានដ៏សំខាន់ដែលនាំឱ្យយើង និងអ្នកគាំទ្រដឹងពីមូលហេតុ និងផលប៉ះពាល់បញ្ហា។ ៥-ធ្វើផែនការស្វែងរកមតិគាំទ្រ គឺត្រូវការគោលដៅជាក់លាក់ កំណត់ពីអ្វីដែលនឹងសម្រេចបាន ជាមួយអ្នកណា ដោយរបៀបណា និងរយៈពេលសម្រេច ព្រមទាំងអាចវាស់វែងបាន។ ៦-ធ្វើសកម្មភាព គឺការអនុវត្តតាមផែនការ ការផ្តោតឱ្យចំចំណុច និងអនុវត្តន៍ឱ្យចំពេលវេលា។ ៧-ការវាយតម្លៃ គឺគ្រប់យុទ្ធនាការស្វែងរកមតិគាំទ្រត្រូវមានការប្តេជ្ញាចិត្តក្នុងការត្រួតពិនិត្យ និងវាយតម្លៃឱ្យទៀងទាត់នូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដោយកំណត់ពេលវេលាខ្លះដើម្បីវិភាគព័ត៌មានដែលប្រមូលបានក្នុងដំណើរការត្រួតពិនិត្យ។ ៨-សម្ភារៈសម្រាប់ការស្វែងរកមតិគាំទ្រ ដូចជា ផ្ទាំងរូបភាព បដា ឬក្រដាសពាក្យស្លោក អត្ថបទសារព័ត៌មាន សៀវភៅរឿងខ្លីៗ និងខិតប័ណ្ណផ្សព្វផ្សាយផ្សេងៗ។ ៩-តួនាទី និងការទទួលខុសត្រូវរបស់អ្នកស្វែងរកមតិគាំទ្រ រួមមាន៖ ចរចា រួមដំណើរ ផ្តល់សិទ្ធិអំណាច ធ្វើជាតំណាង ធ្វើជាអ្នកកណ្តាល និងធ្វើជាគំរូ និង ១០-តួនាទី និងការងារទទួលខុសត្រូវរបស់អ្នកតស៊ូមតិ ដូចជា លើកទឹកចិត្តឱ្យមានការចូលរួម ធានាឱ្យមានភាពស្របច្បាប់ ត្រូវមានការទទួលខុសត្រូវជាសាធារណៈ ធ្វើសកម្មភាពដោយសន្តិវិធី និងធ្វើជាតំណាងក្រុមដែលទទួលរងផលប៉ះពាល់។

យុវជនដែលចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនេះទទួលបានចំណេះដឹងល្អៗ ទុកជាជំនាញទន់ ក៏ដូចជាបានដឹងពីរបៀបដំណើរការការងារតស៊ូមតិប្រកបដោយសន្តិវិធីនៅក្នុងសហគមន៍។ ក្រោយវគ្គបណ្តុះបណ្តាលនេះចប់ យុវជនចំនួនជាង៨០ភាគរយយល់ដឹងពីខ្លឹមសារមេរៀនបានច្រើន និងក៏រៀបចំទ្រាមយកចំណេះដឹងពីវគ្គនេះទៅអនុវត្តនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃក្នុងការចូលរួមការអភិវឌ្ឍសហគមន៍នៅមូលដ្ឋានរបស់ពួកគេ៕



*យុវជននៅវិទ្យាល័យ តេជោ ហ៊ុន សែន កំពង់ទ្រាសកំពុងចូលរួម វគ្គបណ្តុះបណ្តាលស្តីពី "**ការតស៊ូមតិ** "។*

(...តពីទំព័រ ៣៩) បណ្តោយ ១,២ម កម្ពស់ជើង ០,៤ម និងកម្ពស់ទ្រុង ០,៥ ម។ **៣-ការរៀបចំសំបុកសម្រាប់មាន់ពង និងស្នូកសម្រាប់ដាក់ចំណី៖** សំបុកធ្វើល្អី សំបកឡាំង បង្គីបន្ទាប់មកដាក់ចំបើង ស្លឹកចេក ឬកំទេចក្រណាត់ទ្រាប់បាតសំបុកដោយស្លឹកគ្រៃ ថ្នាំជក់ ស្លឹកស្ដៅដើម្បីការពារកុំឱ្យកើតស្រមើល។ ស្នូកសម្រាប់ដាក់ចំណីមាន ដូចជា ស្នូកធ្វើពីសំបកកង់ឡាន ដូង ធុង និងស្នូកធ្វើពីឈើ។ **៤-ការជ្រើសរើសមេមាន់សម្រាប់ចិញ្ចឹម៖** មេមាន់ត្រូវមានលក្ខណៈជាមេមាន់មានពូជធំ (សំពៅ) មានទម្ងន់ ១,៥ គីឡូឡើងទៅ មានសុខភាពល្អ ផ្ដល់ស៊ុតបានពី ៤ ទៅដល់ ៥ដងក្នុង១ឆ្នាំ និងក្រាបពងញាស់បានល្អ មានមុខក្រហមស្រស់ រោមភ្លឺរលោង និងមានជើងលឿងរមៀត។ ចំណែកឯមាន់គក ត្រូវមានទម្ងន់ ២ គីឡូឡើង សុខភាពល្អ ភាពរហ័សរហួន ពូកែជាន់មេ និងមានលក្ខណៈដូចជាមុខក្រហមស្រស់ ភ្នែកភ្លឺថ្លា និងមានជើងលឿងរមៀត។ ចំពោះការជ្រើសរើសកូនមាន់សម្រាប់ចិញ្ចឹមវិញ មេបាវាត្រូវតែមានមាឌធំ និងជាកូនមាន់ដែលធ្វើវ៉ាក់សាំងរួចហើយមានលក្ខណៈដូចជា មានអាយុ២០ថ្ងៃ មុខក្រហមស្រស់ ភ្នែកភ្លឺថ្លា រោមគូថស្ងួត និងរហ័សរហួន។ ម៉្យាងទៀត មាន់ដែលទើបទិញមកថ្មីត្រូវក្រុងទុកដាច់ដោយឡែកសិន ដើម្បីឱ្យប្រាដកថាគ្មានជំងឺមុនដាក់ចិញ្ចឹមចូលជាមួយមាន់ចាស់។ **៥-របៀបភ្ញាស់កូនមាន់៖** ពងមាន់ត្រូវការកំដៅ ៣៧,៥ អង្សាសេ មានសំណើមសមស្រប ហើយពងត្រូវការបង្វិលមួយថ្ងៃយ៉ាងតិច១០ដង។ **៦-របៀបថែទាំកូនមាន់ក្រោយពេលញាស់៖** កូនមាន់ក្រោយពេលញាស់ទុកឱ្យមេក្រុងចំនួន៣ថ្ងៃ ដោយដាក់ក្នុងទ្រុងតូចទាំងមេទាំងកូន បន្ទាប់ពី៣ថ្ងៃ បំបែកមេចេញនៅពេលថ្ងៃ។ ក្នុងរយៈពេលពី៧ទៅ១០ថ្ងៃអាចបំបែកដាច់ពីមេ និងផ្ដល់ទឹកចំណីឱ្យស៊ីរហូតដល់អាយុ១ខែ។ **៧-ការរៀបចំណី និងការផ្ដល់ចំណីមាន់៖** កូនមាន់លាយចំណីសម្រេច១ភាគ ជាមួយចំណីក្នុងភូមិ (ចុងអង្ក កន្ទក់លេខ១ ម្សៅពោត)១ភាគសម្រាប់កូនមាន់អាយុពី១ខែទៅ២ខែ។ រីឯកូនមាន់ធំលាយចំណីសម្រេច១ភាគ ជាមួយចំណីក្នុងភូមិ ២ភាគសម្រាប់កូនមាន់អាយុ២ខែឡើង និងសម្រាប់មេមាន់ពងត្រូវបន្ថែមម្សៅ សំបកខ្យង ឬម្សៅឆ្អឹង។ ទន្ទឹមនឹងនោះ ចិញ្ចឹមជន្លេនក្រហមផ្ដល់ជាចំណីបន្ថែមសម្រាប់មាន់ ពីព្រោះវាសម្បូរជាតិប្រូតេអ៊ីនធ្វើឱ្យមាន់ស៊ីឆាប់ធំ ហើយជួយកាត់បន្ថយការចំណាយលើចំណី។ **៨-ជម្ងឺមាន់៖** មានដូចជា ជម្ងឺញូវកាស ជម្ងឺអុតមាន់ ជម្ងឺអាសន្នរោគ ជម្ងឺផ្ដាសាយបក្សីគឺវាឆ្លងតាមរយៈការផឹកទឹកស៊ីចំណី ហើយវាកើតលើមាន់គ្រប់វ័យ និងមានអត្រាស្លាប់ខ្ពស់ និង **៩-វិធានការណ៍ការពារ៖** គឺត្រូវដាក់មាន់ក្នុងទ្រុង ផ្ដល់ទឹកចំណីគ្រប់គ្រាន់ ចាក់វ៉ាក់សាំងការពារជម្ងឺគ្រប់មុខ និងទៀងទាត់ សម្អាតអនាម័យស្នូកទឹក ស្នូកចំណីជាប្រចាំ ទម្លាក់ព្រូនមាន់១ខែម្ដង និងត្រូវបំបែកមាន់ឈឺចេញពីមាន់ជា។

ការបណ្ដុះបណ្ដាលនេះបានធ្វើឱ្យឪពុកម្ដាយសិស្សយល់ដឹងអំពីរបៀបចិញ្ចឹមមាន់ និងការរៀបចំផែនការអាជីវកម្មខ្នាតតូច ដើម្បីបង្កើនចំណូលក្នុងគ្រួសារ។ បន្ទាប់ពីចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលនេះរួច ឪពុកម្ដាយសិស្សបានធ្វើកិច្ចសន្យាជាមួយគម្រោងដើម្បីបើកដំណើរការចិញ្ចឹមមាន់៕



*លោកស្រី ហ៊ឹម ម៉ារី ប្រធានគម្រោងកំពុងធ្វើធ្វើបទបង្ហាញស្ដីពីការគ្រប់គ្រងចំណូល និងចំណាយរវល់ឪពុកម្ដាយ និងអាណាព្យាបាលសិស្សក្នុងអំឡុងវគ្គបណ្ដុះបណ្ដាលកម្មវិធីបំណិនជីវិតស្ដីពី ការចិញ្ចឹមមាន់។*

# កម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាន

កាលពីថ្ងៃទី២៩ ដល់ទី៣០ ខែធ្នូ ឆ្នាំ២០២១ គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (ស៊ីក/SEEK) ក្រោមជំនួយហិរញ្ញប្បទានពីសហភាពអឺរ៉ុប និងរួមសហប្រតិបត្តិដោយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA) អង្គការក្រុមប្រឹក្សាយុវជនកម្ពុជា (YCC) និងអង្គការវីវើល បានរៀបចំសិក្ខាសាលាស្តីពី កម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាន ដែលប្រព្រឹត្តទៅនៅសាលាបឋមសិក្សាគិរីសុវណ្ណវង្ស។

សិក្ខាសាលានេះមានអ្នកចូលរួមសរុបចំនួន៥៤នាក់ រួមមាន៖ តំណាងការិយាល័យអប់រំ យុវជន និងកីឡាស្រុក នាយក និងលោកគ្រូអ្នកគ្រូទទួលបន្ទុកកម្មវិធីអប់រំបំណិនជីវិតមូលដ្ឋាន ដែលមកពីសាលារៀនគោលដៅចំនួន១៨ ដូចជា សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ក្នុងខេត្តកំពង់ឆ្នាំង។

សិក្ខាសាលានេះមានគោលបំណងឱ្យលោកគ្រូអ្នកគ្រូបានស្វែងយល់ពីសាវតា និងការប្រើប្រាស់សៀវភៅបំណិនជីវិត ដើម្បីយកទៅបង្រៀនសិស្សឱ្យមានចំណេះដឹង បំណិន និងទទួលបានបទពិសោធន៍ផ្នែកបំណិនជីវិតងាយដែលចាំបាច់សម្រាប់បម្រើដល់ជីវភាពប្រចាំថ្ងៃ។

បំណិនជីវិត គឺជាបំណិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈដែលអាចជួយដល់កាធ្វើការសម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ព្រមទាំងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន។ វាគឺជាបំណិនដែលរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព។

សិក្ខាកាមចេះប្រើប្រាស់សៀវភៅបំណិនជីវិតក្នុងការបង្រៀន និងរៀនដូចខាងក្រោម៖ ១-ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស គឺត្រូវត្រូវមាន៖ សម្ភារឧបទេស វត្ថុបំណងសញ្ញាសម្គាល់សម្រាប់សកម្មភាពនីមួយៗ លំនាំបង្រៀន ខ្លឹមសារសង្ខេប និងការវាយតម្លៃ។ ២-សិក្ខាកាមធ្វើការជាដៃគូដើម្បីរៀបចំមេរៀនបង្រៀនពីការដាំដំណាំទ្រើង រួមមាន៖ ការរៀបចំដី ការលូតលាស់ដំណាំសណ្តែកទ្រើង ការធ្វើប្រដាប់បឺតសត្វ និងទ្រុងសត្វល្អិត ដី ការវិភាគប្រព័ន្ធក្សេត្របរិស្ថាន សត្វល្អិត ស្មៅចង្រៃ វដ្តជីវិត និងសំណាញ់ចំណីអាហារ លក្ខណៈជំងឺដំណាំសណ្តែកទ្រើង និងទីវាលចំការ។

លោកគ្រូអ្នកគ្រូបានធ្វើផែនការបង្រៀនកម្មវិធីបំណិនជីវិតតាមសាលារៀននីមួយៗ និងបានយល់ពីសារៈប្រយោជន៍អំពីកម្មវិធីដែលវាបានផ្សារភ្ជាប់ទៅនឹងតម្រូវការប្រចាំថ្ងៃ និងបានជួយឱ្យមនុស្សជៀសផុតពីការប្រឈមនឹងបញ្ហាអត់ការងារធ្វើដែលបណ្តាលមកពីខ្វះការយល់ដឹងក្នុងការធ្វើផលិតកម្មកសិកម្ម៕



*សកម្មភាពលោកគ្រូអ្នកគ្រូធ្វើការជាដៃគូពិភាក្សាអំពីរបៀបដាំដំណាំសណ្តែកទ្រើង។*

អនុវិស័យទី ១០

# កម្មវិធីឆ្លើយតបនឹង
# វិស័យអប់រំក្នុងបរិបទ
# ជំងឺកូវីដ-១៩

## Covid19 Response & Recovery Programming



# សកម្មភាពកម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំនៅកម្ពុជា



*វគ្គទម្រង់ទិសស្តីពី ការប្រើប្រាស់កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមនៅខេត្តកំពត។*

កម្មវិធីឆ្លើយតប និងស្តារឡើងវិញនូវវិស័យអប់រំនៅកម្ពុជាក្នុងបរិបទជំងឺកូវីដ-១៩ (CERRP) គាំទ្រដោយភាពជាដៃគូសកលដើម្បីការអប់រំ ដែលជាកម្មវិធីថ្មីរបស់អង្គការខេប និងគាំទ្រហិរញ្ញប្បទានដោយអង្គការយូនីសេហ្វ (UNICEF)។

អំឡុងពេលខែកញ្ញា ដល់ខែវិច្ឆិកា ឆ្នាំ២០២១ គម្រោងបន្តគាំទ្រផ្នែកបច្ចេកទេសដល់នាយកដ្ឋានរបស់ក្រសួងអប់រំ យុវជននិងកីឡា លើសមាសភាគសំខាន់ៗចំនួនពីរ រួមមាន៖ ១-**បន្តជំរុញការសិក្សាពីចម្ងាយ (អាទិភាពនៅពេលសាលារៀនត្រូវបានបិទ)៖** ដើម្បីបង្កើនលទ្ធភាព និងគុណភាពនៃការប្រើប្រាស់សម្ភារៈសិក្សាពីចម្ងាយដែលផលិតដោយក្រសួងអប់រំ យុវជន និងកីឡា (វីដេអូ និងសន្លឹកកិច្ចការ)។ ២-**កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែម (នៅពេលដែលសាលារៀនបើក)៖** កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមបានគាំទ្រកុមារក្នុងការពង្រឹងសមត្ថភាពទៅលើសមាសភាគសំខាន់ៗក្នុងមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា ដើម្បីឱ្យពួកគេមានភាពស្រួលក្នុងការបន្តការសិក្សានៅថ្នាក់បន្ទាប់បាននាពេលអនាគត។

**សមាសភាគសំខាន់ៗការសិក្សាពីចម្ងាយ៖**

- គម្រោងបានធ្វើការបញ្ចប់ការចាត់ថ្នាក់ និងបានដាក់បញ្ចូលសម្ភារៈសិក្សាពីចម្ងាយចូលទៅក្នុងគេហទំព័រមជ្ឈមណ្ឌលសិក្សតាមរយៈអេឡិចត្រូនិករបស់ក្រសួងអប់រំ យុវជន និងកីឡា (MoEYS E-Learning Portal)។ ធនធានទាំងនេះរួមមាន៖ មត្តេយ្យ សិក្សាបឋមសិក្សា និងអនុវិទ្យាល័យ។

- បន្ថែមធនធានផ្នែកអប់រំពិសេសដែលនឹងត្រូវបានបង្កើតនៅក្នុងកម្មវិធី MoEYS e-Learning Portal។

- នៅត្រីមាសបន្ទាប់ គម្រោងនឹងបញ្ចប់ការដាក់បញ្ចូលសម្ភារអប់រំកម្រិតបឋមសិក្សា រួមទាំងធនធានសិក្សាផ្នែកវិទ្យាសាស្ត្រ និងសង្គមបន្ថែមចូលទៅក្នុងគេហទំព័រ ដែលមានសម្ភារសិក្សាភាសាខ្មែរ និងគណិតវិទ្យាដែលបានដាក់បញ្ចូលរួចជាស្រេច។

- គម្រោងបានពិភាក្សាជាមួយមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ដើម្បីស្វែងរកការសហការក្នុងការផ្សព្វផ្សាយលទ្ធផលសំខាន់ៗរបស់គម្រោង សម្រាប់ជំរុញការសិក្សាពីចម្ងាយ និងការប្រើប្រាស់កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមទៅកាន់វិទ្យាស្ថានបណ្តុះបណ្តាលការបង្រៀន នៅដើមខែកុម្ភៈ ឆ្នាំ២០២២ និងបានសហការជាមួយទីភ្នាក់ងារដៃគូ Melon Rouge Agency (MRA) ដែលកំពុងធ្វើការផលិតសំណុំវីដេអូសម្រាប់នាយកសាលា មាតាបិតា លោកគ្រូអ្នកគ្រូ ដើម្បីគាំទ្រការបង្រៀន និងរៀនរបស់កុមារទាំងនៅផ្ទះ និងនៅសាលារៀន។

**កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែម៖**

- កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមកម្រិតបឋមសិក្សាទាំងអស់ ទាំងភាសាខ្មែរ និងគណិតវិទ្យាត្រូវបានបញ្ចូលទៅកាន់សាលាបឋមសិក្សាទាំងអស់តាមរយៈនាយកដ្ឋានអប់រំបឋមសិក្សា។

- កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមអាចរកបានក្នុង MoEYS E-Learning Portal។

- ថ្មីៗនេះ គម្រោងកំពុងត្រួតពិនិត្យនិងសាកល្បងដាក់ឱ្យប្រើប្រាស់កញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែម ដែលបានកែសម្រួលសម្រេចចុងក្រោយក្នុងខែមករា ឆ្នាំ២០២២។

- គម្រោងបានប្រជុំជាមួយនាយកដ្ឋានអប់រំបឋមសិក្សា និងអង្គការក្រៅរាជរដ្ឋាភិបាលដទៃទៀត រួមទាំងអង្គការទស្សនៈពិភពលោកដើម្បីពិភាក្សាអំពីកិច្ចសហការក្នុងការដាក់ចេញនូវកញ្ចប់ឯកសារការសិក្សាបំប៉នបន្ថែមដល់សាលារៀនទាំងអស់ក្នុងប្រទេស។

អង្គការ ខេប នៅតែបន្តសម្របសម្រួលលើការសិក្សាពីចម្ងាយជាមួយក្រុមការងារដែលដឹកនាំដោយអង្គការសង្គ្រោះកុមារ ដើម្បីរួមបញ្ចូលអនុសាសន៍ទាក់ទងនឹងសកម្មភាពដែលត្រូវអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ឆ្នាំសិក្សាបន្ទាប់។

ចំណុចសំខាន់ៗទាំងអស់ដែលបានលើកឡើងនៅក្នុងការពិភាក្សាជាមួយនាយកដ្ឋានអប់រំបឋមសិក្សា ត្រូវបានបញ្ចូលក្នុងឯកសារដែលនឹងត្រូវធ្វើការចែករំលែកនៅក្នុងកិច្ចប្រជុំ Joint Technical Working Group (JTWG) ដែលនឹងមានអង្គការយូណីសេហ្វចូលរួមដើម្បីធ្វើបច្ចុប្បន្នភាពការអភិវឌ្ឍក្នុងកម្មវិធី CERRP ផងដែរ ៕

# ព្រឹត្តិការណ៍ ចំណេះដឹង កំណាព្យ និងការសិក្សាស្រាវជ្រាវផ្សេងៗ

*“ការអភិវឌ្ឍតាមរយៈបណ្តាញ និងនៅថ្នាក់មូលដ្ឋាន”។*

# Events, Knowledge, Poems, and Other Researches

*"Development through Networking and Outreach."*



# កម្មវិធីបើកដំណើរគម្រោងសម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាពនិងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម ( CO-SAVED )




*អាជ្ញាធរដែនដី លោកគ្រូអ្នកគ្រូ និងអ្នកពាក់ព័ន្ធបានចូលរួមជាសក្ខីភាពក្នុងការបើកដំណើរការគម្រោងតាមរយៈប្រព័ន្ធអនឡាញ។*

កាលពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ អង្គការ ខេប បានរៀបចំកម្មវិធីបើកដំណើការគម្រោង **“សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចេរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម ( CO-SAVED )”** តាមរយៈប្រព័ន្ធអនឡាញ (Zoom) ដែលមានអ្នកចូលរួមសរុបចំនួន៩៨នាក់ ដែលជាប្រធាន/អនុប្រធានមន្ទីរ ការិយាល័យមធ្យម បឋម កុមារតូច និងការិយាល័យក្រៅប្រព័ន្ធអប់រំ យុវជន និងកីឡាខេត្ត-ស្រុក អភិបាលក្រុង សមាជិកក្រុមប្រឹក្សាក្រុង អភិបាលរងស្រុក ចៅសង្កាត់ស្មៀន មេឃុំ ជំទប់១ នាយក និងនាយករងដើម្បីផ្សព្វផ្សាយសកម្មភាពគម្រោងដល់សាលារៀនគោលដៅ និងអ្នកពាក់ព័ន្ធពាក់។

គម្រោង CO-SAVED ត្រូវបានបង្កើតឡើងជាគំរូប្រកបដោយនវានុវត្តន៍ និងការអភិវឌ្ឍដែលធ្វើឱ្យមានភាពជាដៃគូរវាងវិស័យឯកជន រដ្ឋាភិបាល និងសង្គមស៊ីវិលចូលរួមដើម្បីជំរុញដំណើរវឌ្ឍនភាពឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

គោលដៅរបស់គម្រោង គឺលើកកម្ពស់ជីវភាពសហគមន៍នេសាទក្នុងតំបន់ឆ្នេរសមុទ្រប្រែក្លាយមានភាពរស់រវើកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋានប្រកបដោយចេរភាព ពង្រឹងការផ្តល់សេវាកម្ម និងការអភិវឌ្ឍបៃតង ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ និងវិសមភាព ដើម្បី៖ ១-អភិវឌ្ឍសមត្ថភាព និងពង្រឹងភាពជាដៃក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន។ ២-ពង្រឹងនូវការផ្តល់សេវាអប់រំ និងការទទួលបានសេវាទឹកស្អាត និងអនាម័យ។ ៣-ពង្រឹងការផ្តល់ឱកាសសម្រាប់ការប្រកបមុខរបបចិញ្ចឹមជីវិត និងការអភិរក្សបរិស្ថាន ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច។

គម្រោងផ្តោតលើសកម្មភាពសំខាន់ៗដូចជា៖ ១-ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់សាលាមត្តេយ្យសហគមន៍។ ២-លើកកម្ពស់លទ្ធភាពទទួលបានការអប់រំសម្រាប់សិស្សកូនអ្នកនេសាទ។ ៣-បង្កើនការចុះឈ្មោះចូលរៀន និងពង្រឹងគុណភាពសិក្សាសម្រាប់សិស្សអនុវិទ្យាល័យ។

គម្រោង CO-SAVED គឺជាគម្រោងសម្ព័ន្ធដែលមានសកម្មភាពប្រតិបត្តិរយៈពេល៤ឆ្នាំ រួមមាន៖ អង្គការ Aide et Action (AEA) អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប) សមាគមបណ្តុះកុមារ (BK) អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA) គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) អង្គការហេហ្វើអន្តរជាតិ (HI) អង្គការ Impact Hub (IH) សមាគមទេសចរណ៍អាស៊ីប៉ាស៊ីហ្វិច (PATA) សមាគមសហគ្រិនវ័យក្មេងកម្ពុជា (YEAC) សម្ព័ន្ធភាពជាតិក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន (NLC) សមាគមទាំងបួនស្រុក រាជធានី ឃុំ និងសង្កាត់ (AM DCS) អង្គការសម្ព័ន្ធភាពកម្ពុជាដើម្បីអភិរក្សជលផល (CCF) និងអង្គការសង្គមស៊ីវិលចំនួន២០ស្ថាប័ន រួមទាំងវិស័យឯកជន និងសហគ្រាសសង្គមចំនួន១៧ស្ថាប័នបន្ថែមទៀត។

គម្រោង CO-SAVED បានប្រើប្រាស់វិធីសាស្រ្តពហុភាគីពាក់ព័ន្ធ និងផ្តោតលើប្រធានបទពង្រីកបន្ត ដែលនឹងផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋកម្ពុជានៅក្នុងសហគមន៍តំបន់ឆ្នេរ ដើម្បីបង្កើតភាពជាដៃគូយូរអង្វែងសម្រាប់កំណើនសេដ្ឋកិច្ចបៃតង ព្រមទាំងការផ្តល់សេវាកម្មប្រកបដោយគុណភាព និងធ្វើយ៉ាងណាឱ្យជីវភាពរស់របស់អ្នកទទួលផលពីគម្រោងកាន់តែមានភាពល្អប្រសើរឡើង៕

# មហោស្រពជាតិលើកទី១ ស្តីពី ពិព័រណ៍ការអប់រំស្ទែម




*វាគ្មិនគន្លឹះដែលជាអ្នកសិក្សាស្រាវជ្រាវ ទីប្រឹក្សាអប់រំ គ្រូប្រឹក្សាគរុកោសល្យ គ្រូឧទ្ទេស គ្រូបង្រៀន និងប្អូនៗសិស្សានុសិស្សជាច្រើនមកពីគ្រឹះស្ថានសិក្សានានា ដើម្បីចូលរួមចែករំលែកចំណេះដឹង បទពិសោធន៍ទាក់ទងទៅនឹងការបង្រៀនបែបស្ទែម និងបង្ហាញស្នាដៃរបស់សិស្ស តាមរយៈអនឡាញ (Zoom)។*

កាលពីថ្ងៃទី១៣ ដល់ទី១៥ ខែធ្នូ ឆ្នាំ២០២១ មហោស្រពជាតិលើកទី១ ស្តីពី **"ពិព័រណ៍ការអប់រំស្ទែម"** ត្រូវបានរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា រួមសហការជាមួយអង្គការ KOICA, World Best Friend, EMCAST, STTC តាមរយៈប្រព័ន្ធអនឡាញ(ZOOM)។ សមាសភាពអ្នកចូលរួមសរុបក្នុងមហោស្រពជាតិលើកទី១ មានចំនួន១០០០នាក់ រួមមាន៖ វាគ្មិនគន្លឹះដែលជាអ្នកសិក្សាស្រាវជ្រាវ ទីប្រឹក្សាអប់រំ គ្រូប្រឹក្សាគរុកោសល្យ គ្រូឧទ្ទេស គ្រូបង្រៀន និងប្អូនៗសិស្សានុសិស្សជាច្រើនមកពីគ្រឹះស្ថានសិក្សានានា ដើម្បីចូលរួមចែករំលែកចំណេះដឹង បទពិសោធន៍ទាក់ទងទៅនឹងការបង្រៀនបែបស្ទែម និងបង្ហាញស្នាដៃរបស់សិស្ស។

មហោស្រពជាតិលើកទី១នេះ ត្រូវបានរៀបចំឡើងដោយមានគោលបំណង ដើម្បីបញ្ជ្រៀប និងផ្សព្វផ្សាយការអប់រំបែបស្ទែម ដែលទាក់ទងទៅនឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាដែលផ្តោតលើការសិក្សាបែបស៊ីជម្រៅអំពីបាតុភូតអ្វីមួយ ការពិសោធន៍ដែលមានលក្ខណៈវិទ្យាសាស្ត្រ និងការសិក្សាដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើប។

ឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ រ័ត្ន** ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវគរុកោល្យជំនាន់ថ្មីបានមានមតិស្វាគមន៍នៅក្នុងមហោស្រព



*ឯកឧត្តមបណ្ឌិតសភាចារ្យ ច័ន្ទ រ័ត្ន*

ជាតិលើកទី១ថា *"ការអប់រំនាពេលបច្ចុប្បន្នមានការផ្លាស់ប្តូរលឿនជាងការរំពឹងទុក ដែលតម្រូវឱ្យមានផែនការច្បាស់លាស់ ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរក្នុងបរិបទសកលភាវូបនីយកម្ម។ ដូច្នេះ ក្រសួងអប់រំ យុវជន និងកីឡា បានកែប្រែវិស័យអប់រំដោយកំណត់នូវសសរស្តម្ភទាំងប្រាំដែលមានវិសាលភាព ចាប់ពីមត្តេយ្យសិក្សារហូតដល់បឋមសិក្សា។ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនលើការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មានវិទ្យា និងសារគមនាគមន៍ក្នុងដំណើរការបង្រៀន និងរៀន គឺជាកត្តាចម្បងជានាដល់ដំណើរការអប់រំនិងផ្ទេរចំណេះដឹងឱ្យរក្សាបាននូវគុណភាពអប់រំ "*។ លោកបានបន្ថែមថា មហោស្រពជាតិស្តីពីពិព័រណ៍ការអប់រំស្ទែម គឺពិតជាបានចូលរួមចំណែកចែករំលែកចំណេះដឹង បទពិសោធន៍ កិច្ចការងារ និងការបញ្ជ្រៀបបច្ចេកវិទ្យា ព័ត៌មានក្នុងវិស័យអប់រំ ព្រមទាំងបានឆ្លុះបញ្ចាំងពីតួនាទី និងសារៈសំខាន់នៃបច្ចេកវិទ្យា។ គោលបំណងនៃមហោស្រពជាតិនេះ គឺដើម្បីផ្លាស់ប្តូរបទពិសោធន៍តាមរយៈកិច្ចពិភាក្សា អំពីគំរូផ្សេងៗពីការអប់រំស្ទែម ទស្សនយល់ឃើញនៃការអនុវត្តការអប់រំស្ទែម និងកម្រិតសាលារៀនដែលបានផ្តល់ឱកាសដល់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្ស រក្សាបាននូវបណ្តាញទំនាក់ទំនងជាសហគមន៍ព្រមទាំងបានអភិវឌ្ឍសមត្ថភាពលើវិជ្ជាជីវៈជាគ្រូបង្រៀនរបស់ខ្លួនផងដែរ។

លោក KiWoong Nam នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាល (**អានបន្តទំព័រ ៤៧...**)

(...តពីទំព័រ ៤៦) គ្រូសម្រាប់ការអប់រំស្ទែម បានមានមតិស្វាគមន៍នៅក្នុងមហាស្រមជាតិលើកទី១ថា *“ការអប់រំស្ទែមពិតជាសំខាន់សម្រាប់អភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើនជាពិសេសក្នុងសម័យឌីជីថល ឬឧស្សាហកម្ម ៤.០។ នៅក្នុងសតវត្សរ៍ទី២១ ការអប់រំស្ទែមត្រូវការវិធីសាស្ត្រថ្មីសម្រាប់ការអប់រំថ្មីដើម្បីទទួលបានគុណភាពអប់រំខ្ពស់”*។

លោក RHO Hyunjun ជានាយកប្រចាំប្រទេសកម្ពុជារបស់ទីភ្នាក់ងារសហប្រតិបត្តិ



*លោក RHO Hyunjun*

ការអន្តរជាតិកូរ៉េកា មានប្រសាសន៍ថា*“ការអប់រំស្ទែមនឹងជំរុញឱ្យយុវជនកម្ពុជាមានភាពរីកចម្រើនរុងរឿង ដែលជាធនធានយ៉ាងសំខាន់សម្រាប់ដឹកនាំប្រទេសឆ្ពោះទៅមុខ និងជាធនធានសម្រាប់មនុស្សជំនាន់ក្រោយ”*។

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានថ្លែងសុន្ទរកថានៅក្នុងឱកាសបើកកម្មវិធីមហាស្របជាតិលើកទី១ ថា *“កម្មវិធីមហាស្របជាតិ ធ្វើឡើងដើម្បីបង្កើនការយល់ដឹងពីសារៈសំខាន់ ការអប់រំស្ទែម ដោយមានការចូលរួមទាំងគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន គ្រឹះស្ថានបណ្តុះបណ្តាល និងផ្តល់ឱកាសដល់លោកគ្រូអ្នកគ្រូ ជាពិសេសមុខវិជ្ជាឯកទេសវិទ្យាសាស្ត្រ និងគណិតវិទ្យា ដើម្បីបង្ហាញពីសមត្ថភាពបង្រៀនក៏ដូចជាបំផុស និងជំរុញលើកទឹកចិត្តឱ្យសិស្ស និងគ្រូដើម្បីបង្ហាញស្នាដៃបង្កើតថ្មីរបស់ខ្លួនតាមរយៈការផលិតវីដេអូសម្រាប់ធ្វើការចូលរួមប្រកួតប្រជែងក្នុងមហាស្របជាតិលើកទី១នេះ ”*។ លោកបានបន្តទៀតថា ក្រសួងអប់រំ យុវជន និងកីឡាបានសហការយ៉ាងជិតស្និតជាមួយបណ្តាក្រសួងពាក់ព័ន្ធ ភ្នាក់ងារអង្គការជាតិ និងអន្តរជាតិ ធនាគារពិភពលោក ធនាគារអភិវឌ្ឍអាស៊ី និងដៃគូដទៃទៀតក្នុងវិស័យអប់រំ ដោយរួមគ្នាអនុវត្តន៍ និងវិនិយោគលើការអប់រំស្ទែម រួមមានការពង្រីកសាលារៀនជំនាន់ថ្មីដែលបច្ចុប្បន្នមាន១១កន្លែង និងពង្រីក១៥កន្លែងបន្ថែមទៀតក្នុងពេលខាងមុខ។ សាលារៀនជំនាន់ថ្មីផ្តោតលើការអប់រំបច្ចេកវិទ្យា Robotic ការបង្កើតអគារអប់រំស្ទែមនៅសាកលវិទ្យាល័យភ្នំពេញ ការជំរុញមុខវិជ្ជាស្ទែមនៅថ្នាក់ឧត្តមសិក្សា និងការរៀបចំប្រកួតស្នាដៃ ដែលមានគំនិតច្នៃប្រឌិតស្ទែម។ ជាងនេះទៅទៀតក្រសួងបានបញ្ចៀបការសិក្សាបច្ចេកវិទ្យា និងវិទ្យាសាស្ត្រក្នុងកម្មវិធីសិក្សាចំណេះទូទៅថ្នាក់ទី៤ ដល់ទី១២ និងលើកទឹកចិត្តឱ្យសិស្សសិក្សាផ្នែកវិទ្យាសាស្ត្រ។




*ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*

លោក **សម្ប កំសាន្ត** ជានាយករងនៃវិទ្យាល័យព្រះស៊ីសុវត្ថិ កម្មវិធីសាលារៀនជំនាន់ថ្មី តាមរយៈបទបង្ហាញបានលើកឡើងថា *“លោកគ្រូអ្នកគ្រូត្រូវតែផ្លាស់ប្តូរទម្លាប់បង្រៀនតាមបែបប្រពៃណីមកជាសតវត្សរ៍ទី២១វិញ ដោយប្រើប្រាស់វិធីបង្រៀននិងរៀនថ្មីៗ ដូចជា ១-ការសិក្សាបែបរិះរក ២-ការសិក្សាបែបដោះស្រាយបញ្ហា ៣-ការសិក្សាបែបគម្រោង និងថ្នាក់រៀនត្រឡប់ ឬការសិក្សាបែបបញ្ចូលគ្នា។ នេះគឺជាគន្លឹះដែលខាងសាលារៀនជំនាន់ថ្មីត្រៀមធ្វើសម្រាប់ជាថ្នាលដើម្បីបណ្តុះបណ្តាលយុវជនបែបសតវត្សរ៍ទី២១ឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុងសម័យឌីជីថល។ ពិតណាស់ វិទ្យាល័យព្រះស៊ីសុវត្ថិបានអនុវត្តវិធីសាស្ត្រទាំងអស់នេះបាន៤-៥ឆ្នាំមកហើយ និងទទួលបានលទ្ធផលល្អគួរឱ្យកត់សម្គាល់”*។

ឯកឧត្តម **ពុធ សាមិត្ត** ប្រធាននាយកដ្ឋានអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ក្នុងមហាស្របជាតិលើកទី១នេះថា *“ការធ្វើកំណែទម្រង់នៅក្នុងវិស័យអប់រំកត្តាសំខាន់បំផុតគឺកត្តាបង្កើនគុណវុឌ្ឍិគ្រូបង្រៀន ដើម្បីឱ្យប្រព័ន្ធអប់រំមួយរឹងមាំអាស្រ័យលើគុណភាពគ្រូបង្រៀន គឺជាកត្តាចម្បងក្នុងការអភិវឌ្ឍប្រទេសជាតិ”*។

ឯកឧត្តម **អ៊ឹម កុច** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា *“ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើកំណែទម្រង់វិស័យអប់រំ និងបានរៀបចំឱ្យមាននយោបាយអប់រំស្ទែមនៅឆ្នាំ២០១៦ ដើម្បីឈានទៅកេស្វ័យសិក្សារៀនសូត្រក្នុងការស្វែងរកភាពម្ចាស់ការលើខ្លួនឯងដើម្បីឈានទៅរកការអភិវឌ្ឍធនធានមនុស្សឱ្យមានជំនាញសតវត្សរ៍ទី២១ ទាក់ទងផ្នែកខាង **Robotic** និង **Coding**។ ស្ទែមគឺជាការដោះស្រាយបញ្ហាការមើលឃើញពីបញ្ហា និងខិតខំដោះស្រាយបញ្ហា និងបង្កើតបានជាដំណោះស្រាយមួយដែលមានគុណតម្លៃ* (អានបន្តទំព័រ៤៨...)




*ឯកឧត្តមបណ្ឌិត អ៊ឹម កុច រដ្ឋលេខាធិការក្រសួង អប់រំ យុវជន និងកីឡាក្នុងអំឡុងពេលមហោស្រពជាតិលើកទី១តាមរយៈប្រព័ន្ធអនឡាញ។*

( ...តពីទំព័រ ៤៧ ) *សម្រាប់មនុស្សជាតិ"*។

តាមរយៈបទបង្ហាញស្តីពី នវានុវត្តន៍ការបង្រៀនរបស់លោក **អឿម ឃឿម** នាយកវិទ្យាល័យ នេត យង់ ខេត្តបាត់ដំបង មានប្រសាសន៍ថា *"ការបំប៉នសមត្ថភាពលោកគ្រូអ្នកគ្រូលើការប្រើប្រាស់បច្ចេកវិទ្យានៅវិទ្យាល័យរបស់ខ្ញុំ ពិតជាមានសារៈសំខាន់ខ្លាំងនៅក្នុងការជំរុញឱ្យសិស្សានុសិស្សសិក្សាពីចម្ងាយក្នុងបរិបទជំងឺកូវីដ-១៩បានយ៉ាងឆាប់រហ័ស។ នេះក៏ដោយសារក្រសួងអប់រំ យុវជន និងកីឡាជំរុញ និងលើកទឹកចិត្តយ៉ាងខ្លាំងក្លាដល់លោកគ្រូអ្នកគ្រូដើម្បីជួយអភិវឌ្ឍន៍ក្នុងវិស័យអប់រំ។ វឌ្ឍនភាពនៃការបង្រៀនមុខវិជ្ជា STEM នៅវិទ្យាល័យរបស់ខ្ញុំ គឺការបង្រៀនផ្សារភ្ជាប់ជាមួយការអនុវត្តជាក់ស្តែងលើមុខវិជ្ជាវិទ្យាសាស្ត្រ ហើយទទួលបានការចូលរួមរបស់សិស្សក្នុងបង្រៀន"*។

ឯកឧត្តមបណ្ឌិត **អ៊ុម រមៀណី** អគ្គនាយកនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) បានមានប្រសាសន៍ថា *"ITC កំពុងពង្រីកការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅក្នុងប្រទេសកម្ពុជា។ បេសកកម្មរបស់យើងគឺប្រែក្លាយជាគ្រឹះស្ថានមួយក្នុងចំណោមគ្រឹះស្ថានដែលមានការបណ្តុះបណ្តាលកម្រិតខ្ពស់មានគុណភាពល្អនៅក្នុងប្រទេសជាសមាជិកអាស៊ាន ខាងផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា និងការអប់រំវិស្វកម្មដោយពង្រីកធនធានមនុស្សទាំងនិស្សិត និងមហាវិទ្យាល័យជាមួយនឹងជំនាញដែលពាក់ព័ន្ធទៅនឹងគោលនយោបាយអភិវឌ្ឍឧស្សាហកម្មកម្ពុជា ជួយបំពេញចំណុចខ្វះខាតបច្ចេកទេសឱ្យគ្នានៅក្នុងសេដ្ឋកិច្ចតំបន់តាមរយៈនៃការពង្រឹងសមត្ថភាពស្រាវជ្រាវ និងច្នៃប្រឌិត"*។

មហោស្រពជាតិលើកទី១ទទួលបានការគាំទ្រយ៉ាងច្រើនពីលោកគ្រូអ្នកគ្រូសិស្សានុសិស្ស និងអ្នកពាក់ព័ន្ធ។ វីដេអូចំនួន១១៦ ដែលមកពី១៤ រាជធានី-ខេត្ត ដូចជា ភ្នំពេញ កណ្តាល កំពង់ចាម រតនគិរី បាត់ដំបង ព្រះសីហនុ សៀមរាប ស្វាយរៀង ពោធិ៍សាត់ មណ្ឌលគិរី ឧត្តរមានជ័យ កំពង់ឆ្នាំង បន្ទាយមានជ័យ និងត្បូងឃ្មុំ ត្រូវបានដាក់ប្រកួតប្រជែងក្នុងកម្មវិធីនេះ។

ក្នុងចំណោមវីដេអូទាំងអស់ មានវីដេអូចំនួន៦ក្លឹបទទួលបានជ័យលាភីជាមេដាយមាស និងរង្វាន់លើកទឹកចិត្តជា Labtop មួយគ្រឿង វីដេអូចំនួន១០ទទួលបានជ័យលាភីមេដាយប្រាក់ និងរង្វាន់លើកទឹកចិត្តជា Speaker មួយគ្រឿង និងវីដេអូចំនួន ១០ ទទួលបានជ័យលាភីមេដាយសំរិទ្ធ និងរង្វាន់លើកទឹកចិត្តជា Keyboard & Mouse និងមានរង្វាន់លើកចិត្តទឹក Ear Phone សម្រាប់វីដេអូដែលមិនបានជាប់ជាជ័យលាភី។ សមិទ្ធផលស្នាដៃទាំងនេះបានឆ្លុះបញ្ចាំងអំពីការរីកចម្រើនផ្នែកបច្ចេកវិទ្យាក្នុងការផលិតវីដេអូអប់រំ ជាពិសេសបានបង្ហាញអំពីការយកចិត្តទុកដាក់ពីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់ការអប់រំស្ទែម ដែលអាចឆ្លើយតបនឹងតម្រូវការដែលកំពុងកើនឡើងជាក់ស្តែងនៅក្នុងសតវត្សរ៍ទី២១នេះ៕

# ការត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពគម្រោង

កាលពីថ្ងៃទី១១ ដល់ទី១២ ខែធ្នូ ឆ្នាំ ២០២១ បុគ្គលិកគម្រោងអង្គការ ខេប ចំនួន ៤៣នាក់បានចូលរួមវគ្គការកសាងសមត្ថភាព ស្តីពី **"ការត្រួតពិនិត្យ និងវាយតម្លៃគម្រោងប្រកបដោយប្រសិទ្ធភាព"** នៅសណ្ឋាគារ រ៉ក់រ៉ូយ៉ាល់ក្នុងខេត្តកែប។

វគ្គកសាងសមត្ថភាពនេះធ្វើឡើងដើម្បី៖ **១-**ឱ្យបុគ្គលិកបានយល់ដឹងពីការប្រើប្រាស់ឧបករណ៍ការត្រួតពិនិត្យ និងវាយតម្លៃ។ **២-**បង្កើននូវការទុកចិត្តពីម្ចាស់ជំនួយ តាមរយៈគម្រោងមានការត្រួតពិនិត្យ និងវាយតម្លៃច្បាស់លាស់សម្រាប់វាស់នូវវឌ្ឍនភាពគម្រោង។ **៣-**ធ្វើរបាយការណ៍គម្រោងមានគុណភាពខ្ពស់ និងបង្កើតនូវយន្តការនិរន្តរភាពដល់គម្រោង។

បុគ្គលិកគម្រោងទទួលបានចំណេះដឹងដើម្បីយកទៅអនុវត្តន៍គម្រោងនៅតាមសាលារៀនគោលដៅប្រកបដោយប្រសិទ្ធភាពដូចខាងក្រោម៖

១-ការត្រួតពិនិត្យគឺតាមដាន និងបង្ហាញពីវឌ្ឍនភាពដោយផ្តោតសំខាន់លើធាតុចូល សកម្មភាព លទ្ធផល ហានិភ័យ ការសន្មត់ រយៈពេលអនុវត្តន៍ និងទិន្នន័យគម្រោង។ ការវាយតម្លៃគឺសម្តៅទៅការវាយតម្លៃសមិទ្ធិផលរួម និងរបៀបដែលគម្រោងបានសម្រេចតាមរយៈការប្រើប្រាស់ឧបករណ៍ ដូចជា ការស្ទង់មតិ ទិន្នន័យបន្ទាប់បន្សំ និងផ្សេងទៀត ដោយផ្តោតលើប្រសិទ្ធភាព តាមរយៈទិន្នន័យរបស់គម្រោង តាមកាលកំណត់មួយជាក់លាក់។

២-សារៈសំខាន់នៃការត្រួតពិនិត្យ និងវាយតម្លៃគម្រោងគឺពិតជាសំខាន់សម្រាប់ផ្តល់នូវប្រភពព័ត៌មាន និងភាពបន្សុីគ្នាបានល្អអំពីវឌ្ឍនភាពគម្រោង និងងាយស្រួលសរសេររបាយការណ៍ប្រកបដោយគុណភាពទៅកាន់ម្ចាស់ជំនួយព្រមទាំងធ្វើឱ្យប្រធានគម្រោងធ្វើការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាពខ្ពស់។

៣-សូចនាករជាអ្វីដែលគម្រោងប្រើក្នុងការវាស់វែង ដើម្បីដឹងច្បាស់អំពីទ្រឹស្តីនៃការផ្លាស់ប្តូរក្នុងគម្រោង។ ម៉្យាងទៀត សូចនាករដែលល្អគឺត្រូវបែងចែកឱ្យដាច់រវាងសូចនាករ និងចំណុចគោលដៅ។

៤-វិធីសាស្ត្រក្នុងការបង្កើតការស្រាវជ្រាវ

៥-ដឹងពីវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យបែបផ្ទាល់ និងប្រយោល និង

៦-របៀបផ្តល់មតិត្រឡប់ក្នុងន័យស្ថាបនា និងការសរសេររបាយការណ៍។

លោក **សៅ វណ្ណា** នាយកប្រតិបត្តិអង្គខេប បានមានប្រសាសន៍ថា ***"លទ្ធផលគម្រោងទទួលបានបរាជ័យពេលខ្លះវាបណ្តាលមកពីការរៀបចំគម្រោងនោះឡើងនៅមានចំណុចខ្វះចន្លោះច្រើន ដូច្នេះ ដើម្បីកាត់បន្ថយបញ្ហានៅកាន់តែតិច យើងត្រូវតែគិតឱ្យបានល្អិតជាមុន"***។

បុគ្គលិកគម្រោងចូលរួមក្នុងកម្មវិធីនេះទាំងអស់ទទួលបានចំណេះដឹងល្អៗជាច្រើនទាក់ទងទៅនឹងផ្នែកត្រួតពិនិត្យ និងវាយតម្លៃសម្រាប់វាស់នូវវឌ្ឍនភាពគម្រោងក៏ដូចជាយកចំណុចល្អៗទៅអនុវត្តន៍នៅតាមសាលារៀនគោលដៅប្រកបដោយគុណភាព និងឱ្យកាន់តែមានប្រសិទ្ធភាពទ្វេរឡើង៕



*កម្រងរូបភាពអនុស្សាវរីយ៍ក្នុងវគ្គកសាងសមត្ថភាពស្តីពី ការត្រួតពិនិត្យ និងវាយតម្លៃគម្រោងប្រកបដោយប្រសិទ្ធភាពនៅខេត្តកែប*

# ត្រូវក្លាយជាខ្លួនឯង!

រឿងដ៏សាមញ្ញមួយដែលធ្វើឱ្យអ្នកដទៃតែងតែឃើញស្នាមញញឹមរបស់ខ្ញុំ គឺខ្ញុំជ្រើសរើសយកស្នាមញញឹមទៅបង្ហាញពួកគេហើយរឿងដែលតែងតែធ្វើឱ្យខ្ញុំរីករាយជានិច្ចនោះ គឺខ្ញុំជ្រើសរើសយកការរីករាយ។ រាល់ដងដែលខ្ញុំជ្រុលខ្លួនអង្គុយពិបាកចិត្តលើរឿងដែលមិនច្បាស់លាស់ វាក៏ជាពេលដែលខ្ញុំចាប់ផ្ដើមភ្ញាក់ខ្លួនវិញភ្លាមៗ ហើយខ្ញុំផ្ដើមចោទសួរមកកាន់ខ្លួនឯងនូវសំណួរទាំងនេះ។ តើក្នុងស្ថានភាពបែបនេះ ទឹកមុខអស់សង្ឃឹមបែបនេះ វាអាចដោះស្រាយអ្វីឱ្យប្រសើរជាងមុនបានទេ? សរុបទៅ គ្មាននរណាដែលមានរឿងអស់សំណើច ២៤ម៉ោង ក្នុងមួយថ្ងៃទេ ប៉ុន្តែពេលចួបរឿងលំបាកដែលត្រូវដោះស្រាយ តើយើងត្រូវដោះស្រាយដោយញញឹម ឬក៏យើងត្រូវដោះស្រាយទាំងមុខតប់ប្រមល់?

បីឆ្នាំមុន ជីវិតខ្ញុំត្រូវប្រឈមនឹងរឿងអាក្រក់ព្រមគ្នាក្នុងពេលតែមួយ ខ្ញុំត្រូវបាត់បង់ការងារ គ្មានប្រាក់ខែ ហើយបន្តរស់នៅក្នុងទីក្រុងដែលមានតែការចំណាយគ្រប់វិនាទី(ការស្នាក់នៅ ការហូបចុក ការធ្វើដំណើរ គឺគ្រប់យ៉ាងទាំងអស់) ស្នេហាក៏បរាជ័យ គ្រួសារក៏មានបញ្ហាកើតឡើងជាហូរហែ ហើយមិត្តភក្ដិដែលធ្លាប់ស្គាល់រាប់អានគ្នាក៏រសាត់ឆ្ងាយអស់រលីង។ ក្នុងពេលហ្នឹង ខ្ញុំបានដាក់សំណួរមកកាន់ខ្លួនឯង។ តើខ្ញុំត្រូវការអ្វីពីជីវិតនេះ? ចម្លើយ ខ្ញុំត្រូវការសេរីភាព ត្រូវការភាពរីករាយ ត្រូវការទំនុកចិត្ត ត្រូវការក្ដីសង្ឃឹម ត្រូវការភាពរឹងមាំ ក្លាហាន ត្រូវការមិត្តល្អៗ។ ចុះតើខ្ញុំនឹងបានអ្វីទាំងនោះដោយរបៀបណា? ពេលហ្នឹង ខ្ញុំមើលមិនឃើញសោះ ថានរណាម្នាក់ដែលអាចផ្ដល់វាមកឱ្យខ្ញុំបាន។ មនុស្សដែលយើងចង់នៅជិតក៏បានចាកចេញឆ្ងាយ។ មនុស្សដែលយើងចង់រត់គេចមិនឱ្យចួប យើងក៏ត្រូវចួបរាល់ថ្ងៃ។ កន្លែងដែលយើងមិនចង់ទៅ ប៉ុន្តែយើងក៏ត្រូវតែទៅ។ កន្លែងដែលយើងមិនចង់នៅ តែចុងក្រោយក៏បន្តនៅព្រោះវាគ្មានជម្រើសអ្វីដែលល្អជាងហ្នឹង។

ជីវិតនេះពិតជាមិនព្រមបញ្ចប់ត្រឹមភាពលំបាកទាំងអស់ហ្នឹងពិតមែន។ នៅព្រឹកមួយនោះ ខ្ញុំភ្ញាក់ពីគេងនៅកន្លែងដដែល ប៉ុន្តែខ្ញុំមានអារម្មណ៍អស្ចារ្យមួយ ដែលវាមិនមែនជាអារម្មណ៍កាលពីម្សិលមិញនោះទេ។ ខ្ញុំបានរលាស់ខ្លួនចេញពីកន្លែងគេងយ៉ាងមានកម្លាំងនិងស្រស់ស្រាយបំផុត។ ខ្ញុំនឹកទៅដល់រឿងមួយ ហេតុអ្វីបានជាខ្ញុំត្រូវមកខ្វះខ្វាយនឹកគិតតែពីរឿងដែលវាមិនអាចសូម្បីតែធ្វើឱ្យខ្ញុំញញឹមបានដូច្នេះ? តើមាននរណាមកខ្វល់នឹងទឹកមុខដ៏កម្សត់របស់ខ្ញុំ? តើមាននរណាមកខ្វល់ថាស្ថានភាពជីវិតរបស់ខ្ញុំលំបាកកម្រិតណា? បើពេលហ្នឹង ខ្ញុំកំពុងតែស្ថិតនៅក្នុងស្ថានភាពអាក្រក់បែបហ្នឹងនោះ?

បើសុខមកដល់ ក៏ត្រេកអរនឹងវាទៅ ហើយបើទុក្ខមកដល់ ក៏ប្រឈមមុខដោះស្រាយទៅ។ ជីវិតយើងគ្រប់គ្នាសុទ្ធតែមានបញ្ហាដែលត្រូវប្រឈមដោះស្រាយ មានរឿងដែលត្រូវគិត ហើយគ្រប់យ៉ាងដែលកើតចេញពីការសម្រេចចិត្តរបស់យើង វាត្រូវតែជាការទទួលខុសត្រូវរបស់យើងខ្លួនឯង។ ការដែលព្យាយាមយកជីវិតរបស់យើងទៅឆ្លុះមើលជីវិតអ្នកដទៃ ហើយរស់នៅដោយការប្រៀបធៀបជាប្រចាំ វាមិនបានធ្វើឱ្យមានការប្រសើរអ្វីឡើយ។

*(ដកស្រង់ចេញពី #ដើរចេញពីអតីតកាល )*



រូបភាព #Pinterest

# ប្រឡងបាក់ឌុប ២០២១ !

(បទ ពាក្យប្រាំពីរ)

១ គ្រឹះស្ថានសិក្សាគ្រប់កម្រិត
ទុតិយ.បឋមភូមិក្តី
បឋមត្រូវបិទ និងមត្តេយ្យ
ប្រឡងលើកថ្ងៃព្រោះកូវ៉ូណា។

២ ប្រឡងបាក់ឌុបត្រូវពន្យា
សិស្សានុសិស្សត្រៀមកាយា
លើកពេលវេលាជាច្រើនសា
ចាំដំណឹងសារប្រកាសផ្សាយ។

៣ ក្រសួងអប់រំបានសម្រេច
វេលារំកិលនៅមិនឆ្ងាយ
កំណត់ជាស្រេចនឹងបរិយាយ
កៀកជិតបង្កើយគួរខំខិត។

៤ ម្ភៃប្រាំពីរធ្នូពីរពាន់ម្ភៃមួយ
ប្រឡងបាក់ឌុបនឹងប្រព្រឹត្ត
យុវសិស្សនឹកព្រួយរំពឹងគិត
ពុទ្ធិគំនិតត្រូវពង្រឹង។

៥ សិស្សមើលមេរៀន និងលំហាត
ខំធ្វើលំហាត់ដែលតឹងរឹង
មោះមុតជុះខាត់ចំណេះដឹង
ខិតខំប្រែងប្រឹងទុកប្រឡង។

៦ រៀនហើយរៀនទៀតរៀនឱ្យចាំ
ទើបអាចបកស្រាយពេលប្រឡង
រៀនយល់ចំណាំស្ទាត់កន្លង
មិនលួចចម្លងខុសមាត្រា។

៧ បាក់ឌុបនៅតែរឹតបន្តឹង
អ្នកចេះ គឺជាប់ដោយប្រាជ្ញា
វិន័យពង្រឹងយ៉ាងខ្លាំងក្លា
សូកប៉ាន់តវ៉ាខុសវិន័យ។

៨ សម័យទំនើបពិតជឿជាក់
សុក្រឹតយុត្តិធម៌មានតម្លៃ
ប្រឡងជាប់ធ្លាក់កុំព្រួយភ័យ
ពិន្ទុបំភ្លៃពុំកើតមាន។

៩ ដូច្នេះសិស្សត្រូវតែប្រឹងប្រែង
ពិន្ទុសញ្ញាបត្រពីរៀន
ព្យាយាមរមែងជោគជ័យបាន
បន្តជាស្ពានទៅបវរ។

១០ ១០ជាចុងបញ្ចប់សូមពរជ័យ
បំបាត់ភិតភ័យកើតត្រេកអរ
សិរីសួស្តី និងបវរ
យកនិទ្ទេសល្អជូនគ្រួសារ៕



ស្នាដៃនិពន្ធដោយ
**ថា លីជា**
សិស្សថ្នាក់ទី១០
សាលារៀនជំនាន់ថ្មី
វិទ្យាល័យហ៊ុន សែន
ពាមជីកង




# គ្រូបង្រៀនរក្សាបានតួនាទីសំខាន់



## ក្នុងការអប់រំគ្រប់កាលៈទេសៈ

(បទ កាកគតិ)



១. ខ្ញុំសូមសាសព្ទ រៀបរាប់រាយរ៉ាប់ នូវទិវាន័យ
គុណគ្រូបង្រៀន ពិតជាសក្ខី ប្រារព្ធប្រពៃ
ទីប្រាំតុលា។

២. ជារៀងរាល់ឆ្នាំ គ្រប់គ្នាចំណាំ ពិសេសសិស្សា
តែងតែរឭក គុណគ្រូសាស្ត្រា បុព្វហេតុនេះណា
តមកសព្វថ្ងៃ។

៣. លោកគ្រូអ្នកគ្រូ ពិតជាគម្រូ ដល់សិស្សប្រុសស្រី
ផ្តល់ចំណេះដឹង គិតគូរកែច្នៃ ឱ្យសិស្សគ្រប់វ័យ
ទទួលអប់រំ។

៤. តាំងពីដើមមក គ្រូពិតលៃលក បង្រៀនជួបជុំ
ក្នុងថ្នាក់មួយៗ សិស្សប្រមូលផ្តុំ គ្រូលៃសន្សំ
តាមមាគ៌ាពិត។

៥. ចូលពីរពាន់ម្ភៃ បានប្រែផ្លាស់ថ្មី ព្រោះតែកូវីដ
បង្រៀនតាមZoom បង្រៀនតាមMeet គ្រូសិស្សឆ្ងាយឆិត
នៅតែបន្ត។

៦. រៀនប្រើកម្មវិធី នៅគ្រប់ទិសទី ក៏បង្រៀនល្អ
ព្រោះតែចំណេះ មិនអាចកករ ខិតខំគាំទ្រ
ទោះបីនឿយហត់។

៧. សូមកោតសរសើរ ដល់គ្រូដែលប្រើ ប្រាស់គ្រប់កំណត់
បច្ចេកវិទ្យា ដាក់មកសង្កត់ ឱ្យពិតប្រាកដ
ទើបបានប្រពៃ។

៨. សង្ឃឹមសិស្សចេះ ដោយប្រើចំណេះ គំនិតកែច្នៃ
ទ្រទ្រង់សង្គម ជាតិឱ្យថ្លាថ្លៃ សមស្របសម័យ
យុគឌីជីថល។

៩. ទាំងគ្រូទាំងសិស្ស រិះរកគន្លឹះ វិធីគ្មានសល់
ខិតខំឃ្មាតខ្មី ឱ្យបានលទ្ធផល ជ្បិតអីសកល
ជួបនូវវិបត្តិ។

១០.ទឹកចិត្តគ្រូៗ គ្មានអ្វីផ្លាស់ប្តូរ គ្មានអ្វីមកកាត់
ឧត្តុងឧត្តម ព្យាយាមដុសខាត់ លក្ខណៈសម្បត្តិ
ពិតបានថ្កើនថ្កាន។

១១.សូមថ្លែងអំណរ ពរជ័យបវរ ដល់គ្រូគ្រប់ប្រាណ
សុខភាពប្រពៃ គ្មានអ្វីខកខាន ជោគជ័យសុខសាន្ត
តទៅរៀងអើយ៕

និពន្ធដោយ៖ **កញ្ញា ស៊ឹម ផល្លី**
ប្រធានក្រុមគម្រោងអប់រំកុមារី អង្គការ ខេប

*"គ្រូបង្រៀនរក្សាបានតួនាទីសំខាន់ក្នុងការអប់រំគ្រប់កាលៈទេសៈ"*

*អបអរសាទរ ទិវាគ្រូបង្រៀន*
*០៥ តុលា ២០២១*



# មនុស្សរឹងមាំ !

មនុស្សរឹងមាំមិនមែនជាមនុស្សដែលពូកែលាក់ការឈឺចាប់ទេ។ វាក៏មិនមានន័យថា យើងមិនត្រូវការឲ្យនរណាដឹងពីការឈឺចាប់ ឬមិនត្រូវការជំនួយនោះឡើយ។ មនុស្សរឹងមាំមិនមែនជាមនុស្សដែលតែងតែបដិសេធការជួយពីនរណាម្នាក់នោះទេ ហើយក៏មិនមែនជាមនុស្សដែលចង់តស៊ូចំពោះបញ្ហាតែម្នាក់ឯងនោះដែរ។

មនុស្សរឹងមាំមិនមែនជាមនុស្សដែលអាចគេចផុតពីបញ្ហាទេ ប៉ុន្តែជាមនុស្សដែលហ៊ានប្រឈមជាមួយបញ្ហានៅចំពោះមុខ។ មនុស្សរឹងមាំនឹងមិនបង្កើតបញ្ហាមួយទៀតដើម្បីលាក់បាំងបញ្ហាដែលបានកើតឡើងនោះឡើយ។ ផ្ទុយទៅវិញ គេជាមនុស្សដែលហ៊ានទទួលយកការពិតនៅចំពោះមុខ។ មនុស្សរឹងមាំក្លាហានដើម្បីសុំជំនួយពីនរណាម្នាក់បន្ទាប់ពីខ្លួនបានខិតខំប្រឹងបែងអស់លទ្ធភាពហើយ។


រូបភាព #Pinterest

ចង់ធ្វើជាមនុស្សរឹងមាំម្នាក់ដែរមែនទេ ? មិនបាច់ញញឹមដើម្បីទប់ទឹកភ្នែកកុំឲ្យស្រក់ចុះនោះទេ។ បើមានអារម្មណ៍ថា វាចង់ស្រក់ចុះមកហើយ សូមអនុញ្ញាតឲ្យវាស្រក់ឲ្យអស់ចិត្តមក។ អ្វីដែលយើងត្រូវធ្វើគឺជូតទឹកភ្នែកចេញ រួចហើយញញឹមសារជាថ្មីម្តងទៀត។ ធម្មជាតិបង្កើតមនុស្សមកគ្រប់គ្នាអាចសើច អាចយំ អាចមានទុក្ខ អាចឈឺចាប់ អាចរីករាយ។

ដូច្នេះ សូមគ្រាន់តែអនុញ្ញាតឲ្យភ្នែករបស់យើងអាចបង្ហូរទឹកភ្នែក ពេលដែលមាត់របស់យើងមិនអាចនិយាយបាន។ វាមិនអីទេ យើងមិនមែនជាមនុស្សទន់ជ្រាយទេ បើគ្រាន់តែយើងយំ ដោយសារតែពិបាកទ្រាំនោះ៕

*(ដកស្រង់ចេញពីសៀវភៅ #វិញ្ញាសាជីវិត )*

# មតិអ្នកអាន



សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ គម្រោងសាលារៀនជំនាន់ថ្មីរបស់អង្គការ ខេប ដែលបានជួយគាំទ្រដល់សាលាយើងខ្ញុំទាំងសម្ភារៈ និងបច្ចេកទេស ធ្វើឱ្យបុគ្គលិកអប់រំ នឹងអ្នកពាក់ព័ន្ធមានសមត្ថភាពចូលរួមអភិវឌ្ឍវិស័យអប់រំប្រកបដោយប្រសិទ្ធភាព៕

លោក **សោម សំ**

នាយកសាលារៀនជំនាន់ថ្មីបឋមសិក្សាស្វាយព្រហូត